# កម្ពុជា

# ការវាយតម្លៃលើតម្រូវការហិរញ្ញប្បទាន
# នៃយុទ្ធសាស្ត្រជាតិគាំពារសង្គម
# សម្រាប់ជនក្រីក្រនិងជនងាយរងគ្រោះ

**បោះពុម្ពឆ្នាំ២០១២**

ឯកសារនេះ គឺជាការបកប្រែពីឯកសារជាភាសាអង់គ្លេស **“Cambodia : Financial assessment of the National Social Protection Strategy for the Poor and Vulnerable”** ដែលបានរៀបចំឡើងដោយទីប្រឹក្សាជាន់ខ្ពស់នៃអង្គការអន្តរជាតិខាងការងារ ក្នុងគម្រោង **ILO-EU** ស្តីពី "ការបង្កើនកិច្ចគាំពារសង្គមនិងការងារ" ក្រោមកិច្ចសហប្រតិបត្តិការជាមួយ ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ និងស្ថាប័នពាក់ព័ន្ធដទៃទៀតនៃក្រុមការងារបណ្តោះអាសន្នសម្រាប់ការគាំពារសង្គម។ ការបកប្រែឯកសារនេះមកជាភាសាខ្មែរ និងការប្រើប្រាស់ពាក្យពេជន៍ទាំងឡាយនៅក្នុងឯកសារនេះ ពុំឆ្លុះបញ្ចាំងតំណាងឱ្យគោលជំហររបស់ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទឡើយ។

# សេចក្ដីថ្លែងអំណរគុណ

ឯកសារនេះជាផ្នែកមួយនៃបណ្ដារបាយការណ៍សហប្រតិបត្តិការបច្ចេកទេស ដែលបាន រៀបចំឡើងដោយ**នាយកដ្ឋានគោលនយោបាយមុខរបរ** និង**នាយកដ្ឋានរបបសន្តិសុខសង្គម** នៃ**អង្គការអន្តរជាតិខាងការងារ** ហើយស្ថិតនៅក្រោមក្របខណ្ឌគម្រោង ILO-EU ស្ដីពី **ការបង្កើនកិច្ចគាំពារសង្គមនិងការងារ**។ គម្រោងនេះបានទទួលហិរញ្ញប្បទានពីស្ថានបេសកកម្មសហគមន៍អឺរ៉ុប ហើយបានអនុវត្តនៅប្រទេសចំនួនបីរួមមាន Burkina Faso កម្ពុជា និង Honduras។

លោក Jean-Claude Hennicot ដែលជាទីប្រឹក្សាបច្ចេកទេស ក្នុងនាមអង្គការអន្តរជាតិខាងការងារជាអ្នករៀបចំឯកសារនេះ។ អ្នកនិពន្ធសូមធ្វើការថ្លែងអំណរគុណ យ៉ាងជ្រាលជ្រៅដល់កិច្ច សហប្រតិបត្តិការដែលទទួលបានពីក្រសួង-ស្ថាប័នពាក់ព័ន្ធពិសេសគឺក្រុមប្រឹក្សាស្ដារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ។ ជាពិសេស អ្នកនិពន្ធថ្លែងអំណរគុណចំពោះការចូលរួមផ្ដល់មតិកែលំអរ ពីសំណាក់ឯកឧត្តម **ងី ច័ន្ទ្រផល** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធាន ក.ក.ជ ឯកឧត្តមបណ្ឌិត **សាន វឌ្ឍនា** អគ្គលេខាធិការរងក.ក.ជ លោកស្រីវេជ្ជបណ្ឌិត **សុក កញ្ញា** អនុប្រធាននាយកដ្ឋានផែនការនិងព័ត៌មានសុខាភិបាលក្រសួងសុខាភិបាល លោក Helmut Schwarzer ប្រធានទីប្រឹក្សាបច្ចេកទេសនៃគម្រោង ILO-EU ស្ដីពីការបង្កើនកិច្ចគាំពារសង្គមនិងការងារ លោក Hiroshi Yamabana ទីប្រឹក្សាផ្នែករបបសន្តិសុខសង្គម និងលោក André Acuña-Ulate ទីប្រឹក្សាផ្នែករបបសន្តិសុខសង្គមនៃអង្គការអន្តរជាតិខាងការងារ។ អ្នកនិពន្ធក៏សូមថ្លែងអំណរគុណជាពិសេស ជូនចំពោះលោកស្រី **ឌិក ម៉ាលីកា** អ្នកសម្របសម្រួលគម្រោងថ្នាក់ជាតិ សម្រាប់ការគាំទ្រជាប្រចាំក្នុងកំឡុងបេសកកម្មរបស់អ្នកនិពន្ធនៅកម្ពុជា។ អ្នកនិពន្ធ សូមទទួលខុសត្រូវទាំងស្រុងចំពោះកំហុសឆ្គង និងសេចក្ដីធ្វេសប្រហែសដោយអចេតនា ដែលមាននៅក្នុងរបាយការណ៍នេះ។

# មាតិកា


**សេចក្តីថ្លែងអំណរគុណ**

**ជំពូក ១ លំនាំដើម** ........................................ ១

**ជំពូក ២ លក្ខណៈទូទៅនៃយុទ្ធសាស្ត្រជាតិគាំពារសង្គម** ........................................ ៤

២.១ សាវតា ........................................ ៤

២.២ សមាសភាពនៃ យ.ជ.គ.ស ........................................ ៥

**ជំពូក៣ ជម្រើសគោលនយោបាយសម្រាប់ កម្មវិធីគាំពារសង្គម**

៣.១ គោលដៅទី១ ការដោះស្រាយបញ្ហាសន្តិសុខស្បៀងនិងជំនួយសង្គ្រោះបន្ទាន់ ....... ៩

៣.២ គោលដៅទី២ ការកាត់បន្ថយភាពងាយរងគ្រោះលើកុមារ និងមាតា..................... ១២

៣.៣ គោលដៅទី៣ ការដោះស្រាយបញ្ហានិកម្មភាពដែលកើតឡើងជាលក្ខណៈរដូវកាល. ១៥

៣.៤ គោលដៅទី៤ ការពង្រីកការគាំពារសុខភាពសង្គម ........................................ ១៦

៣.៥ គោលដៅទី៥ ការពង្រីកការគាំពារសម្រាប់ក្រុមជនងាយរងគ្រោះពិសេស ............ ១៧

៣.៥.១ ការឧបត្ថម្ភប្រាក់ចំណូលសម្រាប់ជនចាស់ជរា........................................ ១៧

៣.៥.២ ការឧបត្ថម្ភប្រាក់ចំណូលសម្រាប់ជនពិការ ........................................ ២០

៣.៦ សេចក្តីសង្ខេបស្តីពីជម្រើសគោលនយោបាយ ........................................ ២១

**ជំពូក៤ ការវាយតម្លៃផ្នែកហិរញ្ញប្បទានសម្រាប់ ជម្រើសគោលនយោបាយ**

៤.១ គោលដៅទី១ ការដោះស្រាយបញ្ហាសន្តិសុខស្បៀងនិងជំនួយសង្គ្រោះបន្ទាន់........ ២៤

៤.២ គោលដៅទី២ ការកាត់បន្ថយភាពងាយរងគ្រោះលើកុមារនិងមាតា ..................... ២៦

៤.៣ គោលដៅទី៣ ការដោះស្រាយបញ្ហានិកម្មភាពជាលក្ខណៈរដូវកាល .................... ២៨

៤.៤ គោលដៅទី៤ ការពង្រីកវិសាលភាពការគាំពារសុខភាព........................................ ៣០

៤.៥ គោលដៅទី៥ ការពង្រីកវិសាលភាពនៃការគាំពារសង្គម សម្រាប់ជនងាយរងគ្រោះពិសេស ........................................ ៣១

**ជំពូក៥ សេចក្តីសន្និដ្ឋាននិងសង្ខេប**

៥.១ ការឧបត្ថម្ភសាច់ប្រាក់សម្រាប់ជនក្រីក្រគ្រប់រូប ........................................ ៣៨

៥.២ កម្មវិធីផ្តោតទៅលើក្រុមជនងាយរងគ្រោះក្នុងចំណោមជនក្រីក្រ........................ ៣៩

៥.៣ កម្មវិធីដែលផ្តល់លាភការជាសកលសម្រាប់ប្រជាជនគ្រប់គ្នា ............................ ៤០

៥.៤ សេចក្តីសន្និដ្ឋាន........................................ ៤១

**ឧបសម្ព័ន្ធ ក្របខណ្ឌនៃម៉ូដែល និងការសន្មត** ........................................ ៤៣

| | | |
|---|---|---|
| ៦. | ប្រជាករ | ៤៣ |
| ៦.២ | កម្លាំងពលកម្ម និងការងារ | ៤៣ |
| ៦.៣ | ផលក្នុងស្រុកសរុប ថ្លៃទំនិញ និងប្រាក់កម្រៃការងារ | ៤៤ |
| ៦.៤ | ការសន្មតស្តីពីភាពក្រីក្រ | ៤៦ |
| ៦.៤.១ | បន្ទាត់នៃភាពក្រីក្រ | ៤៧ |
| ៦.៤.២ | អត្រានៃភាពក្រីក្រដោយរាប់តាមមនុស្ស | ៤៨ |
| ៦.៥ | ការសន្មតជាក់លាក់សម្រាប់កម្មវិធី | ៥១ |
| ៦.៥.១ | ជម្រើសគោលនយោបាយទី៣ និង៣ស | ៥១ |
| ៦.៥.២ | ជម្រើសគោលនយោបាយទី៦ និងទី៧ | ៥២ |
| ៦.៥.៣ | ជម្រើសគោលនយោបាយទី ១២ និងទី១២ស | ៥២ |
| ៦.៦ | ការប៉ាន់ប្រមាណលើថវិកាចំណាយសម្រាប់ការថែទាំសុខភាព សម្រាប់ជនក្រីក្រ | ៥៣ |
| ៦.៦.១ | អភិក្រមនៃម៉ូដែល | ៥៤ |
| ៦.៦.២ | ទិន្នន័យគោល | ៥៥ |
| ៦.៦.៣ | អត្រានៃការប្រើប្រាស់សេវា | ៥៥ |
| ៦.៦.៤ | ថវិកាចំណាយក្នុងមួយឯកតា | ៥៧ |
| ៦.៦.៥ | វិសាលភាព | ៥៨ |
| ៦.៦.៦ | លទ្ធផលនៃការធ្វើនិទស្សន៍ | ៥៨ |
| **ឯកសារពិគ្រោះ** | | ៦០ |

# បញ្ជីតារាង


| | | |
|---|---|---|
| តារាង២.១ | គោលដៅរបស់ យ.ជ.គ.ស. និងការផ្សារភ្ជាប់ជាមួយគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ........ | ៦ |
| តារាង ៣.១ | ជម្រើសគោលនយោបាយទី១ និងទី២ : ការធានាសន្តិសុខស្បៀងសម្រាប់ជនក្រីក្រ ........ | ១១ |
| តារាង ៣.២ | ជម្រើសគោលនយោបាយទី៣, ៤ និង៥ : ការឧបត្ថម្ភសាច់ប្រាក់សម្រាប់កុមារ និងមាតាក្រីក្រ ........ | ១៣ |
| តារាង ៣.៣ | ជម្រើសគោលនយោបាយទី៣ស ៤ស និង៥ស : ការឧបត្ថម្ភសាច់ប្រាក់សម្រាប់មាតា និងកុមារគ្រប់រូប ជាលក្ខណៈសកល ........ | ១៤ |
| តារាង៣.៤ | ជម្រើសគោលនយោបាយទី៦ និងទី៧: កម្មវិធីសំណង់សាធារណៈ ........ | ១៦ |
| តារាង ៣.៥ | ជម្រើសគោលនយោបាយទី៩ ទី១០ និងទី១១ : របបសោធននិវត្តន៍សម្រាប់ជនចាស់ជរាក្រីក្រ ........ | ១៨ |
| តារាង ៣.៦ | ជម្រើសគោលនយោបាយទី៩ស ទី១០ស ទី១១ស : របបសោធននិវត្តន៍សម្រាប់ជនចាស់ជរាគ្រប់រូបជាលក្ខណៈសកល ........ | ១៩ |
| តារាង ៣.៧ | ជម្រើសគោលនយោបាយទី១២ និងទី១២ស : របបសោធនសម្រាប់ជនពិការ | ២០ |
| តារាង ៣.៨ | សេចក្តីសង្ខេបស្តីពីជម្រើសគោលនយោបាយ ........ | ២១ |
| តារាង ៤.១ | ការនិទស្សន៍ផ្នែកហិរញ្ញប្បទានសម្រាប់ជម្រើសគោលនយោបាយទី១ និង ទី២ ៖ ការដោះស្រាយបញ្ហាសន្តិសុខស្បៀងសម្រាប់ជនក្រីក្រ ........ | ២៥ |
| តារាង ៤.២ | ការនិទស្សន៍ផ្នែកហិរញ្ញប្បទានសម្រាប់ជម្រើសគោលនយោបាយទី៣ ទី៤ និង ទី៥ ៖ ការឧបត្ថម្ភសាច់ប្រាក់សម្រាប់មាតានិងកុមារក្រីក្រ ........ | ២៧ |
| តារាង ៤.៣ | ការនិទស្សន៍ផ្នែកហិរញ្ញប្បទានសម្រាប់ជម្រើសគោលនយោបាយទី៣ស ទី៤ស និង ទី៥ស ៖ ការឧបត្ថម្ភសាច់ប្រាក់សម្រាប់មាតានិងកុមារ ជាលក្ខណៈសកល ........ | ២៨ |
| តារាង ៤.៤ | ការនិទស្សន៍ផ្នែកហិរញ្ញប្បទានសម្រាប់ជម្រើសគោលនយោបាយទី៦ និងទី៧ ៖ កម្មវិធីសំណង់សាធារណៈ ........ | ២៩ |
| តារាង ៤.៥ | ការនិទស្សន៍ផ្នែកហិរញ្ញប្បទានសម្រាប់ជម្រើសគោលនយោបាយទី៨ ៖ ការពង្រីកមូលនិធិសមធម៌ ........ | ៣០ |
| តារាង ៤.៦ | ការនិទស្សន៍ផ្នែកហិរញ្ញប្បទានសម្រាប់ជម្រើសគោលនយោបាយទី៩ ទី១០ និង ទី១១ ៖ របបសោធន សម្រាប់ជនចាស់ជរាក្រីក្រ ........ | ៣២ |

តារាង ៤.៧ ការនិទស្សន៍ផ្នែកហិរញ្ញប្បទានសម្រាប់ជម្រើសគោលនយោបាយទី៩ស ទី១០ស និង ទី១១ស ៖ របបសោធនសម្រាប់ជនចាស់ជរាទាំងអស់ ជាលក្ខណៈសកល ...... ៣៣
តារាង ៤.៨ ការនិទស្សន៍ផ្នែកហិរញ្ញប្បទានសម្រាប់ជម្រើសគោលនយោបាយទី១២ និងទី១២ស ៖ របបសោធនសម្រាប់ជនពិការ ...... ៣៥
តារាង៥.១ តារាងសង្ខេបស្ដីពីជម្រើសគោលនយោបាយនិងលទ្ធផលនៃការនិទស្សន៍ ...... ៤១
តារាង៦.១ ទិន្នន័យប្រជាករ ៖ ចំនួនសរុប និងចំនួនទៅតាមក្រុមអាយុ ដែលនិទស្សន៍សម្រាប់ ២០១២-២០២០ ...... ៤៣
តារាង ៦.២ ទិន្នន័យអត្រាចូលរួមក្នុងទីផ្សារការងារ និងនិកម្មភាព និទស្សន៍សម្រាប់ឆ្នាំ ២០១២-២០២០ ...... ៤៤
តារាង ៦.៣ ផលទុនជាតិសរុប និងនិទស្សន៍សម្រាប់ឆ្នាំ ២០១២-២០២០ ...... ៤៥
តារាង ៦.៤ សន្ទស្សន៍ថ្លៃទំនិញរបស់អ្នកប្រើប្រាស់ និងសន្ទស្សន៍អតិផរណានៃប្រាក់កម្រៃ និទស្សន៍ សម្រាប់ឆ្នាំ ២០១២-២០២០ ...... ៤៥
តារាង ៦.៥ ខ្សែបន្ទាត់នៃភាពក្រីក្រសម្រាប់ប្រទេសកម្ពុជា ១៩៩៣-២០០៩ ...... ៤៧
តារាង ៦.៦ បន្ទាត់នៃភាពក្រីក្រ និទស្សន៍សម្រាប់ឆ្នាំ ២០០៩-២០២០ ...... ៤៨
តារាង ៦.៧ អត្រាប្រេវ៉ាឡង់នៃភាពក្រីក្រ និទស្សន៍សម្រាប់ឆ្នាំ ២០១០ - ២០២០ (គិតជាភាគរយនៃប្រជាជន) ...... ៤៩
តារាង ៦.៨ ចំនួនប្រជាជនក្រីក្រ និទស្សន៍សម្រាប់ឆ្នាំ ២០១០ - ២០២០ ...... ៥០
តារាង ៦.៩ ភាពក្រីក្រដោយរាប់តាមមនុស្ស ទៅតាមក្រុមអាយុ សម្រាប់ឆ្នាំ២០១២ ...... ៥០
តារាង ៦.១០ អត្រាបង្កកំណើតទៅតាមក្រុមអាយុ និងអត្រាបង្កកំណើតសរុប និទស្សន៍សម្រាប់ឆ្នាំ ២០១២ - ២០២០ ...... ៥១
តារាង ៦.១១ អត្រាប្រេវ៉ាឡង់នៃពិការភាព ទៅតាមក្រុមអាយុ និងភេទនៅឆ្នាំ ២០០៨ ...... ៥៣
តារាង ៦.១២ អត្រានៃការប្រើប្រាស់សេវាថែទាំសុខភាព សន្មតសម្រាប់ឆ្នាំ ២០១០-២០២០ ៥៦
តារាង ៦.១៣ ការសម្រាលកូន ក្រោមកម្មវិធីមូលនិធិសមធម៌និទស្សន៍សម្រាប់ឆ្នាំ ២០១២ - ២០២០ ...... ៥៦
តារាង ៦.១៤ ថវិកាចំណាយក្នុងមួយឯកតាសម្រាប់លាភការ ក្នុងកម្មវិធីមូលនិធិសមធម៌ និទស្សន៍សម្រាប់ឆ្នាំ ២០១២ - ២០២០ ...... ៥៧
តារាង ៦.១៥ ចំនួននៃការមកពិនិត្យព្យាបាល សម្រាប់មូលនិធិសមធម៌ និទស្សន៍សម្រាប់ឆ្នាំ ២០១២ - ២០២០ ...... ៥៨
តារាង ៦.១៦ ថវិកាចំណាយសម្រាប់ការចំណាយដោយផ្ទាល់ នៅក្នុងមូលនិធិសមធម៌ និទស្សន៍សម្រាប់ឆ្នាំ ២០១២ - ២០២០ (គិតជាពាន់ដុល្លារ) ...... ៥៩

# បញ្ជីរូបភាព


រូបភាព ៥.១ កម្មវិធីឧបត្ថម្ភសាច់ប្រាក់ដល់ជនក្រីក្រ ៖ និទស្សន៍ថវិកាចំណាយសម្រាប់ឆ្នាំ ២០១២-២០២០ (គិតជាភាគរយនៃផលក្នុងស្រុកជាតិសរុប) ..................... ៣៨

រូបភាព ៥.២ កម្មវិធីដែលផ្តោតទៅលើក្រុមជនងាយរងគ្រោះ ក្នុងចំណោមជនក្រីក្រ ៖ និទស្សន៍លើថវិកាចំណាយ សម្រាប់ឆ្នាំ២០១៣-២០២០ (គិតជាភាគរយនៃផលទុនជាតិសរុប)........................................................................... ៣៩

រូបភាព ៥.៣ លាភការជាលក្ខណៈសកល .................................................................. ៤០

# ជំពូក ១
# សេចក្តីផ្តើម

ការវាយតម្លៃដែលបង្ហាញនៅក្នុងឯកសាររបាយការណ៍នេះ បានរៀបចំឡើងក្រោមក្របខណ្ឌនៃគម្រោង ILO-EU ស្តីពី**ការបង្កើនកិច្ចគាំពារសង្គមនិងការងារ** ដោយមានកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធ ជាមួយ**ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ**។ ក្នុងក្របខណ្ឌដដែលនេះ គម្រោង ILO-EU ក៏បានរៀបចំឯកសារការវាយតម្លៃលើថវិកាចំណាយលើការគាំពារសង្គមនិង ការត្រួតពិនិត្យលើការអនុវត្ត ដែលបានធ្វើឡើងក្នុងកំឡុងឆ្នាំ២០១១ ហើយផលិតជាឯកសារវិភាគស៊ីជម្រៅមួយ (ILO 2012)។

ឯកសារ**យុទ្ធសាស្ត្រជាតិគាំពារសង្គមសម្រាប់ជនក្រីក្រនិងជនងាយរងគ្រោះ** (យ.ជ.គ.ស)បានកំណត់ទស្សនៈវិស័យវែងឆ្ងាយ និងក្របខណ្ឌយុទ្ធសាស្ត្រ សម្រាប់ការបង្កើតនិងពង្រីកវិសាលភាពនៃការគាំពារសង្គម ដោយផ្តោតការយកចិត្តទុកដាក់លើទិដ្ឋភាពផ្សេងៗគ្នានៃការគាំពារសង្គម និងស្ថានភាពហានិភ័យនៃជនក្រីក្រនិងជនងាយរងគ្រោះនៅកម្ពុជា។ ការរៀបចំបង្កើតកម្មវិធីគាំពារសង្គមថ្មីៗក្រោមក្របខណ្ឌយុទ្ធសាស្ត្រដែលកំណត់ដោយ **យ.ជ.គ.ស** នឹងទាមទារឲ្យមានការរៀបចំផែនការ ការកំណត់គោលនយោបាយ និងការប្រើប្រាស់ធនធាន ដែលចាប់ផ្តើមចេញពីភាពជាយុទ្ធសាស្ត្រ ឲ្យស្តែងទៅជាការអនុវត្តជាក់ស្តែង។ ដំណើរការនេះនឹងពាក់ព័ន្ធជាមួយការចូលរួមរបស់ក្រសួង-ស្ថាប័នជាច្រើនរួមទាំង ក.ក.ជ ក្រសួង-ស្ថាប័ននៃរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍសំខាន់ៗមួយចំនួន។

គោលដៅនៃឯកសារ **ការវាយតម្លៃលើតម្រូវការហិរញ្ញប្បទាននៃយុទ្ធសាស្ត្រជាតិគាំពារសង្គមសម្រាប់ជនក្រីក្រនិងជនងាយរងគ្រោះ**នេះ គឺដើម្បីគាំទ្រដល់ដំណើរការរៀបចំផែនការ តាមរយៈការវាយតម្លៃជាបឋមលើហិរញ្ញប្បទានសម្រាប់ជម្រើសគោលនយោបាយផ្សេងៗគ្នា ដែលអាចនឹងត្រូវជ្រើសរើស។ គោលបំណងជាក់លាក់នៃឯកសារនេះ គឺដើម្បីបង្ហាញបច្ច័យនៃការរៀបចំបង្កើតគោលនយោបាយលើតម្រូវការធនធាន។ ការប្រើប្រាស់ធនធានហិរញ្ញវត្ថុ តាមរយៈការកំណត់បែងចែកថវិកាដែលមានប្រភពពីសារពើពន្ធ និងពីដៃគូអភិវឌ្ឍ ជាបុរេលក្ខខណ្ឌដ៏ចាំបាច់ មុនពេលដែលកម្មវិធីគាំពារសង្គមថ្មីៗ ដែលមានចែងក្នុង **យ.ជ.គ.ស** អាចចាប់ផ្តើមអនុវត្ត។

ការវាយតម្លៃផ្នែកហិរញ្ញប្បទានលើអន្តរាគមន៍គន្លឹះនៃការគាំពារសង្គម ជាសកម្មភាពមួយនៅក្នុងផែនការសកម្មភាពនៃ**យ.ជ.គ.ស** ដែលត្រូវធ្វើឡើងក្នុងគោលបំណងកំណត់រកតម្រូវការធនធានថវិកា និងសហការជាមួយដៃគូអភិវឌ្ឍដើម្បីរៀបចំផែនការហិរញ្ញប្បទានរួមមួយ ដែលរួមបញ្ចូលការប្រមូលផ្តុំថវិការួមគ្នា និងអភិក្រមផ្អែកលើកម្មវិធីរួម (ប្រអប់ទី១)។

**ប្រអប់ទី១. តម្រូវការឲ្យមានការប៉ាន់ប្រមាណលើថវិកាចំណាយសម្រាប់ យ.ជ.គ.ស**

*ការប៉ាន់ប្រមាណលើថវិកាចំណាយសម្រាប់រយៈពេលមធ្យមនិងរយៈពេលវែង ក្នុងការអនុវត្ត **យ.ជ.គ.ស.** នឹងត្រូវរៀបចំឡើងជាការងារអាទិភាពក្នុងអំឡុងឆ្នាំដំបូងនៃការអនុវត្ត (ដោយរួមមានការចំណាយដោយលម្អិតនៃអន្តរាគមន៍ដែលមានស្រាប់និងដែលបានគ្រោងទុក និងការវិភាគពីចន្លោះប្រហោងផ្នែកសារពើពន្ធ)។ រាជរដ្ឋាភិបាលនឹងពិភាក្សាជាមួយដៃគូអភិវឌ្ឍ លើការគ្រប់គ្រងផ្នែកហិរញ្ញវត្ថុ ពិសេសលើការប្រមូលមូលនិធិរួមគ្នា និងដើម្បីបង្កើតឲ្យមានកិច្ចអន្តរាគមន៍សង្គមដែលមានលក្ខណៈជាកម្មវិធីទ្រង់ទ្រាយធំមួយ និងដើម្បីធ្វើឲ្យមានសុខដុមនីយកម្មដល់ការគាំទ្ររបស់ស្ថាប័នផ្តល់ជំនួយសម្រាប់ **យ.ជ.គ.ស.**។*

*ដើម្បីផ្តល់ហិរញ្ញប្បទានសម្រាប់ការសម្របសម្រួលក្នុងការអនុវត្ត**យ.ជ.គ.ស.** (ការកសាងសមត្ថភាព ការធ្វើផែនការ ការពិនិត្យតាមដាន និងការគ្រប់គ្រងព័ត៌មាននិងចំណេះដឹង) រាជរដ្ឋាភិបាលកម្ពុជាដាក់ឲ្យមានការរៀបចំមូលនិធិជាកញ្ចប់រួម ដើម្បីឲ្យមានសុខដុមនីយកម្មលើការគាំទ្រជំនួយការបច្ចេកទេសពីដៃគូអភិវឌ្ឍ។*

***រាជរដ្ឋាភិបាលកម្ពុជា (២០១១)***

ប្រការលំបាកមួយក្នុងការរួមបញ្ចូលគ្រប់ប្រភេទកម្មវិធីទាំងអស់ ដែលមានចែងនៅក្នុង **យ.ជ.គ.ស** ទៅក្នុងវិសាលភាពនៃការវិភាគក្នុងឯកសារនេះ គឺដោយសារភាពខុសៗគ្នានៃភាពងាយរងគ្រោះ និងទិដ្ឋភាពផ្សេងៗគ្នានៃការគាំពារសង្គម ហើយដែលប្រែប្រួលទៅតាមក្រុមជនក្រីក្រ និងជនងាយរងគ្រោះដែលប្រឈមនឹងហានិភ័យខុសៗគ្នា។ ទោះជាយ៉ាងណា ឯកសារនេះបានព្យាយាមបង្ហាញការដាក់បញ្ចូលកម្មវិធីទាំងឡាយ ដែលឆ្លើយតបចំពោះហានិភ័យសំខាន់ៗដែលជាបញ្ហាប្រឈមរបស់ជនក្រីក្រនិងជនងាយរងគ្រោះ និងក្រុមជនគោលដៅសំខាន់ៗនៃភាពងាយគ្រោះ។

ឯកសារនេះនឹងបង្ហាញពីបញ្ជីនៃជម្រើសគោលនយោបាយចំនួន១២ ដែលជ្រើសរើសដោយផ្អែកលើភាពត្រូវគ្នាជាមួយ**យ.ជ.គ.ស** និងដោយមានឆ្លងការពិគ្រោះយោបល់ជាមួយស្ថាប័នពាក់ព័ន្ធនៅកម្ពុជា។ ការប៉ាន់ប្រមាណលើថវិកាចំណាយសម្រាប់ជម្រើសគោលនយោបាយនីមួយៗ ដែលបានលើកឡើងនៅក្នុងឯកសារនេះ នឹងរួមបញ្ចូលសេណារីយ៉ូផ្សេងៗគ្នា ផ្អែកលើ**លានការដោយ**

**មានកម្រិត** **ឬដោយលក្ខណៈសកល**។ ប្រការនេះបានសេចក្តីថា សេណារីយ៉ូនីមួយៗនឹងត្រូវគណនាក្នុងលទ្ធភាពពីរយ៉ាង គឺក្នុងករណីដែលកម្មវិធីគាំពារសង្គមត្រូវគ្របដណ្តប់តែលើក្រុមជនគោលដៅណាមួយ (វិសាលភាពគ្របដណ្តប់លើក្រុមជនគោលដៅ) ឬគ្របដណ្តប់សម្រាប់គ្រប់ប្រជាជនទាំងអស់ (វិសាលភាពគ្របដណ្តប់ជាសកលសម្រាប់ប្រជាជនទាំងអស់)។ ការគណនានេះ ជាការវាយតម្លៃបឋមផ្នែកហិរញ្ញប្បទាន ហើយដែលចូលរួមកសាងជាការ**គាំពារសង្គមមូលដ្ឋាន**សម្រាប់កម្ពុជា[១]។ ការលើកឡើងពីលាភការជាលក្ខណៈសកល សម្រាប់ប្រជាជនទាំងអស់ ទាំងជនក្រីក្រនិងទាំងជនពុំក្រីក្រ ជាជម្រើសគោលនយោបាយមួយដែលបានបង្ហាញនៅក្នុង**យ.ជ.គ.ស** ក្នុងចំណោមជម្រើសគោលនយោបាយផ្សេងៗ សម្រាប់ការសម្រេចឲ្យបាននូវគោលបំណងដែលបានកំនត់ទុក ដែលនោះគឺការពង្រីកវិសាលភាពនៃរបបសន្តិសុខសង្គមនៅកម្ពុជា។

ឯកសារនេះចែកចេញជាប្រាំជំពូករួមមាន ៖

- ជំពូក១ **សេចក្តីផ្តើម**
- ជំពូក២ **លក្ខណៈទូទៅនៃយុទ្ធសាស្ត្រជាតិគាំពារសង្គម** បង្ហាញពីព័ត៌មានមូលដ្ឋាន និងក្របខណ្ឌយុទ្ធសាស្ត្រនៃ**យ.ជ.គ.ស**
- ជំពូក៣ **ជម្រើសគោលនយោបាយសម្រាប់កម្មវិធីគាំពារសង្គម** បង្ហាញពីជម្រើសគោលនយោបាយដែលជ្រើសរើសដោយផ្អែកលើគោលដៅទាំងប្រាំនៃ**យ.ជ.គ.ស**
- ជំពូក៤ **ការវាយតម្លៃផ្នែកហិរញ្ញប្បទានសម្រាប់ជម្រើសគោលនយោបាយ** បង្ហាញពីការវាយតម្លៃបឋមលើហិរញ្ញប្បទានសម្រាប់គោលនយោបាយនីមួយៗ
- ជំពូក៥ **សេចក្តីសន្និដ្ឋាន និងសង្ខេប** បង្ហាញពីការពិភាក្សាលើលទ្ធផល និងសេចក្តីសន្និដ្ឋាន

ឧបសម្ព័ន្ធនៃឯកសារនេះ នឹងបកស្រាយពីក្របខណ្ឌម៉ូដែលសម្រាប់ការគណនា ជាមួយនិងសេចក្តីសង្ខេបនៃការសន្មតសំខាន់ៗដែលប្រើប្រាស់នៅក្នុងការវាយតម្លៃផ្នែកហិរញ្ញប្បទាន។

---

[១] **គំនិតផ្តួចផ្តើមនៃការគាំពារសង្គមមូលដ្ឋានជាលក្ខណៈសកល** ថាការរៀបចំនៃប្រព័ន្ធអង្គការសហប្រជាជាតិនៅឆ្នាំ២០០៩ ក្រោមការដឹកនាំរបស់អង្គការពលកម្មអន្តរជាតិ(ILO) និងអង្គការសុខភាពពិភពលោក (WHO)។ នៅខែមិថុនា ឆ្នាំ២០១២ សន្និសិទពលកម្មអន្តរជាតិ បានធ្វើការអនុម័តលើអនុសាសន៍នៃការគាំពារសង្គមមូលដ្ឋានឆ្នាំ២០១២ (លេខ២០២) ដែលផ្តល់ជាការណែនាំសម្រាប់រដ្ឋជាសមាជិក ក្នុងការរៀបចំបង្កើតនិងអនុវត្តការគាំពារសង្គម មូលដ្ឋាននៅកម្រិថ្នាក់ជាតិ ក្រោមក្របខណ្ឌយុទ្ធសាស្ត្រនៃការពង្រីករបបសន្តិសុខសង្គម។

# ជំពូក២

# លក្ខណៈទូទៅនៃយុទ្ធសាស្ត្រជាតិគាំពារសង្គម

## ២.១ សាវតា

យុទ្ធសាស្ត្រជាតិគាំពារសង្គមសម្រាប់ជនក្រីក្រនិងជនងាយរងគ្រោះ (**យ.ជ.គ.ស**) បានផ្សព្វផ្សាយនៅក្នុងវេទិកាថ្នាក់ជាតិ កាលពីខែធ្នូ ឆ្នាំ២០១១ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់**សម្តេចអគ្គមហាសេនាធិបតីតេជោនាយករដ្ឋមន្ត្រី**។ ឯកសារយុទ្ធសាស្ត្រនេះ បានរៀបចំឡើងតាមរយៈដំណើរការពិគ្រោះយោបល់ជាមួយក្រសួង-ស្ថាប័ន ដៃគូអភិវឌ្ឍ និងសង្គមស៊ីវិល ក្នុងគោលដៅកំណត់រកទិសដៅយុទ្ធសាស្ត្រ ឆ្ពោះទៅកាន់ប្រព័ន្ធគាំពារសង្គមមួយនៅកម្ពុជា ដែលមានលក្ខណៈកាន់តែចំរុះ និងមានការសម្របសម្រួល។ **ក្រុមការងារបណ្តោះអាសន្នសម្រាប់ការគាំពារសង្គម** ត្រូវបានបង្កើតឡើងនៅខែកុម្ភៈ ឆ្នាំ២០០៩ ដោយមានការចូលរួមពីគ្រប់ស្ថាប័នពាក់ព័ន្ធ ដើម្បីរៀបចំធ្វើបញ្ជីសារពើភ័ណ្ឌនៃកម្មវិធីគាំពារសង្គមដែលមានស្រាប់ និងតាក់តែងឯកសារទស្សនាទានសម្រាប់ការរៀបចំបង្កើតយុទ្ធសាស្ត្រ។ ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ (ក.ក.ជ) បានរៀបចំនិងដាក់បង្ហាញសេចក្តីព្រាងនៃ **យ.ជ.គ.ស** ទៅកាន់**វេទិកាសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា** ដែលបានរៀបចំឡើងនៅខែមិថុនា ឆ្នាំ២០១០ ហើយការជម្រុញឲ្យមានការយកចិត្តទុកដាក់លើការប៉ាន់ប្រមាណលើការចំណាយសម្រាប់យុទ្ធសាស្ត្រ ក៏បានពិភាក្សាក្នុងឱកាសនោះ។ ជាចុងក្រោយ រាជរដ្ឋាភិបាលកម្ពុជាបានអនុម័តជាផ្លូវការលើ **យ.ជ.គ.ស** ក្នុងកិច្ចប្រជុំគណៈរដ្ឋមន្ត្រី នាថ្ងៃទី១៨ ខែមិនា ឆ្នាំ២០១១។

ទស្សនៈវិស័យក្នុងដំណាក់កាលវែងរបស់រាជរដ្ឋាភិបាលនៅក្នុង **យ.ជ.គ.ស** គឺការពង្រីកវិសាលភាពនៃការគាំពារសង្គម ដើម្បីធានាការផ្តល់ការគាំពារសង្គមសម្រាប់ប្រជាជនគ្រប់រូប តាមរយៈកញ្ចប់នៃប្រយោជន៍និងលាភការ និងសេវាកម្មបំពេញបន្ថែម។ ទស្សនៈវិស័យនេះបានផ្សារភ្ជាប់នៅក្នុង **យ.ជ.គ.ស** ហើយរួមមានការឧបត្ថម្ភសង្គមដោយមានគោលដៅ ចំពោះជនក្រីក្រ និងជនងាយរងគ្រោះ និងការបង្កើតក្របខណ្ឌគាំពារសង្គមដោយមានភាគទាន។ ប្រការនេះ គឺត្រូវគ្នាជាមួយគំនិតផ្តួចផ្តើមនៃការគាំពារសង្គមមូលដ្ឋាន ដែលរៀបចំដោយប្រព័ន្ធអង្គការសហប្រជាជាតិនៅឆ្នាំ២០០៩ ហើយដឹកនាំដោយអង្គការពលកម្មអន្តរជាតិ និងអង្គការសុខភាពពិភពលោក។

ក្នុងការបង្កើតប្រព័ន្ធគាំពារសង្គមមួយ ដែលកាន់តែមានលក្ខណៈចំរុះនិងជាប្រព័ន្ធ ដើម្បីការកែលម្អជីវភាព និងការអភិវឌ្ឍមូលធនមនុស្ស សម្រាប់ជនក្រីក្រនិងជនងាយរងគ្រោះ **យ.ជ.គ.ស** បានដាក់ចេញអភិក្រមបីយ៉ាងរួមមាន៖

- ការពារជនក្រីក្របំផុត និងងាយរងគ្រោះបំផុត ដែលពុំអាចជួយខ្លួនឯងបាន តាមរយៈការគាំទ្រផ្នែកសេវាកម្មសង្គម និងការឧបត្ថម្ភ
- ការបង្កាផលប៉ះពាល់នៃហានិភ័យ ដែលអាចនាំទៅរកការប្រើប្រាស់យុទ្ធសាស្ត្រសម្របខ្លួនដែលមានលក្ខណៈអវិជ្ជមានដោយជនក្រីក្រ និងដែលនាំទៅរកហាយនភាព (ឧទាហរណ៍ បញ្ហាពលកម្មកុមារ) ដោយការពង្រីកសំណាញ់សុវត្ថិភាពសង្គម (ការពិនិត្យសុខភាពដោយពុំគិតថ្លៃសម្រាប់ជនក្រីក្រ ការបណ្តុះបណ្តាលវិជ្ជាជីវៈ)
- ការបង្កើន និងលើកកម្ពស់លទ្ធភាពដែលជនក្រីក្រ អាចចាកផុតពីភាពក្រីក្រ តាមរយៈការកសាងមូលធនមនុស្ស (ការអប់រំ សុខភាព និងជីវភាពរស់នៅ) និងការពង្រីកនុវត្តភាព (RGC, 2011a)។

ឯកសារ **យ.ជ.គ.ស** បានលើកឡើងពីអន្តរាគមន៍គន្លឹះសម្រាប់គោលដៅទាំងប្រាំនៃយុទ្ធសាស្ត្រ ដោយឆ្លុះបញ្ចាំងពីគោលដៅនៃការអភិវឌ្ឍក្នុងគោលដៅអភិវឌ្ឍន៍សហវត្ស (តារាងទី ២.១)។

## ២.២ សមាសភាពនៃ យ.ជ.គ.ស

ឯកសារ **យ.ជ.គ.ស** បានបង្ហាញពីគោលនយោបាយគាំពារសង្គមសំខាន់ៗដោយចែកជាគោលដៅយុទ្ធសាស្ត្រចំនួនប្រាំ ហើយពាក់ព័ន្ធផ្ទាល់ដល់***គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា***។ គោលដៅយុទ្ធសាស្ត្រទាំងប្រាំនៃ **យ.ជ.គ.ស** រួមមាន៖

- **គោលដៅទី១** ជនក្រីក្រ និងជនងាយរងគ្រោះ ទទួលបានការគាំទ្រ ដែលរួមមានស្បៀង អនាម័យ ទឹក និងជម្រក ។ល។ ដើម្បីបំពេញតាមតម្រូវការរបស់ពួកគាត់ក្នុងពេលវេលាមានគ្រោះអាសន្ន និងវិបត្តិ។
- **គោលដៅទី២** ជនក្រីក្រ កុមារ និងមាតាងាយរងគ្រោះ ទទួលបានផលប្រយោជន៍ពីសំណាញ់សុវត្ថិភាពសង្គមដើម្បីកាត់បន្ថយភាពក្រីក្រ និងអសន្តិសុខស្បៀង និងពង្រឹងការអភិវឌ្ឍមូលធនមនុស្ស តាមរយៈការបង្កើនគុណភាពអាហារូបត្ថម្ភសុខភាពមាតានិងកុមារ ការលើកកម្ពស់ការអប់រំ និងការលុបបំបាត់ពលកម្មកុមារ ជាពិសេសទម្រង់ធ្ងន់ធ្ងរ។

- **គោលដៅទី៣** ជនក្រីក្រនិងងាយរងគ្រោះដែលពេញវ័យធ្វើការងារទទួលប្រយោជន៍ពីកាលានុវត្តភាពការងារ ដើម្បីធានាឲ្យមានប្រាក់ចំណូលស្បៀង និងឲ្យមានការងារធ្វើ ព្រមទាំងចូលរួមក្នុងការកសាងធនធានរូបវន្ត និងធនធានហេដ្ឋារចនាសម្ព័ន្ធសង្គមដែលមាននិរន្តរភាព។
- **គោលដៅទី៤** ជនក្រីក្រ និងជនងាយរងគ្រោះទទួលបានដោយមានប្រសិទ្ធភាពនូវការថែរក្សាសុខភាពដែលមានគុណភាព និងដែលអាចទទួលប្រើបាន និងការគាំពារផ្នែកហិរញ្ញវត្ថុពេលមានជំងឺ។
- **គោលដៅទី៥** ក្រុមជនងាយរងគ្រោះពិសេស រួមមានក្មេងកំព្រា ចាស់ជរា ស្ត្រីជាមេគ្រួសារ ជនពិការ ជនផ្ទុកមេរោគអេដស៍ ឬអ្នកជំងឺរបេង ។ល។ ទទួលបានការគាំទ្រជាប្រាក់ចំណូល សម្ភារៈ និងចិត្តសាស្ត្រសង្គម ព្រមទាំងការថែទាំសង្គមគ្រប់គ្រាន់។

ដើម្បីសម្រេចឲ្យបានគោលដៅទាំងប្រាំនេះ **យ.ជ.គ.ស** ជម្រុញឲ្យមានការពង្រីកបន្ថែមអន្តរាគមន៍ដែលមានស្រាប់ និងអនុវត្តសាកល្បងកម្មវិធីថ្មី ដើម្បីគ្របដណ្តប់លើចន្លោះប្រហោងដែលមានស្រាប់។ តារាង ២.១ ខាងក្រោមបង្ហាញពីបញ្ជីនៃអន្តរាគមន៍ជាអាទិភាព ដែលបានលើកឡើងក្នុងគោលដៅទាំងប្រាំនៃ យ.ជ.គ.ស។

**តារាង២.១ គោលដៅរបស់ យ.ជ.គ.ស. និងការផ្សារភ្ជាប់ជាមួយគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា**[1]

| វិស័យអាទិភាព និងការផ្សារភ្ជាប់នឹង គ.អ.ស.ក. | គោលដៅ | ជម្រើសកម្មវិធី ឬឧបករណ៍សម្រាប់រយៈពេលមធ្យម |
|---|---|---|
| ឆ្លើយតបនូវតម្រូវការជាមូលដ្ឋានរបស់ជនក្រីក្រ និងជនងាយរងគ្រោះ ក្នុងស្ថានភាពរងគ្រោះអាសន្ន និងកលិយុគ<br>(គ.អ.ស.ក. ១, ៩) | *ជនក្រីក្រ និងជនងាយរងគ្រោះ ទទួលបានការគាំទ្រ ដែលរួមមានស្បៀង អនាម័យ ទឹក និងជម្រក ។ល។ ដើម្បីបំពេញតាមតម្រូវការរបស់ពួកគាត់ ក្នុងដំណាក់កាលមានគ្រោះអាសន្ន និងវិបត្តិ* | - ការចែកចាយស្បៀងដោយមានគោលដៅ<br>- ការចែកចាយទុន សម្ភារៈកសិកម្ម និងប្រតិបត្តិការជំនួយក្នុងគ្រោះអាសន្នដទៃទៀត |
| កាត់បន្ថយភាពក្រីក្រ និង | *ជនក្រីក្រ កុមារ និងមាតាងាយរងគ្រោះ* | - ការឧបត្ថម្ភសាច់ប្រាក់ ស្បៀង ឬសម្ភារៈ |

[1] គោលដៅអភិវឌ្ឍន៍សហស្សវត្សកម្ពុជាមាន៩ រួមមាន ការលុបបំបាត់ភាពក្រីក្រនិងភាពអត់ឃ្លាន ការសម្រេចឲ្យបានការអប់រំមូលដ្ឋានសម្រាប់គ្រប់ៗគ្នា បង្កើនសមភាពយេនឌ័រនិងការផ្តល់អំណាចដល់ស្ត្រី ការកាត់បន្ថយមរណភាពកុមារ ការបង្កើនសុខភាពមាតា ការប្រយុទ្ធប្រឆាំងនឹងមេរោគអេដស៍ គ្រុនចាញ់ និងជំងឺផ្សេងៗទៀត ការធានានិរន្តរភាពបរិស្ថាន ការរៀបចំបង្កើតភាពជាដៃគូសកលសម្រាប់ការអភិវឌ្ឍ និងការបោសសំអាតមីន យុទ្ធភណ្ឌមិនទាន់ផ្ទុះ និងការទ្រទ្រង់ដល់ជនរងគ្រោះ។

| | | |
|---|---|---|
| ភាពងាយរងគ្រោះនៃកុមារ និងមាតា និងបង្កើនការអភិវឌ្ឍធនធានមនុស្សសម្រាប់ពួកគាត់ (គ.អ.ស.ក. ១, ២, ៣, ៤, ៥) | *ទទួលបានផលប្រយោជន៍ពីសំណាញ់សុវត្ថិភាពសង្គម ដើម្បីកាត់បន្ថយភាពក្រីក្រនិងអសន្តិសុខស្បៀង និងពង្រឹងការអភិវឌ្ឍមូលធនមនុស្ស តាមរយៈការបង្កើនគុណភាពអាហារូបត្ថម្ភ សុខភាពមាតា និងកុមារ ការលើកកម្ពស់ការអប់រំ និងការលុបបំបាត់ពលកម្មកុមារ ជាពិសេសទម្រង់ធ្ងន់ធ្ងរ* | ដទៃទៀតសម្រាប់កុមារនិងស្ត្រី ដោយកម្មវិធីរួមមួយ (រួមមានការឧបត្ថម្ភសាច់ប្រាក់ដែលផ្តោតលើអាហារូបត្ថម្ភមាតា និងកុមារ ការឧបត្ថម្ភសាច់ប្រាក់ដែលលើកកម្ពស់ការអប់រំ និងកាត់បន្ថយពលកម្មកុមារ ការផ្តល់អាហារមានជីវជាតិបន្ថែមដល់ស្ត្រីមានផ្ទៃពោះ ម្តាយបំបៅដោះកូន និងកុមារ)<br>- ការផ្តល់អាហារនៅសាលារៀន របបស្បៀងយកទៅផ្ទះ<br>- សេវាកម្មផ្សព្វផ្សាយ និង កម្មវិធីឱកាសថ្មីសម្រាប់យុវជននៅក្រៅសាលារៀន និងការគាំទ្រដល់សេវាកម្មសុខុមាលភាពសង្គម |
| ឆ្លើយតបនូវភាពខ្វះការងារ និងភាពគ្មានការងារដែលកើតមានឡើងតាមរដូវកាល និងផ្តល់ឱកាសសម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះ ដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់ពួកគាត់ (គ.អ.ស.ក. ១) | *ជនក្រីក្រ និងជនងាយរងគ្រោះដែលពេញវ័យធ្វើការងារ ទទួលបានផលប្រយោជន៍ពីកាលានុវត្តភាពការងារ ដើម្បីធានាឲ្យមានប្រាក់ចំណូល ស្បៀង និងមានការងារធ្វើ ព្រមទាំងចូលរួមក្នុងការកសាងធនធានរូបវន្ត និងធនធានហេដ្ឋារចនាសម្ព័ន្ធសង្គមប្រកបដោយនិរន្តរភាព* | - កម្មវិធីសំណង់សាធារណៈអតិពលកម្មជាតិ<br>- គម្រោងស្បៀងពលកម្ម និងសាច់ប្រាក់ពលកម្ម |
| បង្កើនការថែទាំសុខភាពដែលអាចទទួលយកបានដល់ជនក្រីក្រ និងជនងាយរងគ្រោះ (គ.អ.ស.ក. ៤, ៥, ៦) | *ជនក្រីក្រ និងជនងាយរងគ្រោះ ទទួលបានដោយមានប្រសិទ្ធភាព នូវការថែរក្សាសុខភាពដែលមានគុណភាព និងដែលអាចទទួលប្រើបាន និងការគាំពារផ្នែកហិរញ្ញវត្ថុពេលមានជំងឺ* | - ការពង្រីកមូលនិធិសមធម៌សុខភាព (សម្រាប់ជនក្រីក្រ) និងការធានារ៉ាប់រងសុខភាពនៅសហគមន៍ (សម្រាប់ប្រជាជនស្ថិតនៅក្បែរបន្ទាត់នៃភាពក្រីក្រ) ដូចមានចែងក្នុងផែនការមេស្តីពីការគាំពារសុខភាពសង្គម (នៅរង់ចាំការអនុម័ត) |
| បង្កើនការគាំពារសង្គមសម្រាប់ជនងាយរងគ្រោះពិសេសមួយចំនួន (គ.អ.ស.ក. ១, ៦, ៩) | *ក្រុមជនងាយរងគ្រោះពិសេស រួមមានក្មេងកំព្រា ចាស់ជរា ស្ត្រីជាមេគ្រួសារ ជនពិការ ជនផ្ទុកមេរោគអេដស៍ ឬអ្នកជំងឺរបេង ។ល។ ទទួលបាន ការគាំទ្រជាប្រាក់ចំណូល សម្ភារៈ និងចិត្តសាស្ត្រសង្គម ព្រមទាំងការថែទាំសង្គមគ្រប់គ្រាន់* | - សេវាកម្មសុខុមាលភាពសង្គមសម្រាប់ក្រុមជនងាយរងគ្រោះពិសេស<br>- ការឧបត្ថម្ភសង្គម និងប្រាក់សោធននិវត្តន៍សង្គមសម្រាប់មនុស្សចាស់ និងអ្នកដែលមានជំងឺរ៉ាំរ៉ៃ ឬជនពិការ |

**ប្រភព:** RGC (2011a)

ការរៀបចំបង្កើតកម្មវិធីថ្មីៗចេញពីគោលដៅយុទ្ធសាស្ត្រទាំងប្រាំខាងលើ នឹងទាមទារឲ្យមានការចូលរួមពីគ្រប់ស្ថាប័នពាក់ព័ន្ធ ពិសេសក្នុងដំណាក់កាលនៃការអនុវត្ត។ ការចូលរួមរបស់ដៃគូអភិវឌ្ឍ ក៏មានសារៈសំខាន់ ពិសេសតាមរយៈការផ្តល់ហិរញ្ញប្បទាននិងជំនួយការបច្ចេកទេសសម្រាប់ការរៀបចំកម្មវិធី និងការពិនិត្យតាមដាននិងវាយតម្លៃ។

# ជំពូក៣
# ជម្រើសគោលនយោបាយសម្រាប់ កម្មវិធីគាំពារសង្គម

ជំពូកនេះនឹងលើកឡើងពីការកំណត់ជម្រើសគោលនយោបាយមួយចំនួន ដើម្បីធ្វើការវាយតម្លៃជាលក្ខណៈបឋមផ្នែកហិរញ្ញប្បទានសម្រាប់អន្តរាគមន៍គាំពារសង្គម ដែលបានកំណត់នៅក្នុង **យ.ជ.គ.ស**។ ជម្រើសគោលនយោបាយនីមួយៗ នឹងឆ្លុះបញ្ចាំងពីរូបភាពនៃការរៀបចំកម្មវិធីដែលនឹងប្រែប្រួលទៅតាមវិសាលភាពនៃការគ្របដណ្តប់លើក្រុមជនគោលដៅ និងកម្រិតនៃលាភការដែលក្រុមជនគោលដៅនឹងទទួលបាន។ ការប៉ាន់ប្រមាណលើថវិកាចំណាយ (ដែលនឹងត្រូវបង្ហាញក្នុងជំពូកក្រោយ) សម្រាប់ជម្រើសគោលនយោបាយនីមួយៗ នឹងផ្តល់ជាសញ្ញាណនៃវិសាលភាពផ្នែកធនធាន ដែលនឹងត្រូវប្រើប្រាស់សម្រាប់ការអនុវត្តកម្មវិធីនីមួយៗ ក្នុងកំឡុងពេលកំណត់មួយ។ ការវិភាគនេះនឹងផ្សារភ្ជាប់ចន្លោះប្រហោងរវាងយុទ្ធសាស្ត្រ និងការអនុវត្តតាមរយៈការគាំទ្រដល់ដំណើរការរៀបចំគោលនយោបាយ។

ដើម្បីកម្រិតព្រំដែននៃវិសាលភាពសម្រាប់ការវិភាគនេះ ការវាយតម្លៃជាបន្តបន្ទាប់ខាងក្រោម នឹងពាក់ព័ន្ធតែជាមួយ**លាភការនៃការគាំពារសង្គម** ដែលត្រូវផ្តល់ជូនដល់ក្រុមជនគោលដៅតែក្នុងរូបភាពជា**ការឧបត្ថម្ភសាច់ប្រាក់**តែប៉ុណ្ណោះ ហើយដែលរួមបញ្ចូលទាំង**របបសោធន** និង**ប្រាក់កម្រៃពលកម្ម** (សម្រាប់កម្មវិធីសំណង់សាធារណៈ)។ ទោះបីជាការវាយតម្លៃលើកម្មវិធីដែលផ្តល់លាភការជាសម្ភារៈ ឬតាមរយៈសេវាកម្មសុខុមាភាព ជាការវិភាគដែលមានសារៈសំខាន់ និងតម្លៃដូចការវិភាគនេះក៏ដោយ ក៏វិសាលភាពនៃការវិភាគក្នុងឯកសារនេះពុំបានគ្របដណ្តប់ដែរ។ ការបកស្រាយក្នុងអត្ថបទខាងក្រោម នឹងបង្ហាញពីការបរិយាយដោយសង្ខេបស្តីពីជម្រើសគោលនយោបាយនីមួយៗ។

### ៣.១ គោលដៅទី១: ការដោះស្រាយបញ្ហាសន្តិសុខស្បៀងនិងជំនួយសង្គ្រោះបន្ទាន់

គោលដៅទី១ នៃ**យ.ជ.គ.ស** គឺពាក់ព័ន្ធទៅនឹងតម្រូវការមូលដ្ឋាននៃជនក្រីក្រ និងជំនួយសង្គមកិច្ចក្នុងដំណាក់កាលអាសន្ន និងកលិយុគ។ **សន្តិសុខស្បៀង** គឺជាបញ្ហាចម្បងបំផុតសម្រាប់ជន

ក្រីក្របំផុត ដោយសារពួកគាត់ជួបប្រទះខ្លាំងទៅនឹងបញ្ហាជីវភាព។ ការធានាសន្តិសុខសម្រាប់ប្រជាជនគ្រប់រូប ពិសេសជនដែលរស់នៅក្រោម**បន្ទាត់នៃភាពក្រីក្រផ្អែកស្បៀងអាហារ** គឺជាប្រការចាំបាច់បំផុត ហើយជាកម្មវិធីមួយដែលមានមូលដ្ឋានជាអាទិភាព។ ក្រៅពីសម្រាប់ជនក្រីក្របំផុត សន្តិសុខស្បៀងក៏ជាបញ្ហាមួយសម្រាប់ជនដែលរស់នៅក្បែរបន្ទាត់នៃភាពក្រីក្រ ហើយដែលងាយរងគ្រោះទៅនឹងគ្រោះអាសន្ននិងកលិយុគ។ ដោយសារភាគច្រើននៃក្រុមប្រជាជនទាំងនេះមានការពឹងផ្អែកខ្លាំងទៅលើវិស័យកសិកម្មខ្នាតតូចដើម្បីជីវភាពរស់នៅ ពួកគាត់មានភាពងាយរងគ្រោះបំផុតទៅនឹងវិបត្តិដែលបណ្តាលមកពីអាកាសធាតុដែលប៉ះពាល់ដល់ការប្រមូលផលកសិកម្ម ពិសេសគឺគ្រោះរាំងស្ងួត និងទឹកជំនន់។ ក្រៅពីគ្រោះធម្មជាតិ ពួកគាត់ក៏ត្រូវប្រឈមមុខនឹងវិបត្តិដទៃទៀត រួមមានកលិយុគសេដ្ឋកិច្ច ពិសេសគឺបម្រែបម្រួលដោយគំហុគនៃថ្លៃសម្ភារៈកសិកម្ម (ពូជដំណាំ និងជី) ជម្ងឺរាតត្បាតលើសត្វពាហណៈ (ឧទាហរណ៍ ការរាតត្បាតនៃគ្រុនផ្តាសាយបក្សី) និងវិបត្តិដទៃទៀតដែលអាចមានផលប៉ះពាល់ដល់ជីវភាព និងការរស់នៅពួកគាត់។

ប្រការលំបាកមួយដើម្បីវាយតម្លៃទុកជាមុនលើ**ប្រតិបត្តិការសង្គ្រោះបន្ទាន់** ក្នុងស្ថានភាពអាសន្ន គឺដោយសារគ្រោះធម្មជាតិនិងកលិយុគសេដ្ឋកិច្ចអាចកើតឡើងដោយពុំទៀងទាត់ ហើយភាពធ្ងន់ធ្ងរនៃវិបត្តិទាំងនេះមានភាពប្រែប្រួល ដែលដូច្នេះទើបបញ្ហានេះត្រូវដោះស្រាយភ្លាមៗនៅពេលកកើតឡើង ទៅតាមកាលៈទេសៈនីមួយៗ។ ដោយយោងទៅលើភាពពុំទៀងទាត់ និងលក្ខណៈបណ្តោះអាសន្នក្នុងស្ថានភាពអាសន្ន ប្រតិបត្តិការសង្គ្រោះបន្ទាន់ពុំមែនជាកម្មវិធីគាំពារសង្គមពិតប្រាកដទេ។ លើសពីនេះទៀត ដោយសារវិបត្តិគ្រោះធម្មជាតិនិងកលិយុគសេដ្ឋកិច្ចអាចមានឥទ្ធិពលយ៉ាងធ្ងន់ធ្ងរទៅលើការផ្គត់ផ្គង់និងថ្លៃស្បៀងនៅលើទីផ្សារ ការឧបត្ថម្ភលាភការជាសម្ភារៈ (ដូចជារបបស្បៀងអាហារ) ជាជម្រើសប្រសើរជាងសាច់ប្រាក់។ ម្យ៉ាងទៀត ដោយសារប្រតិបត្តិការសង្គ្រោះបន្ទាន់ ជាអន្តរាគមន៍ដែលមានលក្ខណៈស៊ាំញ៉ាំដែលពាក់ព័ន្ធស្ថាប័នជាច្រើន ការប៉ាន់ប្រមាណលើថវិកាចំណាយសម្រាប់អន្តរាគមន៍នេះ ត្រូវស្ថិតនៅក្រៅពីវិសាលភាពនៃឯកសារនេះ។

តារាង៣.១ខាងក្រោម បង្ហាញពីការវាយតម្លៃលើអន្តរាគមន៍ដើម្បីធានាសន្តិសុខស្បៀងដល់ជនក្រីក្រ ដោយមានជម្រើសគោលនយោបាយចំនួនពីរ៖

- **ជម្រើសគោលនយោបាយទី១** រួមមានការឧបត្ថម្ភសាច់ប្រាក់ ចំពោះជនក្រីក្របំផុត ហើយផ្តល់ដោយទៀងទាត់ (ឧទាហរណ៍ រៀងរាល់ខែ)។ ក្រុមជនគោលដៅអាចកំណត់តាមរយៈបញ្ជីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ហើយគ្របដណ្តប់តែទៅលើគ្រួសារក្រីក្រកម្រិតទី១ ប៉ុណ្ណោះ។ កម្រិតលាភការសម្រាប់ឆ្នាំ២០១២ គឺ៥៦០០០

រៀល (១៣,៤០ដុល្លារ) ក្នុងមួយខែសម្រាប់មួយគ្រួសារ ដែលត្រូវជា៦០%នៃបន្ទាត់នៃភាពក្រីក្រផ្នែកស្បៀងអាហារ (៩៤០០០រៀល ឬ២២,៥០ដុល្លារ ក្នុងមួយខែ)។

- **ជម្រើសគោលនយោបាយទី២** រួមមានកម្មវិធីឧបត្ថម្ភសាច់ប្រាក់ ដែលមានគោលដៅពុំត្រឹមតែដើម្បីដោះស្រាយបញ្ហាសន្តិសុខស្បៀងនោះទេ តែថែមទាំងដើម្បីជម្រុញក្រុមគោលដៅឲ្យចាកផុតពីភាពក្រីក្រ។ ក្រុមជនគោលដៅអាចជាគ្រួសារទាំងពីរប្រភេទដែលមានកំណត់នៅក្នុងបញ្ជីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ គឺ**គ្រួសារក្រីក្របំផុត (ក្រីក្រកម្រិតទី១ ឬID-Poor1)** និង**គ្រួសារក្រីក្រ (ក្រីក្រកម្រិតទី២ ឬID-Poor2)**។ កម្រិតនៃលាភការសម្រាប់កម្មវិធីនេះ គឺអាចកំណត់ឲ្យស្មើនឹង៨០%នៃ**បន្ទាត់នៃភាពក្រីក្រផ្នែកស្បៀងអាហារនៅតំបន់ជនបទ** គឺស្មើនឹង ៧៥០០០រៀល (១៧,៩០ដុល្លារ) ក្នុងមួយខែសម្រាប់គ្រួសារក្រីក្រកម្រិតទី១ និង៤០%នៃបន្ទាត់ភាពក្រីក្រផ្នែកស្បៀងអាហារនៅជនបទ គឺស្មើនឹង ៣៧៥០០រៀល (៨,៩៥ដុល្លារ) ក្នុងមួយខែសម្រាប់គ្រួសារក្រីក្រកម្រិតទី២ សម្រាប់ឆ្នាំ២០១២។

**តារាង ៣.១ ជម្រើសគោលនយោបាយទី១ និងទី២ : ការធានាសន្តិសុខស្បៀងសម្រាប់ជនក្រីក្រ**

| | ជម្រើសទី១ | ជម្រើសទី២ |
|---|---|---|
| គោលដៅ | ធានាសន្តិសុខស្បៀងសម្រាប់ជនក្រីក្របំផុត | ធានាសន្តិសុខស្បៀង និងតម្រូវការមូលដ្ឋាន សម្រាប់ជនក្រីក្រទាំងអស់ |
| ក្រុមជនគោលដៅ | ជនក្រីក្រកម្រិត១ | ជនក្រីក្រកម្រិត១ និងកម្រិត២ |
| ប្រភេទលាភការ | ការឧបត្ថម្ភសាច់ប្រាក់ | ការឧបត្ថម្ភសាច់ប្រាក់ |
| កម្រិតលាភការ | ៦០%នៃបន្ទាត់នៃភាពក្រីក្រផ្នែកស្បៀងអាហារនៅជនបទ (៥៦,០០០រៀល ឆ្នាំ២០១២) | ៨០%នៃបន្ទាត់នៃភាពក្រីក្រផ្នែកស្បៀងអាហារនៅជនបទ សម្រាប់ជនក្រីក្រកម្រិត១ (៧៥,០០០រៀល ឆ្នាំ២០១២)<br>៤០%នៃបន្ទាត់នៃភាពក្រីក្រផ្នែកស្បៀងអាហារនៅជនបទ សម្រាប់ជនក្រីក្រកម្រិត២ (៣៧,៥០០រៀល ឆ្នាំ២០១២) |
| ដំណាក់កាលនៃការផ្តល់ | រៀងរាល់ខែ | រៀងរាល់ខែ |
| សន្ទស្សន៍កម្ម | សន្ទស្សន៍ថ្លៃទំនិញរបស់អ្នកប្រើប្រាស់ | សន្ទស្សន៍ថ្លៃទំនិញរបស់អ្នកប្រើប្រាស់ |
| រយៈពេល | ពុំកំណត់ | ពុំកំណត់ |
| យន្តការកំណត់អត្តសញ្ញាណ | កម្មវិធីកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ | កម្មវិធីកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ |

## ៣.២ គោលដៅទី២: ការកាត់បន្ថយភាពងាយរងគ្រោះលើកុមារ និងមាតា

កុមារក្រីក្រមានភាពងាយរងគ្រោះខ្ពស់បំផុត ពិសេសក្នុងដំណាក់កាលដំបូងៗនៃជីវិត។ កង្វះអាហារូបត្ថម្ភ ជាបញ្ហាចម្បងបំផុតដែលជះឥទ្ធិពលលើការអភិវឌ្ឍផ្នែកបញ្ញាស្មារតី និងការអប់រំ ហើយដែលរារាំងពួកគេពីការសម្រេចបាននូវសក្តានុពលពេញលេញនៃការអភិវឌ្ឍ នៅដំណាក់កាលបន្តបន្ទាប់នៃជីវិត។ ដោយបញ្ហាកង្វះអាហារូបត្ថម្ភចំពោះកុមារច្រើនកើតឡើង ចាប់តាំងពីដំណាក់កាលដែលពួកគេនៅក្នុងគភ៌ ប្រការសំខាន់បំផុតគឺការកំណត់គោលដៅគ្របដណ្តប់លើការគាំពារមាតា មុនពេលសម្រាលកូន។ ប្រការនេះនឹងអនុញ្ញាតឲ្យគោលនយោបាយគាំពារសង្គម អាចឆ្លើយតបបានទាំងចំពោះបញ្ហាសុខភាពមាតាផង និងទាំងការកាត់បន្ថយអត្រាមរណៈមាតាផង។

ដើម្បីឆ្លើយតបចំពោះគោលដៅនេះ ជម្រើសគោលនយោបាយចំនួនបី អាចលើកឡើង ដើម្បីដោះស្រាយបញ្ហាភាពក្រីក្រ និងភាពងាយរងគ្រោះលើកុមារនិងមាតា។ **ការឧបត្ថម្ភសាច់ប្រាក់**ជាឧបករណ៍គាំពារសង្គម ដែលប្រើប្រាស់សម្រាប់គ្រប់ជម្រើសគោលនយោបាយ។ ការឧបត្ថម្ភជាសម្ភារៈ (ឧទាហរណ៍ ប័ណ្ណសមធម៌សម្រាប់ការពិនិត្យសុខភាពមាតា) និងការដាក់លក្ខខណ្ឌមួយចំនួនដល់អ្នកទទួលផល ដើម្បីជំរុញឲ្យមានការប្រែប្រួលផ្នែកអាកប្បកិរិយា ជាឧបករណ៍ឬវិធីសាស្ត្រគាំពារសង្គមមួយចំនួនដែលអាចដាក់បន្ថែមទៅលើការឧបត្ថម្ភសាច់ប្រាក់។ ប៉ុន្តែវិសាលភាពនៃការវិភាគនៅក្នុងឯកសារនេះ នឹងពុំគ្របដណ្តប់ទៅលើលក្ខណៈនៃការរៀបចំកម្មវិធីគាំពារសង្គមនិងលក្ខខណ្ឌនៅក្នុងកម្មវិធីឡើយ។

- **ជម្រើសគោលនយោបាយទី៣** : រួមមានកម្មវិធីឧបត្ថម្ភសាច់ប្រាក់សម្រាប់ស្ត្រីមានផ្ទៃពោះក្នុងគ្រួសារក្រីក្រកម្រិតទី១ និងទី២។ លាភការសម្រាប់កម្មវិធីនេះ មានកម្រិតស្មើនឹង ៨០% នៃសន្ទស្សន៍ឬបន្ទាត់នៃភាពក្រីក្រផ្នែកស្បៀងអាហារនៅតំបន់ជនបទគឺត្រូវជា ៧៥០០០រៀល (១៧,៩០ដុល្លារ) ក្នុងមួយខែ អាចផ្តល់ជូនសម្រាប់រយៈពេល៦ខែនៃភាពមានគភ៌ គឺស្មើនឹង៤៥០០០០រៀល (១០៧,៥ដុល្លារ)សម្រាប់ស្ត្រីមានផ្ទៃពោះម្នាក់ៗ
- **ជម្រើសគោលនយោបាយទី៤** : រួមមានកម្មវិធីឧបត្ថម្ភសាច់ប្រាក់ដល់កុមារក្រីក្រអាយុក្រោម៣ឆ្នាំ (ID-Poor១និង២) ទាំងអស់។ លាភការសម្រាប់កម្មវិធីនេះមានកម្រិតស្មើនឹង៦០%នៃបន្ទាត់នៃភាពក្រីក្រផ្នែកស្បៀងអាហារនៅតំបន់ជនបទ គឺស្មើនឹង ៥៦០០០រៀល (១៣,៤០ដុល្លារ) ក្នុងមួយខែ ឬស្មើនឹង៦៧២០០០រៀល (១៦១ ដុល្លារ) ក្នុងមួយឆ្នាំ សម្រាប់ឆ្នាំ២០១២ ។ ការកំណត់ជម្រើសនេះ អាចសន្មតថាលាភការអាចផ្តល់ជូនដល់សិស្សបាន តែក្នុងពេលដែលសិស្សមករៀនដោយទៀងទាត់។

- **ជម្រើសគោលនយោបាយទី៥** ៖ រួមមានកម្មវិធីឧបត្ថម្ភសាច់ប្រាក់ដល់កុមារនៅថ្នាក់បឋមសិក្សា ក្នុងអាយុ៦ដល់១១ឆ្នាំ។ លាភការសម្រាប់កម្មវិធីនេះគួរមានកម្រិតស្មើនឹង ៦០%នៃបន្ទាត់នៃភាពក្រីក្រផ្នែកស្បៀងអាហារនៅតំបន់ជនបទ (៥៦០០០រៀល ឬ ១៣,៤០ដុល្លារក្នុងមួយខែ) ដែលត្រូវជា៦៧២០០០រៀល (១៦១ដុល្លារ) ក្នុងមួយឆ្នាំ សម្រាប់ឆ្នាំ២០១២។ ការកំណត់ជម្រើសនេះ អាចសន្មតថាលាភការអាចផ្តល់ជូនដល់សិស្សបានតែក្នុងពេលដែលសិស្សមករៀនដោយទៀងទាត់។

**តារាង ៣.២ ជម្រើសគោលនយោបាយទី៣ ៤ និង៥ ៖ ការឧបត្ថម្ភសាច់ប្រាក់សម្រាប់កុមារ និងមាតាក្រីក្រ**

| | ជម្រើសទី៣ | ជម្រើសទី៤ | ជម្រើសទី៥ |
|---|---|---|---|
| គោលដៅ | ការផ្តល់ប្រាក់ចំណូលសម្រាប់ស្ត្រីក្រីក្រដែលមានផ្ទៃពោះ | របបឧបត្ថម្ភសម្រាប់កុមារក្រីក្រ | របបឧបត្ថម្ភសម្រាប់កុមារក្រីក្រនៅកម្រិតសិក្សាបឋមសិក្សា |
| ក្រុមជនគោលដៅ | ស្ត្រីមានផ្ទៃពោះ (ក្រីក្រកម្រិត១ និង២) | កុមារអាយុ០-២ឆ្នាំ (ក្រីក្រកម្រិត ១ និង២) | កុមារអាយុ៦-១១ឆ្នាំ (ក្រីក្រកម្រិត ១ និង២) ដែលចូលរៀនថ្នាក់បឋមសិក្សា |
| ប្រភេទលាភការ | ការឧបត្ថម្ភសាច់ប្រាក់ | ការឧបត្ថម្ភសាច់ប្រាក់ | ការឧបត្ថម្ភសាច់ប្រាក់ |
| លក្ខខណ្ឌ | នឹងត្រូវពិចារណា | នឹងត្រូវពិចារណា | ការចូលរៀន |
| កម្រិតលាភការ | ៨០%នៃបន្ទាត់នៃភាពក្រីក្រផ្នែកស្បៀងអាហារនៅជនបទ (៧៥,០០០រៀល ក្នុងមួយខែ ឆ្នាំ២០១២) | ៦០%នៃបន្ទាត់នៃភាពក្រីក្រផ្នែកស្បៀងអាហារនៅជនបទ (៥៦,០០០រៀល ក្នុងមួយខែ ឆ្នាំ២០១២) | ៦០%នៃបន្ទាត់នៃភាពក្រីក្រផ្នែកស្បៀងអាហារនៅជនបទ (៥៦,០០០រៀល ក្នុងមួយខែ ឆ្នាំ២០១២) |
| រយៈពេល | ៦ខែ | អាស្រ័យលើការវាយតម្លៃ | អាស្រ័យលើការវាយតម្លៃ និងការចូលរៀន |
| ដំណាក់កាលនៃការផ្តល់ | រាល់ខែ ឬរាល់ពីរខែ | រាល់ខែ ឬរាល់ពីរខែ | រាល់ខែ ឬរាល់ពីរខែ |
| សន្ទស្សន៍កម្ម | សន្ទស្សន៍ថ្លៃទំនិញរបស់អ្នកប្រើប្រាស់ | សន្ទស្សន៍ថ្លៃទំនិញរបស់អ្នកប្រើប្រាស់ | សន្ទស្សន៍ថ្លៃទំនិញរបស់អ្នកប្រើប្រាស់ |
| រយៈពេល | ពុំកំណត់ | អាស្រ័យលើការវាយតម្លៃ | អាស្រ័យលើការវាយតម្លៃ |
| យន្តការកំណត់អត្តសញ្ញាណ | កម្មវិធីកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ | កម្មវិធីកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ | កម្មវិធីកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ |

**កំណត់ចំណាំ:** ការដាក់លក្ខខណ្ឌសម្រាប់កម្មវិធីទាំងនេះរួមមាន ការទៅពិនិត្យផ្ទៃពោះមុនពេលសម្រាល (ជម្រើសគោលនយោបាយទី៣) និងការពិនិត្យសុខភាព ឬចាក់វ៉ាក់សាំងសម្រាប់កុមារ (ជម្រើសគោលនយោបាយទី៤)។ ការប៉ាន់ប្រមាណលើការចំណាយថវិកា (នៅជំពូកក្រោយ) នឹងលើកឡើងពីសក្តានុពលនៃផលប៉ះពាល់របស់ការដាក់លក្ខខណ្ឌ លើកអ្នកទទួលផលឡើយ។ សម្រាប់ជម្រើសគោលនយោបាយទី៥ កម្មវិធីឧបត្ថម្ភសាច់ប្រាក់ត្រូវសន្មតថាគ្រប់កុមារទាំងអស់នឹងត្រូវចូលសាលារៀន។

ជាងនេះទៅទៀត ដើម្បីវាយតម្លៃលើការប៉ាន់ប្រមាណលើការចំណាយថវិកាសម្រាប់កម្រិតលាភការដូចគ្នា តែសម្រាប់ប្រជាជនកម្ពុជាគ្រប់រូប (**វិសាលភាពនៃការគ្របដណ្តប់ជាលក្ខណៈសកល**) ជម្រើសគោលនយោបាយបន្ថែមចំនួនបីទៀត គឺជម្រើសគោលនយោបាយទី៣ស ៤ស និង ៥ស គួរលើកយកមកពិចារណា។

**តារាង ៣.៣ ជម្រើសគោលនយោបាយទី៣ស ៤ស និង៥ស : ការឧបត្ថម្ភសាច់ប្រាក់សម្រាប់មាតា និងកុមារគ្រប់រូបជាលក្ខណៈសកល**

| | **ជម្រើសទី៣** | **ជម្រើសទី៤** | **ជម្រើសទី៥** |
|---|---|---|---|
| គោលដៅ | ការផ្តល់ប្រាក់ចំណូលសម្រាប់ស្ត្រីក្រីក្រដែលមានផ្ទៃពោះ | របបឧបត្ថម្ភសម្រាប់កុមារក្រីក្រ | របបឧបត្ថម្ភសម្រាប់កុមារក្រីក្រនៅកម្រិតសិក្សាបឋមសិក្សា |
| ក្រុមជនគោលដៅ | ស្ត្រីមានផ្ទៃពោះគ្រប់រូប (លាភការជាលក្ខណៈសកល) | កុមារអាយុ០-២ឆ្នាំ គ្រប់រូប (លាភការជាលក្ខណៈសកល) | កុមារអាយុដែលចូលរៀនថ្នាក់បឋមសិក្សាគ្រប់រូប (លាភការជាលក្ខណៈសកល) |
| ប្រភេទលាភការលក្ខខណ្ឌ | ការឧបត្ថម្ភសាច់ប្រាក់ នឹងត្រូវពិចារណា | ការឧបត្ថម្ភសាច់ប្រាក់ នឹងត្រូវពិចារណា | ការឧបត្ថម្ភសាច់ប្រាក់ ការចូលរៀន |
| កម្រិតលាភការ | ៨០%នៃបន្ទាត់នៃភាពក្រីក្រផ្នែកស្បៀងអាហារនៅជនបទ (៧៥,០០០រៀល ក្នុងមួយខែ ឆ្នាំ២០១២) | ៦០%នៃបន្ទាត់នៃភាពក្រីក្រផ្នែកស្បៀងអាហារនៅជនបទ (៥៦,០០០រៀល ក្នុងមួយខែ ឆ្នាំ២០១២) | ៦០%នៃបន្ទាត់នៃភាពក្រីក្រផ្នែកស្បៀងអាហារនៅជនបទ (៥៦,០០០រៀល ក្នុងមួយខែ ឆ្នាំ២០១២) |
| រយៈពេល | ៦ខែ | អាស្រ័យលើការវាយតម្លៃ | អាស្រ័យលើការវាយតម្លៃ និងការចូលរៀន |
| ដំណាក់កាលនៃការផ្តល់ | រាល់ខែ ឬរាល់ពីរខែ | រាល់ខែ ឬរាល់ពីរខែ | រាល់ខែ ឬរាល់ពីរខែ |
| សន្ទស្សន៍កម្ម | សន្ទស្សន៍ថ្លៃទំនិញរបស់អ្នកប្រើប្រាស់ | សន្ទស្សន៍ថ្លៃទំនិញរបស់អ្នកប្រើប្រាស់ | សន្ទស្សន៍ថ្លៃទំនិញរបស់អ្នកប្រើប្រាស់ |
| រយៈពេល | ៦ខែ | អាស្រ័យលើការវាយតម្លៃ | អាស្រ័យលើការវាយតម្លៃ |
| យន្តការកំណត់អត្តសញ្ញាណ | គ្មាន | គ្មាន | គ្មាន |

**កំណត់ចំណាំ:** ការដាក់លក្ខខណ្ឌសម្រាប់កម្មវិធីទាំងនេះរួមមាន ការទៅពិនិត្យផ្ទៃពោះមុនពេលសម្រាល (ជម្រើសគោលនយោបាយទី៣) និងការពិនិត្យសុខភាព ឬចាក់វ៉ាក់សាំងសម្រាប់កុមារ (ជម្រើសគោលនយោបាយទី៤)។ ការប៉ាន់ប្រមាណលើការចំណាយថវិកា (នៅជំពូកក្រោយ) នឹងលើកឡើងពីសក្តានុពលនៃផលប៉ះពាល់របស់ការដាក់លក្ខខណ្ឌ លើកអ្នកទទួលផលឡើយ។ សម្រាប់ជម្រើសគោលនយោបាយទី៥ កម្មវិធីឧបត្ថម្ភសាច់ប្រាក់ត្រូវសន្មតថាគ្រប់កុមារទាំងអស់នឹងត្រូវចូលសាលារៀន។

### ៣.៣ គោលដៅទី៣: ការដោះស្រាយបញ្ហានិក្ខមភាពដែលកើតឡើងខាងក្នុងរដូវកាល

គោលដៅទី៣ នៃ**យ.ជ.គ.ស** ជំរុញឲ្យមានការពង្រីកកម្មវិធីសំណង់សាធារណៈក្នុងគោលដៅបង្កើតកាលានុវត្តភាពការងារសម្រាប់ជនក្រីក្រនៅតំបន់ជនបទ និងចូលរួមកសាងហេដ្ឋារចនាសម្ព័ន្ធជាតិ។ **កម្មវិធីសំណង់សាធារណៈ** ជាប្រភពដ៏សំខាន់សម្រាប់ទ្រទ្រង់ជីវភាពរស់នៅរបស់ជនក្រីក្រពិសេសបន្ទាប់ពីការកើតឡើងនៃគ្រោះមហន្តរាយធម្មជាតិ និងអំឡុងពេលរដូវខ្វះខាត (មុនពេលការប្រមូលផល) ក្នុងវិស័យកសិកម្ម។ ក្នុងរយៈពេលកន្លងមក **កម្មវិធីសាច់ប្រាក់ពលកម្ម** និង**ស្បៀងពលកម្ម** បានអនុវត្តដោយជោគជ័យនៅបណ្តាខេត្តមួយចំនួន ហើយជាកត្តាដែលធ្វើឲ្យ **យ.ជ.គ.ស** បានកំណត់ទុកថាជាកម្មវិធីដែលត្រូវពង្រីកវិសាលភាព តាមរយៈការផ្តោតលើប្រភេទ**ការងារអតិពលកម្ម** ដោយប្រើប្រាស់កម្លាំងពលកម្មមនុស្សច្រើនជាងមូលធននិងគ្រឿងចក្រ ហើយដែលប្រការនេះ នឹងបង្កើនផលប៉ះពាល់វិជ្ជមានផ្នែកសង្គម។

ដើម្បីវាយតម្លៃលើកម្មវិធីសំណង់សាធារណៈ ជម្រើសគោលនយោបាយចំនួនពីរ អាចលើកឡើង:

- **ជម្រើសគោលនយោបាយទី៦** រួមមានការអនុវត្តកម្មវិធីសំណង់សាធារណៈក្នុងកម្រិតថ្នាក់ជាតិ ដោយផ្តោតលើគ្រួសារក្រីក្រកម្រិតទី១ (ID-Poor ១) ដោយកំណត់ថា ក្នុងមួយគ្រួសារ ត្រូវមានមនុស្សម្នាក់អាចចូលរួមក្នុងកម្មវិធី។ ប្រាក់កម្រៃប្រចាំថ្ងៃអាចមានកម្រិត ១០០០០ រៀលក្នុងមួយថ្ងៃ (២,៤០ដុល្លារ) សម្រាប់ឆ្នាំ២០១២ ប៉ុន្តែអាចធ្វើសន្ទស្សន៍កម្មជាមួយកម្រិតប្រាក់កម្រៃថ្នាក់ជាមធ្យម។
- **ជម្រើសគោលនយោបាយទី៧** ផ្តោតទៅលើកម្មវិធីសំណង់សាធារណៈក្នុងកម្រិតថ្នាក់ជាតិសម្រាប់គ្រប់ក្រុមគ្រួសារក្រីក្រទាំងអស់ (កម្រិតទី១និងទី២)។ កម្រិតនៃប្រាក់កម្រៃ គឺស្មើនឹងការលើកឡើងនៅក្នុងជម្រើសគោលនយោបាយទី៦។

ការវិភាគនៅក្នុងឯកសារនេះ សន្មតថារយៈពេលសរុបរបស់កម្មវិធីគឺ៣ខែ ក្នុងមួយឆ្នាំស្មើនឹង៨០ថ្ងៃពលកម្មដោយមានប្រាក់កម្រៃ ហើយក្នុងមួយគ្រួសារ គឺមានតែមនុស្សម្នាក់ប៉ុណ្ណោះដែលត្រូវចូលរួមក្នុងកម្មវិធី។ ចំនុចសំខាន់ដែលគួរឲ្យចាប់អារម្មណ៍ គឺថាក្នុងចំនោមជនក្រីក្រទាំងអស់ អាចមានប្រជាជនមួយចំនួននឹងមានសកម្មភាពការងារផ្សេងដែលទទួលបានលាភការលើសពីកម្មវិធីដែលជាហេតុធ្វើអោយពួកគាត់នឹងមិនមកចូលរួមក្នុងកម្មវិធី។ ដូច្នេះជម្រើសគោលនយោបាយទី៦ និងទី៧ អាចសន្មតថា មានតែក្រុមគ្រួសារគោលដៅតែប៉ុណ្ណោះដែលនឹងចូលរួមក្នុងកម្មវិធី ហើយដែលនេះជាវិសាលភាពនៃកម្មវិធី។

**តារាង៣.៤ ជម្រើសគោលនយោបាយទី៦ និងទី៧: កម្មវិធីសំណង់សាធារណៈ**

| | ជម្រើសទី៦ | ជម្រើសទី៧ |
|---|---|---|
| គោលដៅ | ផ្តល់ការងារ និងធានាសន្តិសុខនៃប្រាក់ចំណូលជាលក្ខណៈរដូវកាលដល់ជនក្រីក្រ | ផ្តល់ការងារ និងធានាសន្តិសុខនៃប្រាក់ចំណូលជាលក្ខណៈរដូវកាលដល់ជនក្រីក្រ |
| ក្រុមជនគោលដៅ | ជនក្រីក្រកម្រិត១ (១នាក់ក្នុង១គ្រួសារ) | ជនក្រីក្រទាំងអស់ (១នាក់ក្នុង១គ្រួសារ) |
| ប្រភេទលាភការ | ប្រាក់ពលកម្ម | ប្រាក់ពលកម្ម |
| កម្រិតប្រាក់កម្រៃ | ១០,០០០រៀលក្នុងមួយថ្ងៃ ឆ្នាំ២០១២ | ១០,០០០រៀលក្នុងមួយថ្ងៃ ឆ្នាំ២០១២ |
| សន្ទស្សន៍កម្ម | សន្ទស្សន៍អតិផរណានៃប្រាក់កម្រៃ (សូមមើលក្នុងផ្នែកឧបសម្ព័ន្ធ) | សន្ទស្សន៍អតិផរណានៃប្រាក់កម្រៃ (សូមមើលក្នុងផ្នែកឧបសម្ព័ន្ធ) |
| រយៈពេល | ៣ខែក្នុង១ឆ្នាំ (៨០ថ្ងៃការងារ) | ៣ខែក្នុង១ឆ្នាំ (៨០ថ្ងៃការងារ) |
| យន្តការកំណត់អត្តសញ្ញាណ | កម្មវិធីកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ | កម្មវិធីកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ |

## ៣.៤ គោលដៅទី៤: ការពង្រីកការគាំពារសុខភាពសង្គម

គោលដៅទី៤នៃ **យ.ជ.គ.ស** គឺការពង្រីកការគាំពារសង្គមសម្រាប់ជនក្រីក្រនិងជនងាយរងគ្រោះ តាមរយៈការពង្រីក**មូលនិធិសមធម៌សុខភាព** និង**គម្រោងធានារ៉ាប់រងសុខភាពនៅសហគមន៍**។ ការធានាឲ្យបាននូវការទទួលបានការថែទាំសុខភាព ដែលអាចទទួលប្រើបានសម្រាប់ប្រជាជនគ្រប់រូប គឺជាគោលដៅដ៏សំខាន់បំផុត ដើម្បីសម្រេចបានគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា។ លើសពីនេះ ការធានាឲ្យបាននូវការទទួលបានការថែទាំសុខភាពសម្រាប់ជនក្រីក្រនិងជនងាយរងគ្រោះ នឹងចូលរួមដល់ការកាត់បន្ថយអត្រាមរណៈកុមារ (**គ.អ.ស.ក**ទី៤) ការបង្កើនសុខភាពមាតា (**គ.អ.ស.ក**ទី៥) និងគាំទ្រដល់ការប្រយុទ្ធប្រឆាំងជំងឺឆ្លង រួមទាំង HIV/AIDS និងគ្រុនចាញ់ (**គ.អ.ស.ក**ទី៦)។

ជម្រើសគោលនយោបាយខាងក្រោមនឹងលើកឡើង ដើម្បីបង្ហាញពីការវាយតម្លៃលើការប៉ាន់ប្រមាណផ្នែកថវិកាចំណាយ ក្នុងការពង្រីកការថែទាំសុខភាពសម្រាប់ជនក្រីក្រៈ

- **ជម្រើសគោលនយោបាយទី៨** គឺជាការពង្រីកវិសាលភាពមូលនិធិសមធម៌សុខាភិបាលដល់ជនក្រីក្រទាំងអស់ (ID-Poor១ និង២) ដោយធានាឲ្យបានថាជនក្រីក្រគ្រប់រូបនឹងទទួលបានសេវាកម្មពិនិត្យនិងព្យាបាលជម្ងឺដោយពុំគិតថ្លៃ នៅតាមសេវាសុខាភិបាលសាធារណៈតាមរយៈលាភការទាំងឡាយនៃមូលនិធិសមធម៌ និងលាភការដទៃទៀត ដែលមានគោលដៅកាត់បន្ថយឧបសគ្គដែលកើតមានដល់ការថែទាំសុខភាព ដូចជាថ្លៃនៃការធ្វើដំណើរមកមណ្ឌលសុខភាព ថ្លៃម្ហូបអាហារសម្រាប់អ្នកជម្ងឺនិងអ្នកកំដរ។

## ៣.៥ គោលដៅទី៥ : ការពង្រីកការគាំពារសម្រាប់ក្រុមជនងាយរងគ្រោះពិសេស

គោលដៅទី៥នៃ **យ.ជ.គ.ស** គឺការពង្រីកការគាំពារសង្គមសម្រាប់ជនងាយរងគ្រោះពិសេស រួមមានកុមារកំព្រា ជនពិការ ចាស់ជរា អ្នកផ្ទុកមេរោគអេដស៍ និងអ្នកជំងឺរ៉ាំរ៉ៃ។ ដោយសារភាគច្រើននៃពួកគាត់ពុំមានលទ្ធភាពធ្វើការបាន ពីព្រោះលក្ខខណ្ឌរូបសាស្ត្រនិងស្ថានភាពសុខភាព ពួកគាត់ពុំអាចចិញ្ចឹមជីវិតបានងាយស្រួល ហើយភាពងាយរងគ្រោះរបស់ពួកគាត់មានទំហំធំ។ ក្រៅពីតម្រូវការឲ្យមានការឧបត្ថម្ភជាប្រាក់ចំណូល ភាគច្រើននៃពួកគាត់ត្រូវការការថែរក្សាពិសេសបន្ថែមទៀត រួមមានការគាំពារសុខភាព ឬការស្តារនីតិសម្បទា ទៅតាមលក្ខខណ្ឌនៃភាពងាយរងគ្រោះ។ លើសពីនេះទៅទៀត ក្រុមជនងាយរងគ្រោះពិសេសមួយចំនួន ត្រូវការសេចក្តីយកចិត្តទុកដាក់មួយចំនួនទៀត រួមមានភាពឯកានៅឆ្ងាយពីសង្គមនិងការរើសអើង ពិសេសដែលកើតមានចំពោះជនពិការ និងអ្នកផ្ទុកមេរោគអេដស៍។ តម្រូវការផ្នែកសុខុមាលភាពសង្គមទាំងនេះទាមទារឲ្យមានការវាយតម្លៃស៊ីជម្រៅបន្ថែមទៀត សម្រាប់ក្រុមជនងាយរងគ្រោះពិសេសខាងលើ។

ការវិភាគក្នុងឯកសារនេះនឹងលើកឡើងពីកម្មវិធី**របបសោធនសង្គម** សម្រាប់ក្រុមជនងាយរងគ្រោះពិសេសពីរក្រុមរួមមាន ជនចាស់ជរា និងជនពិការ ដើម្បីបង្ហាញពីការប៉ាន់ប្រមាណលើថវិកាចំណាយក្នុងរូបភាពជាការឧបត្ថម្ភជាប្រាក់ចំណូលសម្រាប់ជនងាយរងគ្រោះពិសេស។

### ៣.៥.១ ការឧបត្ថម្ភប្រាក់ចំណូលសម្រាប់ជនចាស់ជរា

ជាលក្ខណៈប្រពៃណី ជនចាស់ជរាតែងទទួលបានការឧបត្ថម្ភពីកូនចៅ ឬសាច់ញាតិនៅក្នុងគ្រួសារ។ ដោយសារការធ្លាក់ចុះនៃ**អត្រាបង្កកំណើត**និងទំហំគ្រួសារ កំនើននៃទេសន្តោប្រវេសន៍ និងការប្រែប្រួលនៃចំណងទាក់ទងក្នុងគ្រួសារ លក្ខណៈប្រពៃណីនេះកំពុងទទួលរងភាពប្រែប្រួលក្នុងសង្គមកម្ពុជា ក៏ដូចនៅប្រទេសដទៃទៀតក្នុងពិភពលោក។ លើសពីនេះដោយសារ**អាយុរំពឹងទុក** និង **អត្រាពឹងផ្អែកនៅវ័យជរា**កំពុងកើនឡើងនៅគ្រប់ទីកន្លែង ការរៀបចំបង្កើតរបបសោធននិវត្តសម្រាប់ជនចាស់ជរា ដើម្បីធានាជីវភាពរស់នៅជាកិច្ចការសំខាន់មួយ តែប្រកបដោយបញ្ហាប្រឈម។

ការវិភាគក្នុងឯកសារនេះ នឹងលើកឡើងជាជម្រើសគោលនយោបាយចំនួនបីដើម្បីឆ្លើយតបទៅនឹងការវាយតម្លៃលើការប៉ាន់ប្រមាណផ្នែកថវិកាចំណាយ សម្រាប់កម្មវិធីសោធននិវត្តន៍សង្គមនៅកម្ពុជា។

- **ជម្រើសគោលនយោបាយទី៩** រួមមានរបបសោធននិវត្តន៍សម្រាប់ជនចាស់ជរា ដែលមានអាយុចាប់ពី៧០ឆ្នាំឡើងទៅសម្រាប់គ្រួសារក្រីក្របំផុត (ID-Poor១)។ បរិមាណនៃលាភការ អាចមានកម្រិតស្មើនឹង១០០%នៃបន្ទាត់នៃភាពក្រីក្រផ្នែកស្បៀងអាហារ

នៅតំបន់ជនបទ គឺស្មើនឹង៩៤០០០រៀល (២២,៥០ដុល្លារ) ក្នុងមួយខែ សម្រាប់ឆ្នាំ ២០១២។

- **ជម្រើសគោលនយោបាយទី១០** រួមមានរបបសោធននិវត្តន៍សម្រាប់ជនចាស់ជរា ដែលមានអាយុចាប់ពី៦៥ឆ្នាំឡើងទៅសម្រាប់គ្រប់គ្រួសារក្រីក្រ។ បរិមាណនៃលាភការអាចមានកម្រិតស្មើនឹងការកំណត់ក្នុងជម្រើសគោលនយោបាយទី៩។
- **ជម្រើសគោលនយោបាយទី១១** រួមមានរបបសោធននិវត្តន៍សម្រាប់ជនចាស់ជរាដែលមានអាយុចាប់ពី៦០ឆ្នាំឡើងទៅសម្រាប់គ្រប់គ្រួសារក្រីក្រ។ បរិមាណនៃលាភការអាចមានកម្រិតស្មើនឹងការកំណត់ក្នុងជម្រើសគោលនយោបាយទី៩។

**តារាង ៣.៨ ជម្រើសគោលនយោបាយទី៩ ទី១០ និងទី១១ : របបសោធននិវត្តន៍សម្រាប់ជនចាស់ជរាក្រីក្រ**

| | ជម្រើសទី៩ | ជម្រើសទី១០ | ជម្រើសទី១១ |
|---|---|---|---|
| គោលដៅ | ការផ្តល់របបសោធនសម្រាប់ជនចាស់ជរា | ការផ្តល់របបសោធនសម្រាប់ជនចាស់ជរា | ការផ្តល់របបសោធនសម្រាប់ជនចាស់ជរា |
| ក្រុមជនគោលដៅ | ជនក្រីក្រកម្រិត១ | ជនក្រីក្រកម្រិត១និង២ | ជនក្រីក្រកម្រិត១និង២ |
| លក្ខខណ្ឌអាយុ | ៧០ | ៦៥ | ៦០ |
| ប្រភេទលាភការ | របបសោធននិវត្តន៍ | របបសោធននិវត្តន៍ | របបសោធននិវត្តន៍ |
| កម្រិតលាភការ | ១០០%នៃបន្ទាត់នៃភាពក្រីក្រផ្នែកស្បៀងអាហារនៅជនបទ (៩៤,០០០រៀល ក្នុងមួយខែ ឆ្នាំ២០១២) | ១០០%នៃបន្ទាត់នៃភាពក្រីក្រផ្នែកស្បៀងអាហារនៅជនបទ (៩៤,០០០រៀល ក្នុងមួយខែ ឆ្នាំ២០១២) | ១០០%នៃបន្ទាត់នៃភាពក្រីក្រផ្នែកស្បៀងអាហារនៅជនបទ (៩៤,០០០រៀល ក្នុងមួយខែ ឆ្នាំ២០១២) |
| ដំណាក់កាលនៃការផ្តល់ | រាល់ខែ ឬរាល់ពីរខែ | រាល់ខែ ឬរាល់ពីរខែ | រាល់ខែ ឬរាល់ពីរខែ |
| រយៈពេល | រៀងរាល់ខែ | រៀងរាល់ខែ | រៀងរាល់ខែ |
| សន្ទស្សន៍កម្ម | សន្ទស្សន៍ថ្លៃទំនិញរបស់អ្នកប្រើប្រាស់ | សន្ទស្សន៍ថ្លៃទំនិញរបស់អ្នកប្រើប្រាស់ | សន្ទស្សន៍ថ្លៃទំនិញរបស់អ្នកប្រើប្រាស់ |
| រយៈពេល | រហូតដល់ស្លាប់ | រហូតដល់ស្លាប់ | រហូតដល់ស្លាប់ |
| យន្តការកំណត់អត្តសញ្ញាណ | កម្មវិធីកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ | កម្មវិធីកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ | កម្មវិធីកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ |

ការវិភាគនៅក្នុងឧបសម្ព័ន្ធនៃឯកសារនេះ (ឧបសម្ព័ន្ធទី៣) នឹងបង្ហាញបន្ថែមទៀតពីបែបផែននៃនីតិវិធីក្នុងការកំណត់លាភការសម្រាប់របបសោធននិវត្តន៍ ដែលបានលើកឡើងក្នុងជម្រើសគោលនយោបាយខាងលើ ដោយផ្អែកលើបន្ទាត់នៃភាពក្រីក្រផ្នែកស្បៀងអាហារនៅតំបន់ជនបទ

ហើយការកែសម្រួលគឺអាចធ្វើឡើងជាប្រចាំឆ្នាំ ទៅតាមការវិវត្តនៃ**សន្ទស្សន៍ថ្លៃទំនិញរបស់អ្នកប្រើប្រាស់**[១] (CPI)។

ការវិភាគនៅក្នុងឯកសារនេះ ក៏បានលើកឡើងសម្រាប់ការពិចារណាលើជម្រើសគោលនយោបាយបីបន្ថែមទៀត **គឺជម្រើសគោលនយោបាយ ទី៩ស ទី១០ស និងទី១១ស** ដើម្បីវាយតម្លៃលើការប៉ាន់ប្រមាណផ្នែកថវិកាចំណាយ ក្នុងករណីដែលរបបសោធននិវត្តន៍សម្រាប់ជនចាស់ជរាត្រូវមានវិសាលភាពសម្រាប់ជនចាស់ជរាកម្ពុជាគ្រប់រូប។ ជម្រើសបន្ថែមទាំងបីនេះ ទាក់ទងនឹងជម្រើសគោលនយោបាយទី៩ ទី១០និងទី១១ តាមរយៈការសន្មតលើអាយុចូលនិវត្តន៍ដូចគ្នា។

**តារាង ៣.៦ ជម្រើសគោលនយោបាយទី៩ស ទី១០ស ទី១១ស : របបសោធននិវត្តន៍សម្រាប់ជនចាស់ជរាគ្រប់រូបជាលក្ខណៈសកល**

| | **ជម្រើសទី៩ ស** | **ជម្រើសទី១០ ស** | **ជម្រើសទី១១ ស** |
|---|---|---|---|
| គោលដៅ | ការផ្តល់របបសោធនសម្រាប់ជនចាស់ជរា | ការផ្តល់របបសោធនសម្រាប់ជនចាស់ជរា | ការផ្តល់របបសោធនសម្រាប់ជនចាស់ជរា |
| ក្រុមជនគោលដៅ | ប្រជាជនគ្រប់រូប (លាភការជាលក្ខណៈសកល) | ប្រជាជនគ្រប់រូប (លាភការជាលក្ខណៈសកល) | ប្រជាជនគ្រប់រូប (លាភការជាលក្ខណៈសកល) |
| លក្ខខណ្ឌអាយុ | ៧០ | ៦៥ | ៦០ |
| ប្រភេទលាភការ | របបសោធននិវត្តន៍ (ជាប្រាក់) | របបសោធននិវត្តន៍ (ជាប្រាក់) | របបសោធននិវត្តន៍ (ជាប្រាក់) |
| កម្រិតលាភការ | ១០០%នៃបន្ទាត់នៃភាពក្រីក្រផ្នែកស្បៀងអាហារនៅជនបទ (៩៨,០០០រៀល ក្នុងមួយខែ ឆ្នាំ២០១២) | ១០០%នៃបន្ទាត់នៃភាពក្រីក្រផ្នែកស្បៀងអាហារនៅជនបទ (៩៨,០០០រៀល ក្នុងមួយខែ ឆ្នាំ២០១២) | ១០០%នៃបន្ទាត់នៃភាពក្រីក្រផ្នែកស្បៀងអាហារនៅជនបទ (៩៨,០០០រៀល ក្នុងមួយខែ ឆ្នាំ២០១២) |
| ដំណាក់កាលនៃការផ្តល់ | រាល់ខែ ឬរាល់ពីរខែ | រាល់ខែ ឬរាល់ពីរខែ | រាល់ខែ ឬរាល់ពីរខែ |
| រយៈពេល | រៀងរាល់ខែ | រៀងរាល់ខែ | រៀងរាល់ខែ |
| សន្ទស្សន៍កម្ម | សន្ទស្សន៍ថ្លៃទំនិញរបស់អ្នកប្រើប្រាស់ | សន្ទស្សន៍ថ្លៃទំនិញរបស់អ្នកប្រើប្រាស់ | សន្ទស្សន៍ថ្លៃទំនិញរបស់អ្នកប្រើប្រាស់ |
| រយៈពេល | រហូតដល់ស្លាប់ | រហូតដល់ស្លាប់ | រហូតដល់ស្លាប់ |
| យន្តការកំណត់អត្តសញ្ញាណ | គ្មាន | គ្មាន | គ្មាន |

[១]សន្ទស្សន៍ថ្លៃទំនិញរបស់អ្នកប្រើប្រាស់ (CPI) គឺជារង្វាស់នៃភាពប្រែប្រួលនៃថ្លៃរបស់ទំនិញ និងសេវាកម្ម ដែលគ្រួសារមួយទិញ។

### ៣.៥.២ ការឧបត្ថម្ភប្រាក់ចំណូលសម្រាប់ជនពិការ

ពិការភាពគឺជាបញ្ហាចម្បងមួយសម្រាប់ប្រទេសកម្ពុជា។ យោងតាមតួលេខនៃ**ការជំរឿនប្រជាសាស្ត្រ**លើកចុងក្រោយ ចំនួនសរុបនៃជនពិការអចិន្ត្រៃយ៍គឺមាន១៩២៥៣៨នាក់ ត្រូវជា១,៤% នៃប្រជាជនសរុប។ ពិការភាពធ្វើអោយបាត់បង់លទ្ធភាពធ្វើការងារ ដូច្នេះជនពិការនឹងពុំមានភាពងាយស្រួលក្នុងការប្រកបរបរចិញ្ចឹមជីវភាពឡើយ ហើយត្រូវមានការពឹងផ្អែកខ្ពស់ចំពោះការឧបត្ថម្ភពីគ្រួសារនិងសហគមន៍។ ដោយជនពិការជាក្រុមជនងាយរងគ្រោះពិសេសមួយ ឯកសារនេះនឹងលើកឡើងជាជម្រើសគោលនយោបាយ ក្នុងការដាក់បញ្ចូល**របបសោធនសម្រាប់ជនពិការ** ទៅក្នុងប្រព័ន្ធគាំពារសង្គម។ ការវិភាគក្នុងឯកសារនេះនឹងលើកឡើងជាជម្រើសគោលនយោបាយចំនួនពីរ ដើម្បីវាយតម្លៃលើការប៉ាន់ប្រមាណផ្នែកថវិកាចំណាយរបស់របបសោធនសម្រាប់ជនពិការ។

- **ជម្រើសគោលនយោបាយទី១២** រួមមានការផ្តល់របបសោធនសម្រាប់ជនពិការក្រីក្រទាំងអស់ (ID-Poor១និង២) ហើយកម្រិតនៃលាភការគឺស្មើនឹង ១០០% នៃបន្ទាត់នៃភាពក្រីក្រផ្នែកស្បៀងអាហារនៅតំបន់ជនបទ គឺស្មើនឹង៩៤០០០រៀលក្នុងមួយខែ (២២,៥ដុល្លារ) សម្រាប់ឆ្នាំ២០១២។ ឯកសារនេះសន្មតថា កម្រិតនៃលាភការត្រូវកែសម្រួលជាប្រចាំឆ្នាំឲ្យស្របទៅតាមសន្ទស្សន៍ថ្លៃទំនិញរបស់អ្នកប្រើប្រាស់។
- **ជម្រើសគោលនយោបាយទី១២ស** គឺការផ្តល់របបសោធននិវត្តន៍សម្រាប់ជនពិការកម្ពុជាទាំងអស់ ដែលបាត់បង់សមត្ថភាពធ្វើការងារជាអចិន្ត្រៃយ៍។

**តារាង ៣.៧ ជម្រើសគោលនយោបាយទី១២ និងទី១២ស : របបសោធនសម្រាប់ជនពិការ**

| | ជម្រើសទី១២ | ជម្រើសទី១២ ស |
|---|---|---|
| គោលដៅ | របបសោធនសម្រាប់ជនពិការក្រីក្រ | របបសោធនសម្រាប់ជនពិការទាំងអស់ |
| ក្រុមជនគោលដៅ | ជនពិការក្រីក្រកម្រិត១ និង២ | ជនពិការទាំងអស់ |
| លក្ខខណ្ឌវាយតម្លៃ | ការបាត់បង់សមត្ថភាពពលកម្មអចិន្ត្រៃយ៍ | ការបាត់បង់សមត្ថភាពពលកម្មអចិន្ត្រៃយ៍ |
| ប្រភេទលាភការ | របបសោធន | របបសោធន |
| កម្រិតប្រាក់កម្រៃ | ១០០%នៃបន្ទាត់នៃភាពក្រីក្រផ្នែកស្បៀងអាហារនៅជនបទ (៩៤០០០រៀល ក្នុងមួយខែឆ្នាំ២០១២) | ១០០%នៃបន្ទាត់នៃភាពក្រីក្រផ្នែកស្បៀងអាហារនៅជនបទ (៩៤០០០រៀល ក្នុងមួយខែឆ្នាំ២០១២) |
| ដំណាក់កាលនៃការផ្តល់ | រៀងរាល់ខែ | រៀងរាល់ខែ |
| សន្ទស្សន៍កម្ម | សន្ទស្សន៍អតិផរណានៃប្រាក់កម្រៃ (សូមមើលក្នុងផ្នែកឧបសម្ព័ន្ធ) | សន្ទស្សន៍អតិផរណានៃប្រាក់កម្រៃ (សូមមើលក្នុងផ្នែកឧបសម្ព័ន្ធ) |
| រយៈពេល | ៣ខែក្នុង១ឆ្នាំ (៨០ថ្ងៃការងារ) | ៣ខែក្នុង១ឆ្នាំ (៨០ថ្ងៃការងារ) |
| យន្តការកំណត់អត្តសញ្ញាណ | កម្មវិធីកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ និងការវាយតម្លៃលើពិការភាព | ការវាយតម្លៃលើពិការភាព |

កម្មវិធីរបបសោធននិវត្តន៍សម្រាប់ជនពិការ ទាមទារឲ្យមានការកំណត់និយមន័យស្តីពីពិការភាព ឬ**ការបាត់បង់សមត្ថភាពធ្វើការងារជាអចិន្ត្រៃយ៍** ឲ្យបានច្បាស់លាស់ ព្រមទាំងគោលការណ៍ណែនាំក្នុងការវាយតម្លៃឲ្យបានសមស្រប។ អាស្រ័យទៅលើនិយមន័យស្តីពីពិការភាពដែលនឹងត្រូវកំណត់ ការវាយតម្លៃជាប្រចាំជាប្រការចាំបាច់ពិសេសក្នុងករណីដែលជនគោលដៅ អាចទទួលបានការ**ស្តារលទ្ធភាពពលកម្ម**បានទាំងស្រុង ឬមួយផ្នែក។ ជាងនេះទៅទៀតដោយសារករណីនៃពិការភាពពុំអចិន្ត្រៃយ៍អាចកើតមានជាប្រចាំ ការពិចារណាឲ្យមានការកំណត់កម្រិត ឬកាត់បន្ថយលាភការ ទៅតាមករណីនីមួយៗ ជាប្រការចាំបាច់។

## ៣.៦ សេចក្តីសង្ខេបស្តីពីជម្រើសគោលនយោបាយ

តារាង ៣.៨ បង្ហាញដោយសង្ខេបពីជម្រើសគោលនយោបាយទាំងអស់ ដែលបានលើកឡើង។

**តារាង ៣.៨ សេចក្តីសង្ខេបស្តីពីជម្រើសគោលនយោបាយ**

| ជម្រើសគោលនយោបាយ | គោលដៅ យ.ជ.គ.ស | កម្មវិធី | ក្រុមជនគោលដៅ |
|---|---|---|---|
| ១ | ១ | ឧបត្ថម្ភសាច់ប្រាក់សម្រាប់ជនក្រីក្រ | ជនក្រីក្រកម្រិត១ |
| ២ | ១ | ឧបត្ថម្ភសាច់ប្រាក់សម្រាប់ជនក្រីក្រ | ជនក្រីក្រកម្រិត១និង២ |
| ៣/៣ ស | ២ | ឧបត្ថម្ភសាច់ប្រាក់សម្រាប់ស្ត្រីមានផ្ទៃពោះ | ជនក្រីក្រកម្រិត១និង២/សកល |
| ៤/៤ ស | ២ | ឧបត្ថម្ភសាច់ប្រាក់សម្រាប់កុមារអាយុ០ដល់២ឆ្នាំ | ជនក្រីក្រកម្រិត១និង២/សកល |
| ៥/៥ ស | ២ | ឧបត្ថម្ភសាច់ប្រាក់សម្រាប់កុមារថ្នាក់បឋមសិក្សា | ជនក្រីក្រកម្រិត១និង២/សកល |
| ៦ | ៣ | កម្មវិធីសំណង់សាធារណៈជាតិ | ជនក្រីក្រកម្រិត១ |
| ៧ | ៣ | កម្មវិធីសំណង់សាធារណៈជាតិ | ជនក្រីក្រកម្រិត១និង២ |
| ៨ | ៤ | ការពង្រីកវិសាលភាពមូលនិធិសមធម៌សុខភាព | ជនក្រីក្រកម្រិត១និង២ |
| ៩/៩ ស | ៥ | របបសោធននិវត្តន៍ជនចាស់ជរាអាយុលើសពី៧០ឆ្នាំ | ជនក្រីក្រកម្រិត១/សកល |
| ១០/១០ ស | ៥ | របបសោធននិវត្តន៍ជនចាស់ជរាអាយុលើសពី៦៥ឆ្នាំ | ជនក្រីក្រកម្រិត១និង២/សកល |
| ១១/១១ ស | ៥ | របបសោធននិវត្តន៍ជនចាស់ជរាអាយុលើសពី៦០ឆ្នាំ | ជនក្រីក្រកម្រិត១និង២/សកល |
| ១២/១២ ស | ៥ | របបសោធនសម្រាប់ជនពិការ | ជនក្រីក្រកម្រិត១និង២/សកល |

# ជំពូក៤

# ការវាយតម្លៃផ្នែកហិរញ្ញប្បទានសម្រាប់ជម្រើសគោលនយោបាយ

ជំពូកនេះនឹងបង្ហាញពីការវាយតម្លៃផ្នែកហិរញ្ញប្បទាន ទៅលើជម្រើសគោលនយោបាយនីមួយៗដែលបានលើកឡើងនៅក្នុងជំពូកមុន។ ការប៉ាន់ប្រមាណលើការចំណាយនីមួយៗគឺផ្អែកលើស្ថានភាពសេដ្ឋកិច្ចនៅឆ្នាំ២០១២។ ការធ្វើនិទស្សន៍លើផ្នែកហិរញ្ញប្បទាន សម្រាប់អំឡុងឆ្នាំ ២០១៣-២០២០ គឺធ្វើឡើងដើម្បីបង្ហាញពី ថវិកាដែលត្រូវចំណាយសម្រាប់កម្មវិធីនីមួយៗ គិតជាសាច់ប្រាក់ និងភាគរយនៃ**ផលទុនក្នុង ស្រុក សរុប** (GDP)។

ការប៉ាន់ប្រមាណលើថវិកាចំណាយសម្រាប់ការគាំពារសង្គមនៅក្នុងជំពូកនេះ គឺជាការវិភាគបឋមប៉ុណ្ណោះ ហើយការវិភាគនេះត្រូវបន្តធ្វើឲ្យមានលក្ខណៈលម្អិតបន្ថែមទៀត ទៅតាមការអនុវត្តកម្មវិធីជាក់ស្តែង ឲ្យសមស្របទៅតាមលក្ខណៈនៃការរៀបចំកម្មវិធី និងបញ្ហានៅពេលអនុវត្ត។ ជាការសន្មតក្នុងឯកសារនេះ ការផ្តល់លាភការគឺត្រូវចាប់ផ្តើមនៅថ្ងៃទី១ ខែមករា ឆ្នាំ២០១២ ហើយវិសាលភាពនៃការផ្តល់លាភការ គឺត្រូវគ្របដណ្តប់ភ្លាមៗនៅពេលចាប់ផ្តើមកម្មវិធីទាំងអស់[១]។ ដូច្នេះ ការវិភាគនេះ ត្រូវចាត់ទុកថាជាលក្ខណៈទស្សនាទាន ដែលមានគោលដៅបង្ហាញការប្រៀបធៀបភាពខុសគ្នានៃការប៉ាន់ប្រមាណលើការចំណាយថវិកា រវាងជម្រើសគោលនយោបាយផ្សេងៗគ្នា និងការនិទស្សន៍សម្រាប់ដំណាក់កាលបន្តបន្ទាប់។

ការសន្មតទាក់ទងនឹង "**អត្រាខូបត្តិហេតុនៃនាពក្រីក្រ**" និងនិន្នាការអនាគតគឺបានធ្វើឡើងដោយផ្អែកមូលដ្ឋានលើទិន្នន័យផ្លូវការ ដែលមាននៅក្នុងឯកសារ**ការត្រួតពិនិត្យពាក់កណ្តាលអណត្តិលើផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ** (RGC, 2011b) រួមទាំង**អត្រានៃនាពក្រីក្ររាប់តាមចំនួនមនុស្ស** នៅឆ្នាំ

---

[១] ការសន្មតថាវិសាលភាពនៃការផ្តល់លាភការនឹងត្រូវគ្របដណ្តប់លើអ្នកទទួលផលភ្លាមៗនៅពេលចាប់ផ្តើមកម្មវិធី គឺមានលក្ខណៈរហ័សពេកទាក់ទងនឹងការអនុវត្តកម្មវិធី (ព្រោះការអនុវត្តកម្មវិធីនីមួយៗនឹងចាប់ផ្តើមដំបូងដោយមានលក្ខណៈជាជំហានៗ) ដោយសារប្រការនេះនឹងពឹងផ្អែកទៅលើបែបផែននៃការរៀបចំកម្មវិធី និងនីតិវិធីនៃការអនុវត្តសម្រាប់កម្មវិធីនីមួយៗ។ ដូច្នេះ ការនិទស្សន៍ដែលមាននៅក្នុងឯកសារនេះ ត្រូវចាត់ទុកថាជាការនិទស្សន៍ដែលមានលក្ខណៈ "**អភិរក្សនិយម**" ឬ "**ទុទិដ្ឋិនិយម**"

២០០៧ និងនិន្នាការនៃការធ្លាក់ចុះនៃភាពក្រីក្រដែលនិទស្សន៍សម្រាប់ឆ្នាំជាបន្តបន្ទាប់ (២០០៨-២០២០)។ អត្រាភាពក្រីក្រសរុប សម្រាប់ឆ្នាំ២០២០គឺសន្មតថានៅត្រឹមកម្រិត ២៦,១% ដែលថយចុះក្នុងកម្រិត១,៣%ក្នុងមួយឆ្នាំ ក្នុងអំឡុងឆ្នាំ២០១១-២០២០ (ចំនុចទី៤ ក្នុងឧបសម្ព័ន្ធ)។ដូច្នេះ ផលប៉ះពាល់ដែលទទួលបានពីកម្មវិធីគាំពារសង្គម (ដែលនឹងត្រូវរៀបចំឡើង) ទៅលើអត្រាឧប្បត្តិហេតុនៃភាពក្រីក្រ នឹងពុំរាប់បញ្ចូលទេ[២]។

ការវិភាគនៅក្នុងឯកសារនេះ ក៏ដាក់ការសន្មតថាអត្រាឧប្បត្តិហេតុនៃភាពក្រីក្រ ដែលដកស្រង់ចេញពីទិន្នន័យស្ថិតិសាស្ត្រជាតិ (ពិសេសគឺ**ការអង្កេតសង្គម-សេដ្ឋកិច្ចកម្ពុជា**) ត្រូវឆ្លុះបញ្ចាំងចំពោះក្រុមជនគោលដៅនីមួយៗ ដែលបានកំណត់រួចក្នុង**កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ**។ ប្រការដែលគួរកត់សម្គាល់ គឺកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រជាការវាយតម្លៃស៊ីជម្រៅនៅកម្រិតគ្រួសារ ហើយរៀបចំឡើងនៅថ្នាក់ភូមិ ចំណែកឯទិន្នន័យនៃការអង្កេតសង្គមសេដ្ឋកិច្ចកម្ពុជា ជាការរៀបចំអង្កេតកម្រិតថ្នាក់ជាតិ ដោយប្រើប្រាស់តំណាងគ្រួសារពីទូទាំងប្រទេស។

កម្រិតនៃលាភការនៅក្នុងកម្មវិធីភាគច្រើន គឺផ្អែកលើ**បន្ទាត់នៃភាពក្រីក្រផ្នែកស្បៀងអាហារនៅតំបន់ជនបទ** ដែលធ្វើនិទស្សន៍សម្រាប់អំឡុងឆ្នាំ២០១០-២០២០ ពីតួរលេខឆ្នាំ២០០៩ដែលវិភាគដោយធនាគារពិភពលោក។ កម្រិតនៃលាភការនេះ នឹងធ្វើសន្ទស្សន៍កម្មជាមួយ**សន្ទស្សន៍ថ្លៃទំនិញរបស់អ្នកប្រើប្រាស់** ហើយកែសម្រួលជាប្រចាំឆ្នាំ ដើម្បីឆ្លើយតបចំពោះការបាត់បង់អំណាចនៃការបញ្ជាទិញដោយសារអតិផរណានៃថ្លៃទំនិញ[៣]។ បន្ទាត់នៃភាពក្រីក្រផ្នែកស្បៀងអាហារនៅតំបន់ជនបទសម្រាប់ឆ្នាំ២០១២ គឺស្មើនឹង៩៤០០០រៀល (២២,៥ដុល្លារ) ក្នុងមួយខែ។

---

[២] ដូច្នេះឯកសារនេះសន្មតថា ភាពជាក់លាក់នៃនិន្នាការនៃការធ្លាក់ចុះរបស់អត្រាឧប្បត្តិហេតុនៃភាពក្រីក្រ គឺជាលទ្ធផលនៃការអភិវឌ្ឍសេដ្ឋកិច្ច ហើយពុំមែនជាលទ្ធផលដោយផ្ទាល់នៃកម្មវិធីគាំពារសង្គមដែលផ្តល់ជូនប្រជាជននោះទេ។ ជាប្រការសំខាន់ដែលត្រូវកត់សម្គាល់ ការវិវត្តនៃអត្រាឧប្បត្តិហេតុនៃភាពក្រីក្រ គឺជាកត្តាសំខាន់បំផុតនៃការធ្វើនិទស្សន៍លើការប៉ាន់ប្រមាណនៃការចំណាយថវិកាដែលបង្ហាញនៅក្នុងឯកសារនេះ។

[៣] ការធ្វើសន្ទស្សន៍ថ្លៃទំនិញរបស់អ្នកប្រើប្រាស់ គឺជាជម្រើសសំខាន់បំផុតសម្រាប់ការនិទស្សន៍លើបន្ទាត់នៃភាពក្រីក្រផ្នែកស្បៀងអាហារ ទោះបីជាការវិវត្តនៃថ្លៃស្បៀងអាហារអាចខុសគ្នាពីថ្លៃទំនិញសរុបរបស់អ្នកប្រើប្រាស់ក៏ដោយ ដែលជាលទ្ធផលនៃវិបត្តិកលិយុគ សេដ្ឋកិច្ច ឬអាកាសធាតុ។ លើសពីនេះទៀត ការធ្វើសន្ទស្សន៍កម្មទៅលើសន្ទស្សន៍ថ្លៃទំនិញរបស់អ្នកប្រើប្រាស់សម្រាប់ការកំនត់កម្រិតលាភការ ពុំរារាំងការរីកធំនៃគម្លាតប្រាក់ចំណូលរបស់ប្រជាជនឡើង ហើយដូច្នេះពុំអាចចាត់ទុកថាមានភាពគ្រប់គ្រាន់ ឬមាននិរន្តរភាពជាលក្ខណៈនយោបាយ ក្នុងអំឡុងពេលយូរឡើយ។

[៤] ការប៉ាន់ប្រមាណលើថវិកាចំណាយរដ្ឋបាល តែងមានកម្រិតខ្ពស់សម្រាប់កម្មវិធីដែលតម្រូវឲ្យមានការកំណត់ក្រុមគោលដៅ ដោយសារថវិកាដែលត្រូវចំណាយលើការកំណត់អត្តសញ្ញាណនៃអ្នកទទួលផល។ ដោយសារកម្មវិធីកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ មានវត្តមាននៅកម្ពុជារួចហើយ ការចំណាយរដ្ឋបាលនៅក្នុងគ្រប់ជម្រើសគោលនយោបាយដែលត្រូវមានវិសាលភាពលើក្រុមគោលដៅជាក់លាក់ ត្រូវសន្មតថាមានទំហំស្មើនឹងកម្មវិធីក្នុងជម្រើសគោលនយោបាយដែលមានវិសាលភាពសម្រាប់ប្រជាជនគ្រប់រូប។

ការប៉ាន់ប្រមាណលើថវិកាចំណាយសម្រាប់ផ្នែកការងាររដ្ឋបាល អាចសន្មតថាមានទំហំស្មើនឹង១០% នៃការចំណាយលើលាភការ[៥]។ ទំហំនៃការចំណាយរដ្ឋបាលសម្រាប់កម្មវិធី និងការផ្តល់លាភការឲ្យទៅដល់អ្នកទទួលផល ត្រូវពាក់ព័ន្ធទៅនឹងទំនួលខុសត្រូវជាលក្ខណៈស្ថាប័ន ក៏ដូចជាយន្តការផ្តល់លាភការដែលនឹងត្រូវកំណត់សម្រាប់កម្មវិធីនីមួយៗ។ ការចំណាយថវិកាសម្រាប់ការកំណត់អត្តសញ្ញាណអ្នកទទួលផល ត្រូវសន្មតថាមានរួចរាល់ក្នុងកម្មវិធីផ្សេងមួយទៀត ដូច្នេះការចំណាយថវិកាលើការងារនេះ នឹងពុំដាក់បង្ហាញក្នុងឯកសារនេះទេ។ ម៉្យាងទៀត ដោយសារយន្តការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រនេះត្រូវប្រើប្រាស់សម្រាប់កម្មវិធីច្រើនព្រមៗគ្នា ការចំណាយថវិកាលើការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ ពុំត្រូវផ្តោតបន្ទុកតែទៅលើកម្មវិធីគាំពារសង្គមតែមួយទេ។

## ៤.១ គោលដៅទី១ ការដោះស្រាយបញ្ហាសន្តិសុខស្បៀងនិងជំនួយសង្គ្រោះបន្ទាន់

តារាង៤.១ខាងក្រោម នឹងបង្ហាញពីនិទស្សន៍លើការប៉ាន់ប្រមាណលើការចំណាយថវិកាសម្រាប់ជម្រើសគោលនយោបាយទី១ និងទី២ (ការឧបត្ថម្ភសាច់ប្រាក់សម្រាប់ជនក្រីក្រ)។ នៅឆ្នាំ ២០១២ អ្នកក្រីក្រសរុបមានចំនួនប្រហែល៣,៥៤លាននាក់ដែលក្នុងនោះរួមមាន ជនក្រីក្របំផុតកម្រិត១ (ID-Poor 1) ១,៩៤ លាននាក់ និងក្រីក្រកម្រិត២ (ID-Poor 2) ១,៥១ លាននាក់។ ទំហំនៃលាភការសម្រាប់ជម្រើសគោលនយោបាយទី១ គឺសន្មតត្រឹម៦០%នៃបន្ទាត់នៃភាពក្រីក្រផ្នែកស្បៀងអាហារនៅតំបន់ជនបទ ឬស្មើនឹង៥៦០០០រៀល (១៣,៤០ដុល្លារ) ក្នុងមួយខែ ដែលត្រូវជា ៦៧២០០០រៀល (១៦១ដុល្លារ) ក្នុងមួយឆ្នាំ សម្រាប់អ្នកទទួលផលម្នាក់។ គិតរួមទាំងចំណាយរដ្ឋបាល ថវិកាចំណាយសរុបសម្រាប់ឆ្នាំ២០១២គឺស្មើនឹង១,៤៤កោដិរៀល (៣៤៣លានដុល្លារ) ដែលស្មើនឹង២,៥%នៃផលទុនក្នុងស្រុកសរុប។ យោងតាមការធ្វើនិទស្សន៍លើការធ្លាក់ចុះនៃភាពក្រីក្រ និងកំណើនដោយមាននិរន្តភាពនៃផលទុនក្នុងស្រុកសរុប ថវិកាចំណាយសម្រាប់កម្មវិធីអាចនឹងត្រូវថយចុះមកត្រឹម០,៧%នៃផលទុនក្នុងស្រុកសរុបនៅឆ្នាំ២០២០។ ទោះបីជាថវិកាចំណាយនេះមានទំហំធំយ៉ាងណាក្តី ក៏ការលុបបំបាត់ភាពក្រីក្របំផុតតាមរយៈ ការឧបត្ថម្ភសាច់ប្រាក់អាចជាលទ្ធភាពប្រត្យក្សមួយ ដែលអាចធ្វើទៅបាននៅមុនបំណាច់ទសវត្សរ៍នេះ។

សម្រាប់ជម្រើសគោលនយោបាយទី២ ទំហំលាភការគឺសន្មតត្រឹម៨០%នៃបន្ទាត់ភាពក្រីក្រផ្នែកស្បៀងអាហារនៅតំបន់ជនបទ ឬស្មើនឹង៧៥០០០រៀល (១៨ដុល្លារ) ក្នុងមួយខែ សម្រាប់ជនក្រីក្របំផុត និងត្រឹម៤០%នៃបន្ទាត់នៃភាពក្រីក្រផ្នែកស្បៀងអាហារនៅតំបន់ជនបទ ឬស្មើនឹង ៣៧៥០០រៀល (៩ដុល្លារ) ក្នុងមួយខែ សម្រាប់ជនក្រីក្រកម្រិត២។ គិតរួមទាំងចំណាយរដ្ឋបាល ថវិកាចំណាយសរុបសម្រាប់ឆ្នាំ២០១២ គឺស្មើនឹង២,៦៧កោដិរៀល (៦៣៨លានដុល្លារ) ដែលស្មើនឹង៤,៧%នៃផលទុនក្នុងស្រុកសរុប។ ថវិកាចំណាយសម្រាប់កម្មវិធីអាចនឹងត្រូវថយចុះមកត្រឹម ១,៥%នៃផលទុនក្នុងស្រុកសរុបនៅឆ្នាំ ២០២០។

**តារាង ៤.១ ការនិទស្សន៍ផ្នែកហិរញ្ញប្បទានសម្រាប់ជម្រើសគោលនយោបាយទី១ និង ទី២ ៖ ការដោះស្រាយបញ្ហាសន្តិសុខស្បៀងសម្រាប់ជនក្រីក្រ**

| | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ |
|---|---|---|---|---|---|---|---|---|---|
| ប្រជាជនក្រីក្រ ក្នុងកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ (គិតជាលាននាក់) | | | | | | | | | |
| ជនក្រីក្រកម្រិត១ | 1.94 | 1.83 | 1.71 | 1.58 | 1.45 | 1.32 | 1.18 | 1.04 | 0.90 |
| ជនក្រីក្រ១និង២ | 3.45 | 3.31 | 3.15 | 2.99 | 2.83 | 2.66 | 2.48 | 2.30 | 2.11 |
| និទស្សន៍ចំនួនអ្នកទទួលផល (គិតជាលាននាក់) | | | | | | | | | |
| ជម្រើសទី១ | 1.94 | 1.83 | 1.71 | 1.58 | 1.45 | 1.32 | 1.18 | 1.04 | 0.90 |
| ជម្រើសទី២ | 3.45 | 3.31 | 3.15 | 2.99 | 2.83 | 2.66 | 2.48 | 2.30 | 2.11 |
| បរិមាណលាភការក្នុងមួយឆ្នាំ (រៀល/ឆ្នាំ) | | | | | | | | | |
| ជម្រើសទី១ | 672 000 | 696 864 | 717770 | 739303 | 761482 | 784327 | 807856 | 832092 | 857055 |
| ជម្រើសទី២(a) | 900 000 | 933 300 | 961299 | 990138 | 1019842 | 1050437 | 1081950 | 1114409 | 1147841 |
| ជម្រើសទី២(b) | 450 000 | 466 650 | 480650 | 495069 | 509921 | 525219 | 540975 | 557205 | 573921 |
| ថវិកាចំណាយសរុប (គិតជាកោដិរៀល) | | | | | | | | | |
| ជម្រើសទី១ | 1435 | 1399 | 1347 | 1286 | 1217 | 1139 | 1052 | 954 | 845 |
| ជម្រើសទី២ | 2671 | 2634 | 2569 | 2492 | 2402 | 2298 | 2180 | 2047 | 1896 |
| ថវិកាចំណាយសរុប (គិតជាលានដុល្លារ) | | | | | | | | | |
| ជម្រើសទី១ | 342.8 | 334.4 | 321.8 | 307.3 | 290.9 | 272.3 | 251.4 | 228.0 | 202.0 |
| ជម្រើសទី២ | 638.2 | 629.5 | 613.9 | 595.4 | 573.9 | 549.2 | 521.0 | 489.1 | 453.1 |
| ការចំណាយថវិកាសម្រាប់កម្មវិធី គិតជា%នៃផលទុនក្នុងស្រុកសរុប | | | | | | | | | |
| ជម្រើសទី១ | 2.50 | 2.22 | 1.94 | 1.67 | 1.43 | 1.22 | 1.02 | 0.84 | 0.68 |
| ជម្រើសទី២ | 4.66 | 4.18 | 3.70 | 3.24 | 2.82 | 2.45 | 2.12 | 1.81 | 1.53 |

**កំណត់សម្គាល់:**

១. ជម្រើសទី២a ពាក់ព័ន្ធនឹងលាភការសម្រាប់អ្នកទទួលផលជាជនក្រីក្របំផុត (ID-Poor 1)ក្រោមជម្រើសគោលនយោបាយទី២

២. ជម្រើសទី២b ពាក់ព័ន្ធនឹងលាភការសម្រាប់អ្នកទទួលផលជាជនក្រីក្រទី២ (ID-Poor 2) ក្រោមជម្រើសគោលនយោបាយទី២

៣. គិតរួមទាំងចំណាយរដ្ឋបាល ដែលសន្មតថាស្មើនឹង ១០នៃថវិកាចំណាយ %លើលាភការ

ជាថ្មីម្តងទៀត ការនិទស្សន៍ខាងលើមានលក្ខណៈអភិរក្សនិយម។ ការឧបត្ថម្ភសាច់ប្រាក់ជូនដល់ជនក្រីក្រ នឹងភ្ជោចដល់វិស័យសេដ្ឋកិច្ចថ្នាក់មូលដ្ឋាន នៅតំបន់ជនបទ និងជំរុញជនក្រីក្រឲ្យចេញពីអន្ទាក់នៃភាពក្រីក្រ។ ដោយយោងទៅលើផលប៉ះពាល់ដែលការឧបត្ថម្ភសាច់ប្រាក់អាចមានលើជីវភាពរស់នៅរបស់ជនក្រីក្រ កម្មវីធីខាងលើនេះអាចចូលរួមដល់និន្នាការនៃការកាត់បន្ថយអត្រាឧប្បត្តិហេតុនៃភាពក្រីក្រនៅពេលអនាគត។

## ៤.២ គោលដៅទី២ ការកាត់បន្ថយភាពងាយរងគ្រោះលើកុមារនិងមាតា

តារាង៤.២ខាងក្រោម នឹងបង្ហាញពីនិទស្សន៍លើការប៉ាន់ប្រមាណលើការចំណាយថវិកាសម្រាប់ជម្រើសគោលនយោបាយទី៣ ទី៤ និងទី៥ ដែលជាការឆ្លើយតបទៅនឹងគោលដៅទី២ នៃ យ.ជ.គ.ស សម្រាប់អំឡុងឆ្នាំ២០១២-២០២០។

នៅក្នុងជម្រើសគោលនយោបាយទី៣ (ការឧបត្ថម្ភសាច់ប្រាក់សម្រាប់ស្ត្រីក្រីក្រ) ចំនួនស្ត្រីមានផ្ទៃពោះសរុបមានចំនួនប្រហែល៨៤៥០០នាក់នៅឆ្នាំ២០១២ (ឧបសម្ព័ន្ធ ៦.៥)។ ទំហំនៃលាភការ គឺសន្មតត្រឹម៨០%នៃបន្ទាត់នៃភាពក្រីក្រផ្នែកស្បៀងអាហារនៅតំបន់ជនបទ ឬស្មើនឹង ៧៥០០០រៀល(១៨,០០ ដុល្លារ) ក្នុងមួយខែ សម្រាប់រយៈពេល៦ខែ គឺស្មើនឹង៤៥០០០០រៀល (១០៨ដុល្លារ) សម្រាប់អ្នកទទួលផលម្នាក់។ ដោយគិតរួមទាំងចំណាយរដ្ឋបាលថវិកាចំណាយសរុបសម្រាប់ឆ្នាំ២០១២ គឺស្មើនឹង៤២កោដិរៀល (១០លានដុល្លារ) ដែលស្មើនឹង០,០៧%នៃផលទុនក្នុងស្រុកសរុប។ យោងទៅលើការធ្វើនិទស្សន៍លើការធ្លាក់ចុះនៃភាពក្រីក្រ ការធ្លាក់ចុះនៃអត្រានៃការបង្កកំណើត និងកំណើនដោយមាននិរន្តភាពនៃផលទុនក្នុងស្រុកសរុប ថវិកាចំណាយសម្រាប់កម្មវិធីអាចនឹងត្រូវថយចុះមកត្រឹម០,០២%នៃផលទុនក្នុងស្រុកសរុប នៅឆ្នាំ២០២០។

នៅក្នុងជម្រើសគោលនយោបាយទី៤ (ការឧបត្ថម្ភសាច់ប្រាក់សម្រាប់កុមារក្រីក្រ អាយុ ០-២ឆ្នាំ) កុមារក្រីក្រសរុបមានចំនួនប្រហែល២៦៦០០០នាក់ នៅឆ្នាំ២០១២។ យោងទៅលើការធ្វើនិទស្សន៍លើការធ្លាក់ចុះនៃភាពក្រីក្រ និងការធ្លាក់ចុះនៃអត្រានៃការបង្កកំណើត ចំនួនកុមារក្រីក្រអាចនឹងត្រូវធ្លាក់ចុះពាក់កណ្តាល នៅឆ្នាំ២០២០។ ទំហំនៃលាភការគឺសន្មតត្រឹម៦០%នៃបន្ទាត់នៃភាពក្រីក្រផ្នែកស្បៀងអាហារនៅតំបន់ជនបទ ឬស្មើនឹង៥៦០០០រៀល (១៣,៤០ដុល្លារ) ក្នុងមួយខែ គឺស្មើនឹង៦៧២០០០រៀល (១៦១ដុល្លារ) សម្រាប់អ្នកទទួលផលម្នាក់ ក្នុងមួយឆ្នាំ។ ថវិកាចំណាយសរុបសម្រាប់ឆ្នាំ២០១២ គឺស្មើនឹង១៩៧កោដិរៀល (៤៧លានដុល្លារ) ដែលស្មើនឹង០,៣៤%នៃផលទុនក្នុងស្រុកសរុប។ ថវិកាចំណាយសម្រាប់កម្មវិធីអាចនឹងត្រូវថយចុះមកត្រឹម០,១០% នៃផលទុនក្នុងស្រុកសរុប នៅឆ្នាំ២០២០។

នៅក្នុងជម្រើសគោលនយោបាយទី៥ (ការឧបត្ថម្ភសាច់ប្រាក់សម្រាប់កុមារក្រីក្រ អាយុ ៦-១១ឆ្នាំ) កុមារក្រីក្រសរុបមានចំនួនប្រហែល ៤១៨០០០នាក់ នៅឆ្នាំ២០១២ ហើយដែលចំនួននេះនឹងថយចុះជាបណ្តើរៗរហូតដល់២៥១០០០ នៅឆ្នាំ២០២០។ ទំហំនៃលាភការគឺសន្មតត្រឹម ៦០%នៃបន្ទាត់នៃភាពក្រីក្រផ្នែកស្បៀងអាហារនៅតំបន់ជនបទ ឬស្មើនឹង៥៦០០០រៀល (១៣,៤០ ដុល្លារ) ក្នុងមួយខែ គឺស្មើនឹង៦៧២០០០រៀល (១៦១ដុល្លារ) សម្រាប់អ្នកទទួលផលម្នាក់ ក្នុងមួយឆ្នាំ។ ថវិកាចំណាយសរុបសម្រាប់ឆ្នាំ២០១២គឺស្មើនឹង៣០៩កោដិរៀល (៧៤លានដុល្លារ) ដែលស្មើ

នឹង០,៥៤%នៃផលទុនក្នុងស្រុកសរុប។ ថវិកាចំណាយសម្រាប់កម្មវិធី អាចនឹងត្រូវថយចុះមកត្រឹម ០,១៩% នៃផលទុនក្នុងស្រុកសរុបនៅឆ្នាំ២០២០។

**តារាង ៤.២ ការនិទស្សន៍ផ្នែកហិរញ្ញប្បទានសម្រាប់ជម្រើសគោលនយោបាយទី៣ ទី៤ និង ទី៥ ៖ ការឧបត្ថម្ភសាច់ប្រាក់សម្រាប់មាតានិងកុមារក្រីក្រ**

| | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ |
|---|---|---|---|---|---|---|---|---|---|
| និទស្សន៍ចំនួនអ្នកទទួលផល | | | | | | | | | |
| ជម្រើសទី៣ | 84533 | 79596 | 74503 | 69282 | 64769 | 60052 | 55163 | 50135 | 45039 |
| ជម្រើសទី៤ | 266515 | 247836 | 232214 | 216545 | 200849 | 185150 | 169429 | 153653 | 137865 |
| ជម្រើសទី៥ | 418154 | 392960 | 363709 | 342458 | 328339 | 312330 | 293398 | 272568 | 251268 |
| បរិមាណលាភការក្នុងមួយឆ្នាំ (រៀល/ឆ្នាំ)[១] | | | | | | | | | |
| ជម្រើសទី៣ | 9.38 | 9.72 | 10.01 | 10.31 | 10.62 | 10.94 | 11.27 | 11.61 | 11.96 |
| ជម្រើសទី៤ | 14.00 | 14.52 | 14.95 | 15.40 | 15.86 | 16.34 | 16.83 | 17.34 | 17.86 |
| ជម្រើសទី៥ | 14.00 | 14.52 | 14.95 | 15.40 | 15.86 | 16.34 | 16.83 | 17.34 | 17.86 |
| ថវិកាចំណាយសរុប (គិតជាកោដិរៀល)[២] | | | | | | | | | |
| ជម្រើសទី៣ | 41.8 | 40.9 | 39.4 | 37.7 | 36.3 | 34.7 | 32.8 | 30.7 | 28.4 |
| ជម្រើសទី៤ | 197.0 | 190.0 | 183.3 | 176.1 | 168.2 | 159.7 | 150.6 | 140.6 | 130.0 |
| ជម្រើសទី៥ | 309.1 | 301.2 | 287.2 | 278.5 | 275.0 | 269.5 | 260.7 | 249.5 | 236.9 |
| ថវិកាចំណាយសរុប (គិតជាលានដុល្លារ)[១,២] | | | | | | | | | |
| ជម្រើសទី៣ | 10.0 | 9.8 | 9.4 | 9.0 | 8.7 | 8.3 | 7.8 | 7.3 | 6.8 |
| ជម្រើសទី៤ | 47.1 | 45.4 | 43.8 | 42.1 | 40.2 | 38.2 | 36.0 | 33.6 | 31.1 |
| ជម្រើសទី៥ | 73.9 | 72.0 | 68.6 | 66.5 | 65.7 | 64.4 | 62.3 | 59.6 | 56.6 |
| ការចំណាយថវិកាសម្រាប់កម្មវិធី គិតជា%នៃផលទុនក្នុងស្រុកសរុប | | | | | | | | | |
| ជម្រើសទី៣ | 0.07 | 0.06 | 0.06 | 0.05 | 0.04 | 0.04 | 0.03 | 0.03 | 0.02 |
| ជម្រើសទី៤ | 0.34 | 0.30 | 0.26 | 0.23 | 0.20 | 0.17 | 0.15 | 0.12 | 0.10 |
| ជម្រើសទី៥ | 0.54 | 0.48 | 0.41 | 0.36 | 0.32 | 0.29 | 0.25 | 0.22 | 0.19 |

**កំណត់សម្គាល់:**

១. សម្រាប់ជម្រើសទី៣ អ្នកទទួលផលនឹងទទួលលាភការតែក្នុងរយៈពេល៦ខែតែប៉ុណ្ណោះ

២. រួមបញ្ចូលទាំងថវិកាចំណាយរដ្ឋបាល ដែលសន្មតថាស្មើនឹង១០%នៃការចំណាយលើប្រាក់លាភការ

តារាង៤.៣ បង្ហាញពីលទ្ធផលនៃការធ្វើនិទស្សន៍លើបរិមាណលាភការជាលក្ខណៈសកល ដែលសន្មតសម្រាប់ជម្រើសគោលនយោបាយទី៣ស, ៤ស, ៥ស ("**ស**" គឺតំណាងឲ្យការផ្តល់លាភការជាលក្ខណៈសកល សម្រាប់ក្រុមជនគោលដៅទាំងអស់គ្នា)។ ការចំណាយថវិកាសរុបសម្រាប់កម្មវិធីនីមួយៗ អាចស្មើនឹង០,៣% ១,៣% និង២,២% នៃផលទុនក្នុងស្រុកសរុប នៅឆ្នាំ២០១២។ នៅឆ្នាំ២០២០ ការចំណាយថវិកាសរុបសម្រាប់កម្មវិធីនីមួយៗ អាចធ្លាក់ចុះមកត្រឹម

០,១៥% ០,៧% និង១,៤% នៃផលទុនក្នុងស្រុកសរុប សម្រាប់ជម្រើសគោលនយោបាយទាំងបីខាងលើ។

**តារាង ៤.៣ ការនិទស្សន៍ផ្នែកហិរញ្ញប្បទានសម្រាប់ជម្រើសគោលនយោបាយទី៣ស ទី៤ស និង ទី៥ស ៖ ការឧបត្ថម្ភសាច់ប្រាក់សម្រាប់មាតានិងកុមារ ជាលក្ខណៈសកល**

| | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ |
|---|---|---|---|---|---|---|---|---|---|
| និទស្សន៍ចំនួនអ្នកទទួលផល (គិតជាលាននាក់) | | | | | | | | | |
| ជម្រើសទី៣ស | 0.33 | 0.33 | 0.33 | 0.33 | 0.33 | 0.33 | 0.33 | 0.33 | 0.32 |
| ជម្រើសទី៤ស | 1.00 | 0.99 | 0.99 | 0.98 | 0.98 | 0.98 | 0.98 | 0.97 | 0.96 |
| ជម្រើសទី៥ស | 1.70 | 1.69 | 1.67 | 1.68 | 1.73 | 1.78 | 1.82 | 1.86 | 1.90 |
| បរិមាណលាភការក្នុងមួយឆ្នាំ (ដុល្លារ/ខែ) | | | | | | | | | |
| ជម្រើសទី៣ស | 18.75 | 9.72 | 10.01 | 10.31 | 10.62 | 10.94 | 11.27 | 11.61 | 11.96 |
| ជម្រើសទី៤ស | 14.00 | 14.52 | 14.95 | 15.40 | 15.86 | 16.34 | 16.83 | 17.34 | 17.86 |
| ជម្រើសទី៥ស | 14.00 | 14.52 | 14.95 | 15.40 | 15.86 | 16.34 | 16.83 | 17.34 | 17.86 |
| ថវិកាចំណាយសរុប (គិតជាកោដិរៀល) [១] | | | | | | | | | |
| ជម្រើសទី៣ស | 164 | 169 | 174 | 178 | 184 | 190 | 195 | 199 | 203 |
| ជម្រើសទី៤ស | 738 | 756 | 778 | 800 | 823 | 845 | 867 | 889 | 910 |
| ជម្រើសទី៥ស | 1 256 | 1 298 | 1 317 | 1 364 | 1 448 | 1 535 | 1 618 | 1 699 | 1 788 |
| ថវិកាចំណាយសរុប (គិតជាលានដុល្លារ) [១] | | | | | | | | | |
| ជម្រើសទី៣ស | 39.1 | 40.5 | 41.5 | 42.5 | 44.0 | 45.3 | 46.5 | 47.6 | 48.6 |
| ជម្រើសទី៤ស | 176.4 | 180.7 | 186.0 | 191.3 | 196.6 | 201.9 | 207.2 | 212.4 | 217.3 |
| ជម្រើសទី៥ស | 300.1 | 310.3 | 314.6 | 325.8 | 346.1 | 366.8 | 386.5 | 406.0 | 427.2 |
| ការចំណាយថវិកាសម្រាប់កម្មវិធី គិតជា%នៃផលទុនក្នុងស្រុកសរុប | | | | | | | | | |
| ជម្រើសទី៣ស | 0.29 | 0.27 | 0.25 | 0.23 | 0.22 | 0.20 | 0.19 | 0.18 | 0.16 |
| ជម្រើសទី៤ស | 1.29 | 1.20 | 1.12 | 1.04 | 0.97 | 0.90 | 0.84 | 0.79 | 0.73 |
| ជម្រើសទី៥ស | 2.19 | 2.06 | 1.89 | 1.77 | 1.70 | 1.64 | 1.57 | 1.50 | 1.44 |

**កំណត់សម្គាល់:**

១. រួមបញ្ចូលទាំងថវិកាចំណាយរដ្ឋបាល ដែលសន្មតថាស្មើនឹង១០%នៃការចំណាយលើប្រាក់លាភការ

## ៤.៣ គោលដៅទី៣ ការដោះស្រាយបញ្ហានិកម្មភាពជាលក្ខណៈរដូវកាល

តារាង៤.៤ខាងក្រោម នឹងបង្ហាញពីនិទស្សន៍លើការប៉ាន់ប្រមាណលើការចំណាយថវិកាសម្រាប់ជម្រើសគោលនយោបាយទី៦ និងទី៧ (កម្មវិធីសំណង់សាធារណៈ)។ គ្រួសារក្រីក្រសរុបមានចំនួនប្រហែល៧៥១០០០នាក់នៅឆ្នាំ២០១២ ដែលត្រូវជា៤២២០០០គ្រួសារក្រីក្រកម្រិត១ និង៣៧៩០០០គ្រួសារក្រីក្រកម្រិត២ (ឧបសម្ព័ន្ធ ៦.៥)។

នៅក្នុងជម្រើសគោលនយោបាយទី៦ (កម្មវិធីសំណង់សាធារណៈ) ចំនួនអ្នកចូលរួមក្នុងកម្មវិធីគឺអាចសន្មតថាស្មើនឹង១០%នៃចំនួនគ្រួសារក្រីក្រ គឺត្រូវជា៤២២០០នាក់ ក្នុងឆ្នាំ២០១២។ ប្រសិនបើប្រាក់កម្រៃមានកម្រិតស្មើនឹង១០០០០រៀល ឬ២,៤០ដុល្លារ (សម្រាប់ឆ្នាំ២០១២) ហើយផ្តល់ជូនសម្រាប់៨០ថ្ងៃការងារ ប្រាក់កម្រៃសរុបសម្រាប់កម្មករម្នាក់អាចមានបរិមាណ៨០ម៉ឺនរៀល (១៩២ដុល្លារ) ដែលត្រូវជា៣៣,៨កោដិរៀល (៨,១លានដុល្លារ) សម្រាប់ការចំណាយលើប្រាក់កម្រៃ។ ដោយសន្មតថាសមមាត្រនៃការចំណាយក្រៅពីប្រាក់កម្រៃអាចស្មើនឹង៥០% (ឧបសម្ព័ន្ធ ៦.៥) ថវិកាចំណាយសរុបសម្រាប់កម្មវិធីទាំងមូលគឺស្មើនឹង៦៧,៦កោដិរៀល (១៦,២លានដុល្លារ) ដែលស្មើនឹង០,១២%នៃផលទុនក្នុងស្រុកសរុប។ យោងទៅលើការធ្វើនិទស្សន៍លើការធ្លាក់ចុះនៃភាពក្រីក្រ និងកំណើនដោយមាននិរន្តភាពនៃផលទុនក្នុងស្រុកសរុប ថវិកាចំណាយសម្រាប់កម្មវិធីអាចនឹងត្រូវថយចុះមកត្រឹម០,០៤%នៃផលទុនក្នុងស្រុកសរុប នៅឆ្នាំ២០២០ ដោយសន្មតថាអត្រាចូលរួមក្នុងកម្មវិធីនឹងស្ថិតនៅថេរ (១០%) ក្នុងចំណោមគ្រួសារក្រីក្រកម្រិតទី១ ក្នុងអំឡុងពេលនៃការធ្វើនិទស្សន៍។

ក្នុងជម្រើសគោលនយោបាយទី៧ អ្នកចូលរួមក្នុងកម្មវិធីគឺអាចមានចំនួន៧៥១០០នាក់ ក្នុងឆ្នាំ២០១២។ ដោយប្រើការសន្មតដូចគ្នាទៅនឹងជម្រើសគោលនយោបាយទី៦ដើម្បីកំណត់កម្រិតប្រាក់កម្រៃនិងរយៈពេលការងារ ប្រាក់កម្រៃសរុបសម្រាប់កម្មករទាំងអស់អាចមានបរិមាណ៦០កោដិរៀល (១៤,៤លានដុល្លារ) នៅឆ្នាំ២០១២។ ដោយសន្មតថាសមមាត្រនៃការចំណាយក្រៅពីប្រាក់កម្រៃអាចស្មើនឹង៥០% ថវិកាចំណាយសរុបសម្រាប់កម្មវិធីទាំងមូលគឺស្មើនឹង១២០កោដិរៀល (២៨,៨លានដុល្លារ) ឬត្រូវជា០,២១%នៃផលទុនក្នុងស្រុកសរុប។ យោងទៅលើការធ្វើនិទស្សន៍លើការធ្លាក់ចុះនៃភាពក្រីក្រនិងកំណើនដោយមាននិរន្តភាពនៃផលទុនក្នុងស្រុកសរុប ថវិកាចំណាយសម្រាប់កម្មវិធីអាចនឹងត្រូវថយចុះមកត្រឹម០,០៩%នៃផលទុនក្នុងស្រុកសរុប នៅឆ្នាំ២០២០ ដោយសន្មតថាអត្រាចូលរួមក្នុងកម្មវិធីនឹងស្ថិតនៅថេរ (១០%) ក្នុងចំណោមគ្រួសារក្រីក្រកម្រិតទី១ ក្នុងអំឡុងពេលនៃការធ្វើនិទស្សន៍។

**តារាង ៤.៤ ការនិទស្សន៍ផ្នែកហិរញ្ញប្បទានសម្រាប់ជម្រើសគោលនយោបាយទី៦ និងទី៧ ៖ កម្មវិធីសំណង់សាធារណៈ**

| | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ |
|---|---|---|---|---|---|---|---|---|---|
| ចំនួនគ្រួសារក្រីក្រក្នុងកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ | | | | | | | | | |
| កម្រិត១ | 421 946 | 396 834 | 370 801 | 343 825 | 315 926 | 287 110 | 257 352 | 226 633 | 194 952 |
| កម្រិត១និង២ | 750 958 | 718 855 | 685 486 | 650 812 | 614 867 | 577 666 | 539 157 | 499 302 | 458 078 |
| និទស្សន៍ចំនួនអ្នកទទួលផល | | | | | | | | | |
| ជម្រើសទី៦ | 42 195 | 39 683 | 37 080 | 34 383 | 31 593 | 28 711 | 25 735 | 22 663 | 19 495 |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ជម្រើសទី៧ | 75 096 | 71 885 | 68 549 | 65 081 | 61 487 | 57 767 | 53 916 | 49 930 | 45 808 |
| ការសន្មតលើបរិមាណប្រាក់កម្រៃសម្រាប់ជម្រើសគោលនយោបាយទី៦និងទី៧ (ដុល្លារ) | | | | | | | | | |
| កម្រៃប្រចាំថ្ងៃ | 2.4 | 2.5 | 2.6 | 2.8 | 2.9 | 3.1 | 3.3 | 3.4 | 3.6 |
| សរុប (៨០ថ្ងៃ) | 191.2 | 201.7 | 211.9 | 223.4 | 235.6 | 248.0 | 261.0 | 274.7 | 289.2 |
| ថវិកាចំណាយសរុប (គិតជាកោដិរៀល) [១] | | | | | | | | | |
| ជម្រើសទី៦ | 67.5 | 67.0 | 65.8 | 64.3 | 62.3 | 59.6 | 56.2 | 52.1 | 47.2 |
| ជម្រើសទី៧ | 120.2 | 121.4 | 121.6 | 121.7 | 121.3 | 119.9 | 117.8 | 114.8 | 110.9 |
| ថវិកាចំណាយសរុប (គិតជាលានដុល្លារ) [១] | | | | | | | | | |
| ជម្រើសទី៦ | 16.1 | 16.0 | 15.7 | 15.4 | 14.9 | 14.2 | 13.4 | 12.5 | 11.3 |
| ជម្រើសទី៧ | 28.7 | 29.0 | 29.1 | 29.1 | 29.0 | 28.7 | 28.1 | 27.4 | 26.5 |
| ការចំណាយថវិកាសម្រាប់កម្មវិធី គិតជា%នៃផលទុនក្នុងស្រុកសរុប | | | | | | | | | |
| ជម្រើសទី៦ | 0.12 | 0.11 | 0.09 | 0.08 | 0.07 | 0.06 | 0.05 | 0.05 | 0.04 |
| ជម្រើសទី៧ | 0.21 | 0.19 | 0.17 | 0.16 | 0.14 | 0.13 | 0.11 | 0.10 | 0.09 |

**កំណត់សម្គាល់:**

១. រួមបញ្ចូលទាំងថវិកាចំណាយក្រៅពីប្រាក់កម្រៃពលកម្ម (រួមមានចំណាយលើសម្ភារៈ) និងថវិកាចំណាយរដ្ឋបាល ដែលសន្មតថាស្មើនឹង៥០%នៃថវិកាចំណាយសរុប

## ៤.៤ គោលដៅទី៤ ការពង្រីកវិសាលភាពការគាំពារសុខភាព

តារាង៤.៥ខាងក្រោម នឹងបង្ហាញពីនិទស្សន៍លើការប៉ាន់ប្រមាណលើការចំណាយថវិកាសម្រាប់ជម្រើសគោលនយោបាយទី៨ (ការពង្រីកវិសាលភាពមូលនិធិសមធម៌សុខភាព)។ ការបកស្រាយជាពិស្តារលើលក្ខណៈម៉ូដែលនិងការសន្មត នឹងបង្ហាញនៅក្នុងឧបសម្ព័ន្ធ៦.៦។ បរិមាណនៃថវិកាចំណាយដែលបង្ហាញនៅក្នុងតារាង៤.៥ នឹងឆ្លុះបញ្ចាំងលើថវិកាចំណាយរបស់មូលនិធិសមធម៌ដែលស្ថិតក្រោមការឧបត្ថម្ភនៅពេលបច្ចុប្បន្ន និងដោយសន្មតថាមានវិសាលភាពពេញលេញ ហើយតួរលេខនេះពុំរាប់បញ្ចូលថវិកាឧបត្ថម្ភកធនសម្រាប់ផ្នែកផ្គត់ផ្គង់ (មន្ទីរពេទ្យ មណ្ឌលសុខភាព សម្ភារៈ) ឡើយ ដែលការចំណាយទាំងនេះនឹងស្ថិតនៅក្រោមកញ្ចប់ថវិកាជាតិ[2]។

**តារាង ៤.៥ ការនិទស្សន៍ផ្នែកហិរញ្ញប្បទានសម្រាប់ជម្រើសគោលនយោបាយទី៨ ៖ ការពង្រីកមូលនិធិសមធម៌**

| | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ |
|---|---|---|---|---|---|---|---|---|---|
| វិសាលភាពកម្មវិធី (លាន) [១] | 3.45 | 3.31 | 3.15 | 2.99 | 2.83 | 2.66 | 2.48 | 2.30 | 2.11 |
| ចំណាយផ្ទាល់ (លានដុល្លារ) | 10.99 | 11.85 | 12.59 | 13.26 | 13.88 | 14.39 | 14.78 | 14.95 | 14.95 |
| ចំណាយពុំផ្ទាល់ (លានដុល្លារ) [២] | 2.72 | 2.94 | 3.12 | 3.29 | 3.44 | 3.57 | 3.66 | 3.70 | 3.70 |
| សរុបថ្លៃចំណាយ (លានដុល្លារ) | **13.72** | **14.79** | **15.71** | **16.55** | **17.31** | **17.96** | **18.45** | **18.65** | **18.66** |

2 ដោយសារហិរញ្ញប្បទានលើផ្នែកផ្គត់ផ្គង់ក្នុងវិស័យសុខាភិបាលនៃប្រតិបត្តិករសុខាភិបាលសាធារណៈ នឹងគ្របដណ្តប់លើការចំណាយលើហេដ្ឋារចនាសម្ព័ន្ធ ប្រាក់បៀវត្សរ៍ ឱសថ និងថ្លៃប្រតិបត្តិការមូលដ្ឋាន ការចំណាយលើមូលនិធិសមធម៌នឹងមានទំហំតូច ហើយឆ្លុះបញ្ចាំងតែផ្នែកតូចមួយនៃថវិកាចំណាយសរុបនៃសេវាកម្មវេជ្ជសាស្ត្រដែលផ្តល់ជូនជនក្រីក្រក្នុងកម្មវិធីមូលនិធិសមធម៌។ ការវាយតម្លៃលើសេចក្តីត្រូវការហិរញ្ញប្បទានសម្រាប់វិស័យផ្គត់ផ្គង់ គឺស្ថិតនៅក្រៅពីវិសាលភាពនៃការសិក្សានេះ។

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ចំណាយក្នុងម្នាក់ (ដុល្លារ/ឆ្នាំ) | 3.97 | 4.47 | 4.98 | 5.53 | 6.12 | 6.76 | 7.44 | 8.12 | 8.85 |
| សរុប (%នៃផល ទុនក្នុងស្រុក) | 0.10 | 0.10 | 0.09 | 0.09 | 0.09 | 0.08 | 0.07 | 0.07 | 0.06 |

**កំណត់សម្គាល់:**

១. ដោយសន្មតថាមានវិសាលភាពពេញលេញសម្រាប់ជនក្រីក្រគ្រប់រូប (ជនក្រីក្រកម្រិតទី១និងទី២) នៅឆ្នាំ២០១២

២. ថវិកាចំណាយពុំផ្ទាល់ ត្រូវសន្មតថាមានសមមាត្រថេរ គឺស្មើនឹង២៤,៨%នៃថវិកាចំណាយផ្ទាល់

ថវិកាចំណាយសរុបសម្រាប់កម្មវិធីមូនិធិសមធម៌សម្រាប់ឆ្នាំ២០១២ គឺស្មើនឹង១៣,៧ លានដុល្លារ ដែលត្រូវជា០,១០%នៃផលទុនក្នុងស្រុកសរុប។ ថវិកាចំណាយសម្រាប់កម្មវិធី អាចនឹងត្រូវថយចុះមកត្រឹម០,០៦%នៃផលទុនក្នុងស្រុកសរុបនៅឆ្នាំ២០២០ ដោយសារការធ្លាក់ចុះនៃភាពក្រីក្រនិងកំណើនដោយមាននិរន្តភាពនៃផលទុនក្នុងស្រុកសរុប។ ថវិកាចំណាយគិតជាមធ្យមប្រចាំឆ្នាំក្នុងមនុស្សម្នាក់នៅក្នុងកម្មវិធីមូលនិធិសមធម៌ អាចនឹងកើនឡើងពី៣,៩៧ដុល្លារនៅឆ្នាំ២០១២ ដល់៨,៨៥ដុល្លារក្នុងឆ្នាំ២០២០ ដោយសារការសន្មតនៃកំណើនការប្រើប្រាស់ និងអតិផរណានៃថ្លៃព្យាបាល (ឧបសម្ព័ន្ធ ៦.៦)។

## ៤.៥ គោលដៅទី៥ ការពង្រីកវិសាលភាពនៃការគាំពារសង្គមសម្រាប់ជនងាយរងគ្រោះពិសេស

តារាង៤.៦ខាងក្រោម នឹងបង្ហាញពីនិទស្សន៍លើការប៉ាន់ប្រមាណលើការចំណាយថវិកាសម្រាប់ជម្រើសគោលនយោបាយទី៩ ទី១០ និងទី១១ ស្តីពីរបបសោធននិវត្តន៍ជនចាស់ជរា។ នៅក្នុងជម្រើសគោលនយោបាយទី៩ ជនចាស់ជរាក្រីក្របំផុតដែលមានអាយុលើសពី៧០ឆ្នាំ មានចំនួនប្រហែល៦៥០០០នាក់ នៅឆ្នាំ២០១២។ ចំនួននេះអាចនឹងថយចុះមកតិចជាង៣៤០០០នាក់នៅឆ្នាំ២០២០ ដោយសារការធ្លាក់ចុះនៃអត្រាប្រេវ៉ាឡង់នៃភាពក្រីក្រ។ ទំហំនៃលាភការគឺសន្មតស្មើនឹង ១០០%នៃបន្ទាត់នៃភាពក្រីក្រផ្នែកស្បៀងអាហារ នៅតំបន់ជនបទ ហើយថវិកាចំណាយសរុបសម្រាប់កម្មវិធីរបបសោធនជនចាស់ជរាក្នុងឆ្នាំ២០១២ គឺស្មើនឹង៨០កោដិរៀល (១៩លានដុល្លារ) ដែលស្មើនឹង០,១៤%នៃផលទុនក្នុងស្រុកសរុប។ យោងទៅលើការធ្វើនិទស្សន៍លើការធ្លាក់ចុះនៃភាពក្រីក្រ និងកំណើនដោយមាននិរន្តភាពនៃផលទុនក្នុងស្រុកសរុប ថវិកាចំណាយកម្មវិធីអាចនឹងត្រូវថយចុះមកត្រឹម០,០៤%នៃផលទុនជាតិសរុប នៅឆ្នាំ២០២០។

**តារាង ៤.៦ ការនិទស្សន៍ផ្នែកហិរញ្ញប្បទានសម្រាប់ជម្រើសគោលនយោបាយទី៩ ទី១០ និង ទី១១ ៖ របបសោធនសម្រាប់ជនចាស់ជរាក្រីក្រ**

| | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ |
|---|---|---|---|---|---|---|---|---|---|
| និទស្សន៍ចំនួនអ្នកទទួលផល | | | | | | | | | |
| ជម្រើសទី៩ | 64 779 | 61 336 | 57 712 | 53 961 | 50 121 | 46 227 | 42 252 | 38 128 | 33 754 |
| ជម្រើសទី១០ | 157 218 | 152 114 | 147 192 | 142 313 | 137 244 | 131 747 | 125 679 | 118 926 | 111 477 |
| ជម្រើសទី១១ | 229 799 | 223 860 | 217 318 | 210 203 | 202 579 | 194 521 | 185 999 | 176 851 | 166 840 |
| បរិមាណលាភការក្នុងមួយឆ្នាំ (ដុល្លារ/ខែ) | | | | | | | | | |
| ជម្រើសទី៩ | 22.5 | 23.3 | 24.0 | 24.7 | 25.5 | 26.2 | 27.0 | 27.8 | 28.6 |
| ជម្រើសទី១០ | 22.5 | 23.3 | 24.0 | 24.7 | 25.5 | 26.2 | 27.0 | 27.8 | 28.6 |
| ជម្រើសទី១១ | 22.5 | 23.3 | 24.0 | 24.7 | 25.5 | 26.2 | 27.0 | 27.8 | 28.6 |
| ថវិកាចំណាយសរុប (គិតជាកោដិរៀល) [១] | | | | | | | | | |
| ជម្រើសទី៩ | 80.4 | 78.9 | 76.5 | 73.7 | 70.5 | 66.9 | 63.0 | 58.6 | 53.4 |
| ជម្រើសទី១០ | 195.1 | 195.7 | 195.1 | 194.3 | 193.0 | 190.8 | 187.5 | 182.7 | 176.4 |
| ជម្រើសទី១១ | 285.1 | 288.0 | 288.0 | 286.9 | 284.8 | 281.7 | 277.4 | 271.7 | 264.0 |
| ថវិកាចំណាយសរុប (គិតជាលានដុល្លារ) [១] | | | | | | | | | |
| ជម្រើសទី៩ | 19.2 | 18.9 | 18.3 | 17.6 | 16.8 | 16.0 | 15.1 | 14.0 | 12.8 |
| ជម្រើសទី១០ | 46.6 | 46.8 | 46.6 | 46.4 | 46.1 | 45.6 | 44.8 | 43.7 | 42.2 |
| ជម្រើសទី១១ | 68.1 | 68.8 | 68.8 | 68.6 | 68.1 | 67.3 | 66.3 | 64.9 | 63.1 |
| ការចំណាយថវិកាសម្រាប់កម្មវិធី គិតជា%នៃផលទុនក្នុងស្រុកសរុប | | | | | | | | | |
| ជម្រើសទី៩ | 0.14 | 0.13 | 0.11 | 0.10 | 0.08 | 0.07 | 0.06 | 0.05 | 0.04 |
| ជម្រើសទី១០ | 0.34 | 0.31 | 0.28 | 0.25 | 0.23 | 0.20 | 0.18 | 0.16 | 0.14 |
| ជម្រើសទី១១ | 0.50 | 0.46 | 0.41 | 0.37 | 0.33 | 0.30 | 0.27 | 0.24 | 0.21 |

**កំណត់សម្គាល់:**

១. រួមបញ្ចូលទាំងថវិកាចំណាយរដ្ឋបាល ដែលសន្មតថាស្មើនឹង១០%នៃការចំណាយលើប្រាក់លាភការ

នៅក្នុងជម្រើសគោលនយោបាយទី១០ ជនចាស់ជរាក្រីក្រដែលមានអាយុលើសពី៦៥ឆ្នាំ មានចំនួនប្រហែល១៥៧០០០នាក់ នៅឆ្នាំ២០១២។ ទំហំនៃលាភការប្រចាំខែ គឺសន្មតស្មើនឹង១០០%នៃបន្ទាត់នៃភាពក្រីក្រផ្នែកស្បៀងអាហារនៅតំបន់ជនបទ គឺស្មើនឹង៩៤០០០រៀល ហើយថវិកាចំណាយសរុបសម្រាប់កម្មវិធីរបបសោធនជនចាស់ជរាក្នុងឆ្នាំ២០១២ គឺស្មើនឹង១៩៥កោដិរៀល (៤៧លានដុល្លារ) ដែលស្មើនឹង០,៣៤%នៃផលទុនក្នុងស្រុកសរុប។ យោងទៅលើការធ្វើនិទស្សន៍លើការធ្លាក់ចុះនៃភាពក្រីក្រនិងកំណើនដោយមាននិរន្តភាពនៃផលទុនក្នុងស្រុកសរុប ថវិកាចំណាយកម្មវិធី អាចនឹងត្រូវថយចុះមកត្រឹម០,១៤%នៃផលទុនក្នុងស្រុកសរុប នៅឆ្នាំ២០២០។

នៅក្នុងជម្រើសគោលនយោបាយទី១១ ជនចាស់ជរាក្រីក្រដែលមានអាយុលើសពី៦០ឆ្នាំ មានចំនួនប្រហែល២៣០,០០០នាក់ នៅឆ្នាំ២០១២ ហើយដែលនឹងថយចុះជាបន្តបន្ទាប់មក

ត្រឹម១៦៧០០០នាក់ក្នុងឆ្នាំ២០២០។ ទំហំនៃលាភការប្រចាំខែគឺសន្មតស្មើនឹង១០០% នៃបន្ទាត់នៃភាពក្រីក្រផ្នែកស្បៀងអាហារនៅតំបន់ជនបទ គឺស្មើនឹង៩៤,០០០រៀល (២២,៥០ដុល្លារ)ហើយថវិកាចំណាយសរុបសម្រាប់កម្មវិធីរបបសោធនជនចាស់ជរាក្នុងឆ្នាំ២០១២ គឺស្មើនឹង២៨៥កោដិរៀល (៦៨លានដុល្លារ) ដែលស្មើនឹង០,៥%នៃផលទុនក្នុងស្រុកសរុប។យោងតាមការធ្វើនិទស្សន៍លើការធ្លាក់ចុះនៃភាពក្រីក្រនិងកំណើនដោយមាននិរន្តភាពនៃផលទុនក្នុងស្រុកសរុប ថវិកាចំណាយកម្មវិធី អាចនឹងត្រូវថយចុះមកត្រឹម០,២%នៃផលទុនក្នុងស្រុកសរុប នៅឆ្នាំ២០២០។

តារាង៤.៧ បង្ហាញពីលទ្ធផលនៃការធ្វើនិទស្សន៍លើបរិមាណលាភការជាលក្ខណៈសកល ដែលសន្មតសម្រាប់ជម្រើសគោលនយោបាយទី៩ស, ១០ស, និង១១ស។ នៅឆ្នាំ២០១២ ជនចាស់ជរាកម្ពុជា ដែលមានអាយុលើសពី៧០ឆ្នាំ (ជម្រើសទី៩ស) មានចំនួន៤០០០០០នាក់ អ្នកដែលអាយុលើសពី៦៥ឆ្នាំ (ជម្រើសទី១០ស) មានចំនួន៦៤៣០០០នាក់ និងអ្នកដែលអាយុលើសពី៦០ឆ្នាំ (ជម្រើសទី១១ស) មានចំនួន១លាននាក់។ ដោយសារកំណើននៃចំនួនប្រជាជន និងកំណើននៃជរាភាព ចំនួនជនចាស់ជរាកម្ពុជានៅឆ្នាំ២០២០ ដែលមានអាយុលើសពី៧០ឆ្នាំ (ជម្រើសទី៩ស) អាចនឹងកើនដល់៥០៧,០០០នាក់ អាយុលើសពី៦៥ឆ្នាំ (ជម្រើសទី១០ស) អាចនឹងកើនដល់៨៦២,០០០នាក់ និងអាយុលើសពី៦០ឆ្នាំ (ជម្រើសទី១១ស) អាចនឹងកើនដល់ ចំនួន១,៣៦លាននាក់។ ការចំណាយថវិកាសរុបសម្រាប់កម្មវិធីនីមួយៗនៅឆ្នាំ២០១២ អាចស្មើនឹង៤៩៦កោដិរៀល (១១៩លានដុល្លារ) សម្រាប់ជម្រើសទី៩ស ៧៩៨កោដិរៀល (១៩១លានដុល្លារ) សម្រាប់ជម្រើសទី១០ស និង១២៤០កោដិរៀល (២៩៦លានដុល្លារ) សម្រាប់ជម្រើសទី១១ស ដែលត្រូវជា០,៩% ១,៤% និង២,២% នៃផលទុនក្នុងស្រុកសរុប នៅឆ្នាំ២០១២ ទៅតាមកម្មវិធីនីមួយៗ។ ដោយសារចំនួននៃជនចាស់ជរានឹងមានកំណើនឡើងជាបន្តបន្ទាប់ ថវិកាចំណាយសរុបសម្រាប់កម្មវិធីនីមួយៗនឹងមានកំណើនឡើងជាប្រចាំ។ ប៉ុន្តែ ដោយសារកំណើនដោយមាននិរន្តរភាពនៃផលទុនក្នុងស្រុកសរុប ការចំណាយថវិកាសរុបនៅឆ្នាំ២០២០សម្រាប់កម្មវិធីនីមួយៗ អាចធ្លាក់ចុះមកត្រឹម ០,៦% ១,១% និង១,៧% នៃផលទុនក្នុងស្រុកសរុប សម្រាប់ជម្រើសគោលនយោបាយទាំងបី ខាងលើ។

**តារាង ៤.៧ ការនិទស្សន៍ផ្នែកហិរញ្ញប្បទានសម្រាប់ជម្រើសគោលនយោបាយទី៩ស ទី១០ស និង ទី១១ស ៖ របបសោធនសម្រាប់ជនចាស់ជរាទាំងអស់ ជាលក្ខណៈសកល**

| | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ |
|---|---|---|---|---|---|---|---|---|---|
| និទស្សន៍ចំនួនអ្នកទទួលផល | | | | | | | | | |
| ជម្រើសទី៩ | 400 128 | 409 168 | 418 319 | 428 063 | 439 012 | 451 976 | 467 416 | 485 723 | 506 769 |
| ជម្រើសទី១០ | 643 428 | 662 275 | 684 562 | 710 177 | 738 366 | 768 111 | 798 768 | 830 052 | 862 443 |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ជម្រើសទី១១ | 999 381 | 1 034863 | 1 071204 | 1 108961 | 1 149270 | 1 193689 | 1 243130 | 1 298052 | 1 357833 |
| បរិមាណលាភការក្នុងមួយឆ្នាំ (ដុល្លារ/ខែ) | | | | | | | | | |
| ជម្រើសទី៩ | 22.5 | 23.3 | 24.0 | 24.7 | 25.5 | 26.2 | 27.0 | 27.8 | 28.6 |
| ជម្រើសទី១០ | 22.5 | 23.3 | 24.0 | 24.7 | 25.5 | 26.2 | 27.0 | 27.8 | 28.6 |
| ជម្រើសទី១១ | 22.5 | 23.3 | 24.0 | 24.7 | 25.5 | 26.2 | 27.0 | 27.8 | 28.6 |
| ថវិកាចំណាយសរុប (គិតជាកោដិរៀល) ១ | | | | | | | | | |
| ជម្រើសទី៩ | 496.5 | 526.5 | 554.4 | 584.3 | 617.3 | 654.6 | 697.2 | 746.3 | 802.0 |
| ជម្រើសទី១០ | 798.4 | 852.2 | 907.3 | 969.4 | 1 038.2 | 1 112.4 | 1 191.5 | 1 275.3 | 1 364.8 |
| ជម្រើសទី១១ | 1 240.0 | 1 331.6 | 1 419.7 | 1 513.8 | 1 615.9 | 1 728.7 | 1 854.3 | 1 994.3 | 2 148.8 |
| ថវិកាចំណាយសរុប (គិតជាលានដុល្លារ) ១ | | | | | | | | | |
| ជម្រើសទី៩ | 118.6 | 125.8 | 132.5 | 139.6 | 147.5 | 156.4 | 166.6 | 178.3 | 191.6 |
| ជម្រើសទី១០ | 190.8 | 203.6 | 216.8 | 231.6 | 248.1 | 265.8 | 284.7 | 304.7 | 326.1 |
| ជម្រើសទី១១ | 296.3 | 318.2 | 339.2 | 361.7 | 386.1 | 413.1 | 443.1 | 476.5 | 513.4 |
| ការចំណាយថវិកាសម្រាប់កម្មវិធី គិតជា%នៃផលទុនក្នុងស្រុកសរុប | | | | | | | | | |
| ជម្រើសទី៩ | 0.87 | 0.83 | 0.80 | 0.76 | 0.72 | 0.70 | 0.68 | 0.66 | 0.65 |
| ជម្រើសទី១០ | 1.39 | 1.35 | 1.31 | 1.26 | 1.22 | 1.19 | 1.16 | 1.13 | 1.10 |
| ជម្រើសទី១១ | 2.16 | 2.11 | 2.04 | 1.97 | 1.90 | 1.84 | 1.80 | 1.76 | 1.73 |

**កំណត់សម្គាល់:**

១. រួមបញ្ចូលទាំងថវិកាចំណាយរដ្ឋបាល ដែលសន្មតថាស្មើនឹង១០%នៃការចំណាយលើប្រាក់លាភការ

គួរកត់សម្គាល់ដែរថា ដោយសារសមមាត្រនៃជនចាស់ជរានៅកម្ពុជាក្នុងចំនួនប្រជាជនសរុបមានកម្រិតទាប ដោយសារមូលហេតុនៃវិនាសកម្មក្នុងប្រវត្តិសាស្ត្រ ការចំណាយថវិកាសម្រាប់កម្មវិធីរបបសោធននិវត្តន៍ដែលមានលក្ខណៈសកល អាចនឹងមានទំហំតូចជាងការនិទស្សន៍ខាងលើ។ ទោះបីជាការចំណាយថវិកាសម្រាប់កម្មវិធីដែលផ្តល់លាភការជាលក្ខណៈសកល អាចនឹងហួសពីលទ្ធភាពសារពើពន្ធដែលអាចផ្តល់ឲ្យកម្មវិធីនីមួយៗនៅពេលបច្ចុប្បន្ន ក៏កម្មវិធីរបបសោធននិវត្តន៍ដែលផ្តោតគោលដៅលើជនចាស់ជរាក្រីក្រ អាចនឹងស្ថិតក្នុងលទ្ធភាពដែលត្រូវសិក្សាបន្ថែម។

តារាង៤.៨ខាងក្រោម នឹងបង្ហាញពីនិទស្សន៍លើការប៉ាន់ប្រមាណលើការចំណាយថវិកាសម្រាប់ជម្រើសគោលនយោបាយទី១២ និងទី១២ស ស្តីពីរបបសោធនសម្រាប់ជនពិការ។ នៅក្នុងជម្រើសគោលនយោបាយទី១២ ចំនួនជនពិការក្រីក្រអាចមានចំនួនប្រហែល ៤៥០០០នាក់ នៅឆ្នាំ ២០១២ (ឧបសម្ព័ន្ធ៦.៥)។ ចំនួននេះនឹងត្រូវនិទស្សន៍ថាថយចុះមកតិចជាង២៤០០០នាក់នៅឆ្នាំ ២០២០ ដោយសារការធ្លាក់ចុះនៃភាពក្រីក្រ។ ថវិកាចំណាយសរុបសម្រាប់កម្មវិធីរបបសោធនជនពិការក្នុងឆ្នាំ២០១២ គឺស្មើនឹង៥៥,៨កោដិរៀល (១៣,៣លានដុល្លារ) ដែលស្មើនឹង០,១០%នៃផលទុនក្នុងស្រុកសរុប។ យោងទៅលើការធ្វើនិទស្សន៍លើការធ្លាក់ចុះនៃភាពក្រីក្រ និងកំណើនដោយ

មាននិរន្តភាពនៃផលទុនក្នុងស្រុកសរុប ថវិកាចំណាយកម្មវិធីអាចនឹងត្រូវថយចុះមក៣៨កោដិរៀល (៩លានដុល្លារ) ត្រឹម០,០៣%នៃផលទុនក្នុងស្រុកសរុប នៅឆ្នាំ២០២០។

**តារាង ៤.៨ ការនិទស្សន៍ផ្នែកហិរញ្ញប្បទានសម្រាប់ជម្រើសគោលនយោបាយទី១២ និងទី១២ស ៖ របបសោធនសម្រាប់ជនពិការ**

| | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ |
|---|---|---|---|---|---|---|---|---|---|
| និទស្សន៍ចំនួនអ្នកទទួលផល | | | | | | | | | |
| ជម្រើសទី១២ | 44 955 | 42 235 | 39 535 | 36 857 | 34 209 | 31 593 | 29 006 | 26 445 | 23 904 |
| ជម្រើសទី១២ស | 192 538 | 192 538 | 192 538 | 192 538 | 192 538 | 192 538 | 192 538 | 192 538 | 192 538 |
| បរិមាណលាភការក្នុងមួយឆ្នាំ (ដុល្លារ/ខែ) | | | | | | | | | |
| ជម្រើសទី១២ | 22.5 | 23.3 | 24.0 | 24.7 | 25.5 | 26.2 | 27.0 | 27.8 | 28.6 |
| ជម្រើសទី១២ស | 22.5 | 23.3 | 24.0 | 24.7 | 25.5 | 26.2 | 27.0 | 27.8 | 28.6 |
| ថវិកាចំណាយសរុប (គិតជាកោដិរៀល) [១] | | | | | | | | | |
| ជម្រើសទី១២ | 55.8 | 54.3 | 52.4 | 50.3 | 48.1 | 45.8 | 43.3 | 40.6 | 37.8 |
| ជម្រើសទី១២ស | 238.9 | 247.7 | 255.2 | 262.8 | 270.7 | 278.8 | 287.2 | 295.8 | 304.7 |
| ថវិកាចំណាយសរុប (គិតជាលានដុល្លារ) [១] | | | | | | | | | |
| ជម្រើសទី១២ | 13.3 | 13.0 | 12.5 | 12.0 | 11.5 | 10.9 | 10.3 | 9.7 | 9.0 |
| ជម្រើសទី១២ស | 57.1 | 59.2 | 61.0 | 62.8 | 64.7 | 66.6 | 68.6 | 70.7 | 72.8 |
| ការចំណាយថវិកាសម្រាប់កម្មវិធី គិតជា%នៃផលទុនក្នុងស្រុកសរុប | | | | | | | | | |
| ជម្រើសទី១២ | 0.10 | 0.09 | 0.08 | 0.07 | 0.06 | 0.05 | 0.04 | 0.04 | 0.03 |
| ជម្រើសទី១២ស | 0.42 | 0.39 | 0.37 | 0.34 | 0.32 | 0.30 | 0.28 | 0.26 | 0.25 |

**កំណត់សម្គាល់:**

១. រួមបញ្ចូលទាំងថវិកាចំណាយរដ្ឋបាល ដែលសន្មតថាស្មើនឹង១០%នៃការចំណាយលើប្រាក់លាភការ

នៅក្នុងជម្រើសគោលនយោបាយទី១២ស (របបសោធនសម្រាប់ជនពិការដែលមានលក្ខណៈជាសកល) ជនពិការទាំងអស់អាចមានចំនួនប្រហែល១៩២៥០០នាក់ នៅឆ្នាំ២០១២ (ឧបសម្ព័ន្ធ៦.៥)។ ថវិកាចំណាយសរុបសម្រាប់កម្មវិធីរបបសោធនជនពិការក្នុងឆ្នាំ២០១២ គឺស្មើនឹង ២៣៩កោដិរៀល (៥៧លានដុល្លារ) ហើយដែលនឹងអាចកើនឡើងជាលំដាប់រហូតដល់ ៣០៥កោដិរៀល (៧៣លានដុល្លារ) នៅឆ្នាំ២០២០ ប៉ុន្តែថវិកាចំណាយធៀបនឹងផលទុនក្នុងស្រុក សរុបនឹងធ្លាក់ចុះពី០,៤២%នៅឆ្នាំ២០១២ មក០,២៥%នៃផលទុនក្នុងស្រុកសរុប នៅឆ្នាំ២០២០។

គួរកត់សម្គាល់ដែរថា ចំនួនជនពិការដែលបង្ហាញខាងលើអាចមានចំនួនទាប ប្រសិនបើធៀបទៅនឹងបទដ្ឋានអន្តរជាតិ ដែលប្រការនេះបណ្តាលមកពីការប្រើប្រាស់និយមន័យស្តីពីពិការ

ភាពក្នុងន័យចង្អៀត[3]។ ការចំណាយថវិកាលើកម្មវិធីរបបសោធនសម្រាប់ជនពិការ នឹងពឹងផ្អែកទាំងស្រុងលើលក្ខខណ្ឌវាយតម្លៃ ដែលនឹងត្រូវកំណត់ក្នុងកម្មវិធី ពិសេសការពិចារណាលើការបាត់បង់ផ្នែកណាមួយនៃសមត្ថភាពពលកម្ម ដែលអាចជាលក្ខខណ្ឌសម្រាប់ទទួលលាភការពីកម្មវិធី។ ការវាយតម្លៃស៊ីជម្រៅបន្ថែមទៀត ស្តីពីបញ្ហាពាក់ព័ន្ធនឹងពិការភាព គឺស្ថិតនៅក្រៅវិសាលភាពនៃរបាយការណ៍នេះ។

[3] ផ្តោតខ្លាំងទៅលើការបាត់បង់សម្បទារូបសាស្ត្រ

# ជំពូក៥

# សេចក្តីសន្និដ្ឋាន និងសង្ខេប

គោលដៅនៃការវាយតម្លៃដែលបង្ហាញនៅក្នុងឯកសារនេះ គឺដើម្បីធ្វើការប៉ាន់ប្រមាណជាបឋមទៅលើតម្រូវការថវិកាចំណាយសម្រាប់ការអនុវត្តបណ្តាកម្មវិធីគាំពារសង្គមអាទិភាព ដែលបានលើកឡើងនៅក្នុង**យ.ជ.គ.ស**។ ឯកសារនេះបានលើកឡើងពីជម្រើសគោលនយោបាយសម្រាប់គោលដៅយុទ្ធសាស្ត្រនីមួយៗនៃ**យ.ជ.គ.ស** និងការប៉ាន់ប្រមាណលើថវិកាចំណាយក្នុងអំឡុងពេល ២០១២-២០២០។ គោលដៅនៃការធ្វើការប៉ាន់ប្រមាណលើថវិកាចំណាយ គឺដើម្បីបង្ហាញពីផលប៉ះពាល់នៃការរៀបចំកម្មវិធីនៅលើតម្រូវការធនធាន ដែលដូច្នេះនឹងចូលរួមដល់ការគាំទ្រដល់ដំណើរការរៀបចំគោលនយោបាយ។

គួរកត់សម្គាល់ដែរថា កម្មវិធីមួយចំនួនដែលបានលើកឡើង មានលក្ខណៈជាការបំពេញបន្ថែម ហើយកម្មវិធីខ្លះទៀតមានលក្ខណៈត្រួតជាន់គ្នា ឬផ្តល់ជាជម្រើសឲ្យគ្នាទៅវិញទៅមក។ ក្នុងករណីដែលកម្មវិធីទាំងនេះត្រូវអនុវត្តក្នុងពេលដំណាលគ្នា ប្រការចាំបាច់គឺត្រូវពិចារណាលើលទ្ធភាពនៃការត្រួតជាន់គ្នា និងការកែសម្រួលលើការផ្តល់លាភការសម្រាប់កម្មវិធីនីមួយៗ (ឧទាហរណ៍ រវាងរបបសោធនវិវត្តន៍សម្រាប់ជនចាស់ជរា និងជនពិការ)។ បន្ថែមលើនេះទៀត ក្នុងករណីដែលកម្មវិធីទាំងអស់ត្រូវអនុវត្តព្រមពេលជាមួយគ្នា កំណើននៃឥទ្ធិពលផ្នែកសុខមាលភាពទៅលើគ្រួសារក៏ជាប្រការដែលត្រូវពិចារណាបន្ថែមទៀត។ ការវាយតម្លៃបន្តទៀត ជាកិច្ចការដែលចាំបាច់ដើម្បីសិក្សាលើឥទ្ធិពលទៅលើគ្នាទៅវិញទៅមករវាងអន្តរាគមន៍គាំពារសង្គមផ្សេងៗគ្នា នៃឧបករណ៍ក្នុងគោលនយោបាយខុសៗគ្នា។

ជំពូកនេះនឹងបង្ហាញដោយសង្ខេប លើកាវាយតម្លៃផ្នែកហិរញ្ញប្បទានដែលបានវិភាគក្នុងជំពូកមុន។ ការបង្ហាញនេះនឹងញែកចែកដាច់គ្នានូវអន្តរាគមន៍បីប្រភេទរួមមាន៖

- កម្មវិធីដែលផ្តោតគោលដៅទៅលើជនក្រីក្រគ្រប់រូប
- កម្មវិធីដែលផ្តោតគោលដៅទៅលើក្រុមជនងាយរងគ្រោះមួយចំនួន ពីក្នុងជនក្រីក្រ
- កម្មវិធីដែលផ្តោតគោលដៅទៅលើក្រុមជនងាយរងគ្រោះមួយចំនួន ពីក្នុងចំណោមប្រជាជនគ្រប់រូប

### ៥.១ ការឧបត្ថម្ភសាច់ប្រាក់សម្រាប់ជនក្រីក្រគ្រប់រូប

ជម្រើសគោលនយោបាយទី១ និងទី២ បានលើកឡើងពីការឧបត្ថម្ភសាច់ប្រាក់សម្រាប់ប្រជាជនក្រីក្រគ្រប់រូប ក្នុងគោលដៅផ្តល់សន្តិសុខស្បៀង និងការទទួលបានតម្រូវការមូលដ្ឋានរបស់ជនក្រីក្រ។ ទោះបីភាពក្រីក្រនៅកម្ពុជាកំពុងមាននិន្នាការធ្លាក់ចុះក៏ដោយ ក៏ប្រជាជនកម្ពុជាប្រមាណ ៣,៤លាននាក់កំពុងរស់នៅក្រោមបន្ទាត់នៃភាពក្រីក្រ ហើយដែលក្នុងនោះប្រជាជនប្រមាណ១,៩ លាននាក់ ជាប្រជាជនក្រីក្របំផុត។ រូបភាព៥.១ បង្ហាញពីការនិទស្សន៍លើការប៉ាន់ប្រមាណថវិកាចំណាយសម្រាប់កម្មវិធីទាំងពីរនេះ ដែលមានទំហំធំក្នុងដំណាក់កាលខ្លីនិងមធ្យម។ ទោះជាយ៉ាងណា ប្រសិនបើប្រៀបធៀបទៅនឹងផលទុនក្នុងស្រុកសរុប ថវិកាចំណាយសម្រាប់កម្មវិធីទាំងពីរនេះនឹងធ្លាក់ចុះយ៉ាងឆាប់រហ័ស ហើយកម្មវិធីកម្រិតជាតិដែលផ្តោតគោលដៅលើជនក្រីក្របំផុត(ជម្រើសគោលនយោបាយទី១) អាចជាលទ្ធភាពដែលអាចធ្វើទៅបាន នៅមុនបំណាច់ទសវត្សរ៍នេះ។ រហូតដល់ពេលដែលលទ្ធភាពនេះអាចធ្វើទៅបាន ប្រភេទកម្មវិធីដែលផ្តោតគោលដៅទៅលើក្រុមប្រជាជនជាក់លាក់មួយចំនួន (ជម្រើសគោលនយោបាយទី៣-១២) គឺជាជម្រើសសមស្រប ហើយបណ្តាអន្តរាគមន៍គាំពារសង្គមដែលមានគោលដៅផ្តល់សន្តិសុខស្បៀងដល់ជនក្រីក្រ គួរបន្តរក្សានិងពង្រីកបន្ថែមតាមដែលអាចធ្វើទៅបាន។ ការសិក្សាលើលទ្ធផលដែលអាចធ្វើបាននៃកម្មវិធីជាតិមួយដែលមានលក្ខណៈស៊ីជម្រៅសម្រាប់ជនក្រីក្រគ្រប់រូប នឹងត្រូវពឹងផ្អែកលើគន្លងនៃការធ្លាក់ចុះនៃភាពក្រីក្រ និងគន្លងនៃកំណើនសេដ្ឋកិច្ច ដែលអាចនឹងកើតមានឡើងក្នុងទសវត្សរ៍នេះ។

**រូបភាព ៥.១ កម្មវិធីឧបត្ថម្ភសាច់ប្រាក់ដល់ជនក្រីក្រ ៖ និទស្សន៍ថវិកាចំណាយសម្រាប់ឆ្នាំ២០១២-២០២០ (គិតជាភាគរយនៃផលក្នុងស្រុកជាតិសរុប)**



## ៥.២ កម្មវិធីផ្តោតទៅលើក្រុមជនងាយរងគ្រោះក្នុងចំណោមជនក្រីក្រ

ការប៉ាន់ប្រមាណលើថវិកាចំណាយ សម្រាប់កម្មវិធីដែលផ្តោតគោលដៅលើក្រុមជនងាយរងគ្រោះជាក់លាក់ក្នុងចំណោមជនក្រីក្រ (ជម្រើសគោលនយោបាយទី៣-១២) មានបង្ហាញក្នុងរូបភាព៥.២។ សម្រាប់ឆ្នាំ២០១២ ថវិកាចំណាយសម្រាប់កម្មវិធីទាំងនេះអាចស្ថិតក្នុងចន្លោះ ០,១ទៅ០,៥%នៃផលទុនក្នុងស្រុកសរុប។ សម្រាប់កម្មវិធីដែលផ្តោតគោលដៅលើក្រុមជនងាយរងគ្រោះដែលមានចំនួនតិច ថវិកាចំណាយអាចប្រហែលនឹង០,១ភាគរយនៃផលទុនក្នុងស្រុកសរុប រួមមានកម្មវិធីដែលផ្តោតគោលដៅលើស្ត្រីក្រីក្រមានផ្ទៃពោះ (ជម្រើសគោលនយោបាយទី៣) ជនចាស់ជរាអាយុលើសពី៧០ឆ្នាំដែលក្រីក្របំផុត (ជម្រើសគោលនយោបាយទី៩) និងសម្រាប់ជនពិការ (ជម្រើសគោលនយោបាយទី១២)។ ចំណែកកម្មវិធីទីពីរឬ ដែលមានគោលដៅដោះស្រាយភាពងាយរងគ្រោះរបស់ក្រុមជនងាយរងគ្រោះដែលមានចំនួនច្រើនក្នុងចំណោមជនក្រីក្រ រួមមានក្រុមកុមារក្រីក្រដែលពេញវ័យចូលរៀន (ជម្រើសគោលនយោបាយទី៥) និងជនចាស់ជរាក្រីក្រដែលមានអាយុលើសពី៦០ឆ្នាំ (ជម្រើសគោលនយោបាយទី១១) ថវិកាចំណាយអាចនឹងប្រហែល ០,៥%នៃផលទុនជាតិសរុប សម្រាប់ឆ្នាំ២០១២។ នៅឆ្នាំ២០២០ ថវិកាចំណាយទាំងអស់នឹងត្រូវធ្លាក់មកទាបជាង០,២%នៃផលទុនក្នុងស្រុកសរុប។

**រូបភាព៥.២ កម្មវិធីដែលផ្តោតទៅលើក្រុមជនងាយរងគ្រោះ ក្នុងចំណោមជនក្រីក្រ៖ និទស្សន៍លើថវិកាចំណាយសម្រាប់ឆ្នាំ២០១៣-២០២០ (គិតជាភាគរយនៃផលទុនជាតិសរុប)**



## ៥.៣ កម្មវិធីដែលផ្តល់លាភការជាសកលសម្រាប់ប្រជាជនគ្រប់គ្នា

រូបភាព៥.៣ បង្ហាញពីការនិទស្សន៍ថវិកាចំណាយសម្រាប់កម្មវិធីដែលផ្តល់លាភការជាសកលសម្រាប់ប្រជាជនគ្រប់គ្នា។ ប្រសិនបើធៀបទៅនឹងផលទុនក្នុងស្រុកសរុប ថវិកាចំណាយសម្រាប់កម្មវិធីទាំងអស់នឹងធ្លាក់ចុះជាបណ្តើរៗជារៀងរាល់ឆ្នាំ។ សម្រាប់កម្មវិធីដែលផ្តោតលើស្ត្រីមានផ្ទៃពោះនិងកុមារ (ជម្រើសគោលនយោបាយទី៣ស, ៤ស, និង៥ស) ការធ្លាក់ចុះនៃថវិកាចំណាយនេះគឺភាគច្រើនបណ្តាលមកពីនិន្នាការនៃការធ្លាក់ចុះនៃអត្រាកំណើតទារក និងអត្រាភាពពឹងផ្អែករបស់ទារក ក្នុងអំឡុងឆ្នាំនិទស្សន៍។

សម្រាប់កម្មវិធីរបបសោធននិវត្តន៍សម្រាប់ជនចាស់ជរាគ្រប់រូប (ជម្រើសគោលនយោបាយទី៩ស, ១០ស, និង១១ស) គន្លងនៃការធ្លាក់ចុះនៃថវិកាចំណាយមានល្បឿនយឺតបើធៀបទៅនឹងកម្មវិធីដទៃ។ ក្នុងខណៈពេលដែលភាពជរានៃប្រជាជននឹងកើតមានឡើង អត្រានៃភាពពឹងផ្អែកនៃអាយុក៏នឹងនិទស្សន៍ថានឹងកើនឡើង សម្រាប់អាយុចូលនិវត្តន៍ទាំងបីគឺ ៧០, ៦៥ និង៦០ឆ្នាំ។ ទោះបីជាចំនួននិវត្តជនចាស់ជរានឹងមានចំនួនកើនឡើង ហើយដែលធ្វើឲ្យបរិមាណពិតប្រាកដនៃថវិកាចំណាយត្រូវកើនឡើង ផលធៀបទៅនឹងផលទុនក្នុងស្រុកសរុបនៅតែធ្លាក់ចុះ សម្រាប់កម្មវិធីរបបសោធននិវត្តន៍ទាំងបី ស្របទៅតាមការធ្វើសន្មត្សន៍កម្មលើសន្ទស្សន៍ថ្លៃទំនិញរបស់អ្នកប្រើប្រាស់ទៅលើលាភការនៃរបបសោធនវិវត្តន៍។ ថវិកាចំណាយលើកម្មវិធីរបបសោធននិវត្តន៍សម្រាប់ជនពិការគ្រប់រូបធៀបនឹងផលទុនក្នុងស្រុកសរុប នឹងនិទស្សន៍ថាធ្លាក់ចុះក្នុងគន្លងយឺត ក្នុងកិច្ចសន្មតថាអត្រាពិការភាពក្នុងអំឡុងឆ្នាំ២០១២-២០២០ នឹងស្ថិតនៅថេរ។

**រូបភាព៥.៣ លាភការជាលក្ខណៈសកល**



## ៥.៤ សេចក្ដីសន្និដ្ឋាន

ការធ្វើនិទស្សន៍ផ្នែកហិរញ្ញប្បទានក្នុងឯកសារនេះ បានបង្ហាញថាគំហើញថ្មីមួយដែលកើតឡើងនៅដំណាក់កាលខ្លីនិងមធ្យមខាងមុខនេះ ក្នុងការពង្រីកការគាំពារសង្គមនៅកម្ពុជា។ ស្របជាមួយនឹងនិន្នាការនៃការធ្លាក់ចុះនៃអត្រាឧប្បត្តិហេតុនៃភាពក្រីក្រ និងកំណើននៃប្រាក់ចំណូលជាតិ ការធ្វើនិទស្សន៍នេះបានបង្ហាញពីលទ្ធភាពជាក់ស្តែងមួយចំនួន ក្នុងការបើកច្រកឲ្យមានការអនុវត្តកម្មវិធីគាំពារសង្គម ពិសេសកម្មវិធីដែលផ្តោតលើជនក្រីក្រ និងទាមទារឲ្យមានសេចក្តីតាំងចិត្តរួមគ្នារវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍក្នុងការកំណត់ថវិកានិងធនធាន។

លទ្ធភាពផ្នែកហិរញ្ញប្បទានដែលនៅមានកម្រិតគឺនៅតែជាឧបសគ្គមួយ ដែលរារាំងដល់វិសាលភាពនៃអន្តរាគមន៍គាំពារសង្គមឲ្យស្ថិតនៅក្នុងកម្រិតមូលដ្ឋាន ហើយដែលត្រូវអនុវត្តទន្ទឹមគ្នាជាមួយនឹងកម្មវិធីផ្សេងៗដែលឧបត្ថម្ភដោយដៃគូអភិវឌ្ឍ។ នៅពេលដែលមានកំណើននៃប្រាក់ចំណូលជាតិ លទ្ធភាពផ្នែកហិរញ្ញប្បទាននឹងកើនឡើង ហើយផ្តល់ជាមធ្យោបាយឲ្យមានកម្មវិធីជាតិថ្មីៗ និងការពង្រីកវិសាលភាពកម្មវិធីដែលមានស្រាប់។ យុទ្ធសាស្ត្រជាតិគាំពារសង្គមនឹងផ្តល់ជាក្របខណ្ឌយុទ្ធសាស្ត្រដែលតម្រង់ទិសដល់ជម្រើស និងការរៀបចំបង្កើតកម្មវិធីគាំពារសង្គមថ្មីៗ នៅពេលដែលមានលទ្ធភាពផ្នែកធនធាន។ ក្នុងដំណាក់កាលដែលហិរញ្ញប្បទាននៅតែជាកត្តាឧបសគ្គ ប្រការសំខាន់បំផុតគឺការអនុវត្ត អភិក្រមជាជំហានៗ ដោយចាប់ផ្តើមពីកម្មវិធីដែលមានអាទិភាពបំផុត។ ដើម្បីធានានិរន្តរភាពផ្នែកហិរញ្ញប្បទាន ការកំណត់អាទិភាពកម្មវិធីនិងការរៀបចំលំដាប់លំដោយនៃការអនុវត្តជាប្រការចាំបាច់បំផុត។

### តារាង៥.១ តារាងសង្ខេបស្តីពីជម្រើសគោលនយោបាយនិងលទ្ធផលនៃការនិទស្សន៍

| ជម្រើស | កម្មវិធី | ទំហំលាភការ | ប្រភេទកម្មវិធី | | អ្នកទទួលផល ឆ្នាំ២០១២ | ថវិកាចំណាយ ឆ្នាំ២០១២ | ការចំណាយធៀបនឹងផលទុនក្នុងស្រុកសរុប | | |
|---|---|---|---|---|---|---|---|---|---|
| | | | គោលដៅ | សកល | លាននាក់ | លានដុល្លារ | ២០១២ | ២០១៦ | ២០២០ |
| ១ | ការឧបត្ថម្ភសាច់ប្រាក់សម្រាប់ជនក្រីក្របំផុត (ក្រីក្រកម្រិត១) | 60% នៃប.ក.ស.ជ | X | | 1.94 | 342.8 | 2.50 | 1.43 | 0.68 |
| ២ | ការឧបត្ថម្ភសាច់ប្រាក់សម្រាប់ជនក្រីក្រទាំងអស់ (ក្រីក្រកម្រិត១ និង២) | 40/80% នៃប.ក.ស.ជ | X | | 3.45 | 638.2 | 4.66 | 2.82 | 1.53 |
| ៣ | ការឧបត្ថម្ភសាច់ប្រាក់សម្រាប់ស្ត្រីក្រីក្រមានផ្ទៃពោះ | 80% នៃប.ក.ស.ជ | X | | 0.08 | 10.0 | 0.07 | 0.04 | 0.02 |
| ៣ស | ការឧបត្ថម្ភសាច់ប្រាក់សម្រាប់ស្ត្រីមានផ្ទៃពោះទាំងអស់ | 80% នៃប.ក.ស.ជ | | X | 0.33 | 39.1 | 0.29 | 0.22 | 0.16 |
| ៤ | ការឧបត្ថម្ភសាច់ប្រាក់សម្រាប់កុមារក្រីក្រ អាយុ០ដល់២ឆ្នាំ | 60% នៃប.ក.ស.ជ | X | | 0.27 | 47.1 | 0.34 | 0.20 | 0.10 |
| ៤ស | ការឧបត្ថម្ភសាច់ប្រាក់សម្រាប់កុមារទាំងអស់ អាយុ០ដល់២ឆ្នាំ | 60% នៃប.ក.ស.ជ | | X | 1.00 | 176.4 | 1.29 | 0.97 | 0.73 |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ៥ | ការឧបត្ថម្ភសាច់ប្រាក់សម្រាប់កុមារក្រីក្រអាយុចូលរៀនបឋមសិក្សា | 60% នៃប.ក.ស.ជ | X | | 0.42 | 73.9 | 0.54 | 0.32 | 0.19 |
| ៥ស | ការឧបត្ថម្ភសាច់ប្រាក់សម្រាប់កុមារទាំងអស់ អាយុចូលរៀនបឋមសិក្សា | 60% នៃប.ក.ស.ជ | | X | 1.70 | 300.1 | 2.19 | 1.70 | 1.44 |
| ៦ | កម្មវិធីជាតិសំណង់សាធារណៈសម្រាប់គ្រួសារក្រីក្របំផុត | 10000 រៀល/ថ្ងៃ ឆ្នាំ២០១២ | X | | 0.04 | 16.1 | 0.12 | 0.07 | 0.04 |
| ៧ | កម្មវិធីជាតិសំណង់សាធារណៈសម្រាប់គ្រួសារក្រីក្រ | 10000 រៀល/ថ្ងៃ ឆ្នាំ២០១២ | X | | 0.08 | 28.7 | 0.21 | 0.14 | 0.09 |
| ៨ | ការពង្រីកវិសាលភាពមូលនិធិសមធម៌សុខភាពសម្រាប់ជនក្រីក្រ | ព្យាបាល ថែទាំ និងរបបជាប្រាក់ | X | | 3.45 | 13.7 | 0.10 | 0.09 | 0.06 |
| ៩ | របបសោធននិវត្តន៍សម្រាប់ជនចាស់ជរាក្រីក្រ អាយុលើសពី៧០ឆ្នាំ | 60% នៃប.ក.ស.ជ | X | | 0.06 | 19.2 | 0.14 | 0.08 | 0.04 |
| ៩ស | របបសោធននិវត្តន៍សម្រាប់ជនចាស់ជរាទាំងអស់ អាយុលើសពី៧០ឆ្នាំ | 100% នៃប.ក.ស.ជ | | X | 0.40 | 118.6 | 0.87 | 0.72 | 0.65 |
| ១០ | របបសោធននិវត្តន៍សម្រាប់ជនចាស់ជរាក្រីក្រ អាយុលើសពី៦៥ឆ្នាំ | 100% នៃប.ក.ស.ជ | X | | 0.16 | 46.6 | 0.34 | 0.23 | 0.14 |
| ១០ស | របបសោធននិវត្តន៍សម្រាប់ជនចាស់ជរាទាំងអស់ អាយុលើសពី៦៥ឆ្នាំ | 100% នៃប.ក.ស.ជ | | X | 0.64 | 190.8 | 1.39 | 1.22 | 1.10 |
| ១១ | របបសោធននិវត្តន៍សម្រាប់ជនចាស់ជរាក្រីក្រ អាយុលើសពី៦០ឆ្នាំ | 100% នៃប.ក.ស.ជ | X | | 0.23 | 68.1 | 0.50 | 0.33 | 0.21 |
| ១១ស | របបសោធននិវត្តន៍សម្រាប់ជនចាស់ជរាទាំងអស់ អាយុលើសពី៦០ឆ្នាំ | 100% នៃប.ក.ស.ជ | | X | 1.00 | 296.3 | 2.16 | 1.90 | 1.73 |
| ១២ | របបសោធននិវត្តន៍សម្រាប់ជនពិការក្រីក្រ | 100% នៃប.ក.ស.ជ | X | | 0.04 | 13.3 | 0.10 | 0.06 | 0.03 |
| ១២ស | របបសោធននិវត្តន៍សម្រាប់ជនពិការទាំងអស់ | 100% នៃប.ក.ស.ជ | | X | 0.19 | 57.1 | 0.42 | 0.32 | 0.25 |

**កំណត់សម្គាល់:**

១. ដោយសន្មតថាកម្មវិធីទាំងអស់ត្រូវចាប់អនុវត្តនៅថ្ងៃទី១ ខែមករា ឆ្នាំ២០១២

ប.ក.ស.ជ ៖ បន្ទាត់នៃភាពក្រីក្រផ្នែកស្បៀងអាហារនៅតំបន់ជនបទ

# ឧបសម្ព័ន្ធ

# ក្របខណ្ឌនៃម៉ូដែល និងការសន្មត

## ៦. ប្រជាករ

ទិន្នន័យប្រជាករដែលប្រើប្រាស់នៅក្នុងឯកសារនេះ ជាការកែសម្រួលទៅតាមទិន្នន័យជំរឿនប្រជាជនថ្នាក់ជាតិនៅឆ្នាំ២០០៨ និងការនិទស្សន៍ដែលពាក់ព័ន្ធផ្សេងៗទៀត (NIS, 2011)។ យោងទៅតាមទិន្នន័យកែសម្រួលនេះ ចំនួនប្រជាជនសរុបនៅពាក់កណ្ដាលឆ្នាំ២០០៨ គឺមានចំនួន ១៣៨៦៨២២៧នាក់។ ចំនួនប្រជាជនសរុបនៅឆ្នាំ២០១២ គឺអាចមាន១៥លាននាក់ ហើយដែលអាចកើនឡើងដល់១៦,៧លាននាក់ នៅឆ្នាំ២០២០ (តារាង ៦.១)

**តារាង៦.១ ទិន្នន័យប្រជាករ ៖ ចំនួនសរុប និងចំនួនទៅតាមក្រុមអាយុ ដែលនិទស្សន៍សម្រាប់ ២០១២-២០២០**

| គិតជាពាន់នាក់ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ |
|---|---|---|---|---|---|---|---|---|---|
| សរុប | **14 963** | **15 184** | **15 405** | **15 626** | **15 848** | **16 070** | **16 289** | **16 505** | **16 717** |
| បុរស | 7 204 | 7 320 | 7 436 | 7 552 | 7 668 | 7 784 | 7 900 | 8 015 | 8 127 |
| ស្ត្រី | 7 537 | 7 642 | 7 748 | 7 853 | 7 959 | 8 065 | 8 170 | 8 275 | 8 378 |
| ក្រុមអាយុជ្រើសរើស | | | | | | | | | |
| ០–២ [១] | 999 | 987 | 986 | 984 | 982 | 980 | 976 | 971 | 965 |
| ៦–១១ [១] | 1 699 | 1 694 | 1 668 | 1 677 | 1 729 | 1 779 | 1 820 | 1 856 | 1 896 |
| លើសពី៦៥ឆ្នាំ | 382 | 393 | 406 | 421 | 438 | 456 | 476 | 496 | 518 |
| លើសពី៧០ឆ្នាំ | 241 | 246 | 251 | 256 | 263 | 271 | 280 | 291 | 303 |

**ប្រភព:** NIS (២០១១)

## ៦.២ កម្លាំងពលកម្ម និងការងារ

កម្លាំងពលកម្ម ត្រូវបានគណនាតាមទិន្នន័យនិទស្សន៍លើចំនួនប្រជាជន (តារាង៦.១) និងទិន្នន័យ**អត្រានៃការចូលរួមក្នុងកម្លាំងពលកម្ម** ទៅតាមក្រុមអាយុ ដែលបង្ហាញនៅក្នុងលទ្ធផលជំរឿនឆ្នាំ២០០៨ (NIS, ២០០៩) ហើយដែលត្រូវសន្មតថានៅថេរក្នុងអំឡុងពេលនៃការធ្វើនិទស្សន៍។ តារាង៦.២ ខាងក្រោម បង្ហាញពីចំនួនការងារសរុបក្នុងអំឡុងឆ្នាំ ២០១២-២០២០ ដោយសន្មតថា **អត្រានិកម្មភាព** ត្រូវស្ថិតនៅថេរ ស្មើនឹង១,៦ %។

តារាង ៦.២ ទិន្នន័យអត្រាចូលរួមក្នុងទីផ្សារការងារ និងនិកម្មភាព និទស្សន៍សម្រាប់ឆ្នាំ ២០១២-២០២០

| | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ |
|---|---|---|---|---|---|---|---|---|---|
| អត្រាចូលរួមក្នុងទីផ្សារពលកម្ម(%) | 78.9 | 79.2 | 79.5 | 79.8 | 80.2 | 80.5 | 80.8 | 81.1 | 81.3 |
| បុរស | 81.7 | 82.1 | 82.5 | 82.9 | 83.4 | 83.9 | 84.4 | 84.8 | 85.2 |
| ស្ត្រី | 76.4 | 76.6 | 76.7 | 76.9 | 77.1 | 77.3 | 77.5 | 77.6 | 77.7 |
| កម្លាំងពលកម្ម អាយុពី១៥ឆ្នាំឡើង (គិតជាពាន់នាក់) | **8 066** | **8 283** | **8 495** | **8 703** | **8 905** | **9 099** | **9 285** | **9 462** | **9 631** |
| បុរស | 3 999 | 4 122 | 4 242 | 4 361 | 4 478 | 4 590 | 4 698 | 4 802 | 4 901 |
| ស្ត្រី | 4 067 | 4 161 | 4 252 | 4 341 | 4 427 | 4 509 | 4 587 | 4 660 | 4 729 |
| អត្រានិកម្មភាព អាយុពី១៥ឆ្នាំឡើង | **1.6** | **1.6** | **1.6** | **1.6** | **1.6** | **1.6** | **1.6** | **1.6** | **1.6** |
| បុរស | 1.5 | 1.5 | 1.5 | 1.5 | 1.5 | 1.5 | 1.5 | 1.5 | 1.5 |
| ស្ត្រី | 1.8 | 1.8 | 1.8 | 1.8 | 1.8 | 1.8 | 1.8 | 1.8 | 1.8 |
| អ្នកមានការងារធ្វើ អាយុពី១៥ឆ្នាំឡើង(គិតជាពាន់នាក់) | **7 934** | **8 147** | **8 356** | **8 560** | **8 759** | **8 950** | **9 133** | **9 307** | **9 473** |
| បុរស | 3 940 | 4 060 | 4 179 | 4 296 | 4 411 | 4 522 | 4 628 | 4 730 | 4 828 |
| ស្ត្រី | 3 994 | 4 086 | 4 176 | 4 263 | 4 348 | 4 428 | 4 505 | 4 576 | 4 644 |

**ប្រភព:** ការគណនានិទស្សន៍របស់អ្នកនិពន្ធដោយផ្អែកលើទិន្នន័យជំរឿន (NIS, ២០០៩)

កម្លាំងពលកម្មសរុប នឹងនិទស្សន៍ថាមានកំណើនពី៨លានទៅ៩,៦លាននាក់ នៅក្នុងឆ្នាំ២០២០។ ដោយសន្មតថាអត្រានិកម្មភាពនឹងនៅថេរ ចំនួនអ្នកមានការងារធ្វើសរុប នឹងកើនពី ៧,៩លាននៅឆ្នាំ២០១២ដល់៩,៥ លាន នៅឆ្នាំ២០២០។

## ៦.៣ ផលក្នុងស្រុកសរុប ថ្លៃទំនិញ និងប្រាក់កម្រៃការងារ

ការធ្វើនិទស្សន៍ទៅលើផលទុនក្នុងស្រុកសរុបជាតម្រូវការចាំបាច់មួយ ដើម្បីដើរតួនាទីជាចំនុចគោល ក្នុងការប្រៀបធៀបទៅនឹងការចំណាយថវិកាលើកម្មវិធីគាំពារសង្គមនីមួយៗ ទៅនឹងទិន្នផលនៃកម្មវិធីនៅកម្រិតថ្នាក់ជាតិ។ សម្រាប់ឆ្នាំ២០១២-២០១៦ ទិន្នន័យផលទុនក្នុងស្រុកសរុប ត្រូវផ្អែកលើការធ្វើនិទស្សន៍របស់**ស្ថាប័នមូលនិធិរូបិយវត្ថុអន្តរជាតិ** (IMF) នៅឆ្នាំ២០១១ (IMF, ២០១២)។ សម្រាប់ឆ្នាំបន្តបន្ទាប់ ទិន្នន័យផលទុនក្នុងស្រុកសរុបនឹងត្រូវគណនាចេញពីចំនួនការងារសរុប និងតម្លៃបន្ថែមក្នុងមួយឯកតាការងារ ដោយសន្មតថាកំណើននៃតម្លៃបន្ថែម ក្នុងការងារមួយគឺនឹងស្ថិតនៅថេរ ហើយស្មើនឹង៤,៥%ក្នុងមួយឆ្នាំ ក្នុងអំឡុងឆ្នាំ ២០១៧-២០២ (តារាង ៦.៣)។

**តារាង ៦.៣ ផលទុនជាតិសរុប និងនិទស្សន៍សម្រាប់ឆ្នាំ ២០១២-២០២០**

| | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ |
|---|---|---|---|---|---|---|---|---|---|
| ផលទុនក្នុងស្រុកសរុបក្នុងថ្លៃបច្ចុប្បន្ន (កោដិរៀល) | 57 370 | 63 057 | 69 495 | 76 928 | 85 179 | 93 759 | 103 056 | 113 120 | 124 028 |
| ការប្រែប្រួល (%ក្នុង១ឆ្នាំ) | 10.6 | 9.9 | 10.2 | 10.7 | 10.7 | 10.1 | 9.9 | 9.8 | 9.6 |
| Deflator នៃផលទុនក្នុងស្រុក | 8 066 | 8 283 | 8 495 | 8 703 | 8 905 | 9 099 | 9 285 | 9 462 | 9 631 |
| ការប្រែប្រួល (%ក្នុង១ឆ្នាំ) | 3.8 | 3.3 | 3.2 | 3.1 | 3.1 | 3.1 | 3.1 | 3.1 | 3.1 |
| ផលទុនក្នុងស្រុក nominal ក្នុងអ្នកមានការងារធ្វើម្នាក់ (លានរៀល) | 7.231 | 7.740 | 8.318 | 8.987 | 9.725 | 10.476 | 11.285 | 12.156 | 13.094 |
| ការប្រែប្រួល (%ក្នុង១ឆ្នាំ) | 7.6 | 7.0 | 7.5 | 8.1 | 8.2 | 7.7 | 7.7 | 7.7 | 7.7 |
| ការប្រែប្រួលក្នុងអត្រាពិត (%ក្នុង១ឆ្នាំ) | 3.6 | 3.6 | 4.2 | 4.8 | 5.0 | 4.5 | 4.5 | 4.5 | 4.5 |

**ប្រភព** : IMF, និងការគណនាបន្ថែមដោយអ្នកនិពន្ធ

ការវិវត្តនៅពេលអនាគតនៃថ្លៃទំនិញនិងប្រាក់កម្រៃ ជាកត្តាដ៏មានសារៈសំខាន់ដូចគ្នា ដើម្បីធ្វើនិទស្សន៍ទៅលើថវិកាចំណាយសម្រាប់កម្មវិធីគាំពារសង្គមផ្សេងៗគ្នា។ ការនិទស្សន៍ទៅលើការវិវត្តនៃសន្ទស្សន៍ថ្លៃទំនិញសម្រាប់អ្នកប្រើប្រាស់ គឺផ្អែកលើទិន្នន័យថ្មីៗរបស់ស្ថាប័នមូលនិធិរូបិយវត្ថុអន្តរជាតិ នៅឆ្នាំ២០១១ (តារាង ៦.៤)។ សម្រាប់ការវិវត្តនៃប្រាក់កម្រៃវិញ កម្រិតប្រាក់កម្រៃពិតប្រាកដថ្នាក់ជាតិគិតជាមធ្យម ត្រូវសន្មតថាស្មើនឹងពាក់កណ្តាល (៥០%) នៃកំណើននៃអត្រាប្រចាំឆ្នាំរបស់កំណើនផលិតភាពពលកម្ម[4]។

**តារាង ៦.៤ សន្ទស្សន៍ថ្លៃទំនិញរបស់អ្នកប្រើប្រាស់និងសន្ទស្សន៍អតិផរណា នៃប្រាក់កម្រៃ និទស្សន៍ សម្រាប់ឆ្នាំ ២០១២-២០២០**

| | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ |
|---|---|---|---|---|---|---|---|---|---|
| សន្ទស្សន៍ថ្លៃទំនិញរបស់អ្នកប្រើប្រាស់ | | | | | | | | | |
| ការប្រែប្រួល (%ក្នុង១ឆ្នាំ) [១] | 4.3 | 3.7 | 3.0 | 3.0 | 3.0 | 3.0 | 3.0 | 3.0 | 3.0 |
| សន្ទស្សន៍ប្រាក់កម្រៃ | | | | | | | | | |
| ការប្រែប្រួលក្នុងអត្រាពិត (%ក្នុង១ឆ្នាំ) | 1.8 | 1.8 | 2.1 | 2.4 | 2.5 | 2.3 | 2.3 | 2.3 | 2.3 |
| ការប្រែប្រួលក្នុងអត្រា nominal (%ក្នុង១ឆ្នាំ | 6.2 | 5.6 | 5.1 | 5.5 | 5.6 | 5.3 | 5.3 | 5.3 | 5.3 |

**ប្រភព** : IMF, និងការគណនាបន្ថែមដោយអ្នកនិពន្ធ

**កំណត់ចំណាំ** : [១] មធ្យមភាគប្រចាំឆ្នាំនៃការប្រែប្រួលរវាងឆ្នាំមួយធៀបនឹងឆ្នាំមួយទៀត

[4] ផលិតភាពពលកម្ម គឺជាតម្លៃបន្ថែមដែលបានពីកម្មករម្នាក់ៗ។ ប្រការនេះគឺមានន័យថាបរិមាណ៥០%ទៀតនៃកំនើននៃផលិតភាពពលកម្ម ជាការចូលរួមរបស់កត្តាផលិតកម្មផ្សេងទៀត រួមមាន មូលធន ដីធ្លី និងសហគ្រិនភាព។

## ៦.៤ ការសន្មតស្ដីពីភាពក្រីក្រ

ក្រសួងផែនការបានធ្វើការប៉ាន់ប្រមាណលើភាពក្រីក្រ ចាប់តាំងពីឆ្នាំ១៩៩៤ ដោយមានកិច្ចសហការជាមួយដៃគូអភិវឌ្ឍ ពិសេសគឺធនាគារពិភពលោក។ ទិន្នន័យគោលនៃភាពក្រីក្រ ត្រូវបានគណនាជាដំបូង ចេញពីការអង្កេតលើការប្រើប្រាស់ទំនិញក្នុងទ្រង់ទ្រាយធំជាលើកដំបូង គឺការអង្កេតសង្គមសេដ្ឋកិច្ចកម្ពុជា ឆ្នាំ ១៩៩៣/១៩៩៤ (Prescott and Pradhan, ១៩៩៧)។ ទិន្នន័យបច្ចុប្បន្នភាពនៃភាពក្រីក្រ ត្រូវបានគណនាចេញពីលទ្ធផលនៃការអង្កេតសង្គមសេដ្ឋកិច្ចកម្ពុជា ឆ្នាំ ១៩៩៧, ២០០៤ និង២០០៧ និងការប៉ាន់ប្រមាណបឋមសម្រាប់ឆ្នាំ២០០៨ និង២០០៩ (MoP, ១៩៩៨ និងKnowles, ២០០៥, ២០០៩)[5]។ វិធីសាស្ត្រក្នុងការគណនាភាពក្រីក្រ មានការវិវត្តជារៀងរាល់ឆ្នាំ។ ចាប់តាំងពីឆ្នាំ២០០៤មក អត្រានៃភាពក្រីក្រត្រូវបានគណនាដោយមានសង្គតិភាពចេញពីទិន្នន័យនៃការប្រើប្រាស់និងបរិភោគប្រចាំគ្រួសារ តាមរយៈការអង្កេតសង្គមសេដ្ឋកិច្ចកម្ពុជា និងការកំណត់ដោយប្រុងប្រយ័ត្នបំផុត ទៅលើបន្ទាត់នៃភាពក្រីក្រ ។

ក្រសួងផែនការបានអនុវត្តកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ដោយមានកិច្ចសហប្រតិបត្តិការជាមួយទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍អាល្លឺម៉ង់ (GIZ) ក្នុងគោលដៅកំណត់រកគ្រួសារមួយម្ដងៗទូទាំងប្រទេសដែលអាចចាត់ទុកថាក្រីក្របំផុត (ID-Poor 1) និងក្រីក្រ (ID-Poor 2)។ នៅតាមភូមិនីមួយៗ មានបង្កើតជាគណៈកម្មការពិសេសមួយដើម្បីរៀបចំដំណើរការកម្មវិធីនេះ។ ការវាយតម្លៃលើភាពក្រីក្រជាដំណើរការដោយមានការចូលរួម ដោយរួមបញ្ចូលទាំងការវាយតម្លៃដោយគ្រួសារផ្ទាល់ តាមរយៈការឆ្លើយតបទៅនឹងបញ្ជីសំណួរដ៏ពិស្ដារមួយ ស្ដីពីប្រភពប្រាក់ចំណូល ផ្ទះសម្បែង ភាពជាម្ចាស់ កម្មសិទ្ធិលើទ្រព្យសម្បត្តិ និងកត្តាផ្សេងៗមួយចំនួន។ ចម្លើយទៅនឹងបញ្ជីសំនួរនេះនឹងត្រូវដាក់ពិន្ទុ ហើយដោយផ្អែកទៅលើចំនួនពិន្ទុសរុប គណៈកម្មការថ្នាក់ភូមិនឹងកំណត់ថាតើគ្រួសារណាដែលអាចចាត់ទុកជាគ្រួសារក្រីក្របំផុត ឬគ្រួសារក្រីក្រ។ ថ្នាក់នៃភាពក្រីក្រទាំងពីរកម្រិតនេះ គឺអាចប្រៀបធៀបបានទៅនឹងអនុក្រុមប្រជាជន ដែលបែងចែកដោយបន្ទាត់នៃភាពក្រីក្រចំនួនពីរ ទោះបីជាការបែងចែកនេះ ប្រើប្រាស់ វិធីសាស្ត្រខុសគ្នាក៏ដោយ។ ឯកសារនេះកំណត់ការសន្មតថា អត្រានៃភាពក្រីក្រសម្រាប់ជនក្រីក្របំផុតនិងជនក្រីក្រ ដែលកំណត់ដោយការវាយតម្លៃនៃការអង្កេតសង្គមសេដ្ឋកិច្ចកម្ពុជា តំណាងឲ្យអត្រានៃភាពក្រីក្រនៃប្រជាជនដែលស្ថិតក្នុងគ្រួសារក្រីក្របំផុត (ID-Poor 1) និងគ្រួសារក្រីក្រ (ID-Poor 2) ។

### ៦.៤.១ បន្ទាត់នៃភាពក្រីក្រ

បន្ទាត់នៃភាពក្រីក្រ គឺជាខ្សែបន្ទាត់គោលដើម្បីប៉ាន់ប្រមាណលើភាពក្រីក្រ។ ខ្សែបន្ទាត់នៃភាពក្រីក្រផ្នែកស្បៀងអាហារ ឆ្លុះបញ្ចាំងពីថ្លៃលើទីផ្សារនៃតម្រូវការអាហាររូបត្ថម្ភមូលដ្ឋាន ក្នុង

---

[5] ក្នុងពេលនិពន្ធឯកសារ ការប៉ាន់ប្រមាណបឋមសម្រាប់ឆ្នាំ ២០០៨ និង ២០០៩ ស្ដីពីស្ថានភាព នៃភាពក្រីក្រ គឺនៅពុំទាន់ទទួលការអនុម័តពីក្រសួងផែនការនៅឡើយ។

កម្រិត២១០០កាឡូរីសម្រាប់មនុស្សម្នាក់ក្នុងមួយថ្ងៃ ចំណែកឯខ្សែបន្ទាត់នៃភាពក្រីក្រគឺបន្ថែមទៅលើការបរិភោគស្បៀងអាហារមូលដ្ឋាន នូវថ្លៃនៃទំនិញនិងសេវាកម្មចាំបាច់រួមមានសម្លៀកបំពាក់ ផ្ទះសម្បែង មធ្យោបាយធ្វើដំណើរ និងការថែរក្សាសុខភាព។ ដោយផ្អែកលើកញ្ចប់នៃការបរិភោគ និងប្រើប្រាស់នៅឆ្នាំ២០០៤ ការចំណាយលើទំនិញដែលមិនមែនជាអាហារគឺស្មើនឹង២០%នៃកញ្ចប់ទាំងមូល (តារាង ៦.៥) ។

**តារាង ៦.៤ ខ្សែបន្ទាត់នៃភាពក្រីក្រសម្រាប់ប្រទេសកម្ពុជា ១៩៩៣-២០០៩**

| | ១៩៩៣/៩៤ | ២០០៤ | ២០០៧ | ២០០៩ [1] |
|---|---|---|---|---|
| បន្ទាត់នៃភាពក្រីក្រផ្នែកស្បៀងអាហារ | | | | |
| ភ្នំពេញ | 1 181 | 1 782 | 2 445 | 3 395 |
| តំបន់ទីប្រជុំជនដទៃទៀត | 1 000 | 1 568 | 2 274 | 2 907 |
| តំបន់ជនបទ | 886 | 1 389 | 1 965 | 2 721 |
| បន្ទាត់នៃភាពក្រីក្រសរុប | | | | |
| ភ្នំពេញ | 1 574 | 2 351 | 3 092 | 4 185 |
| តំបន់ទីប្រជុំជនដទៃទៀត | 1 269 | 1 952 | 2 704 | 3 438 |
| តំបន់ជនបទ | 1 122 | 1 753 | 2 367 | 3 213 |

***កំណត់សម្គាល់*** ការគណនាជាបឋមរបស់ធនាគារពិភពលោក គឺពឹងផ្អែកលើទិន្នន័យនៃការអង្កេតសង្គមសេដ្ឋកិច្ចកម្ពុជា ឆ្នាំ២០០៩

***ប្រភព*** ក្រសួងផែនការ និងធនាគារពិភពលោក

ដោយភាពក្រីក្រនៅប្រទេសកម្ពុជាបានប្រមូលផ្តុំនៅតំបន់ជនបទ ឯកសារនេះបានប្រើប្រាស់បន្ទាត់នៃភាពក្រីក្រនៅតំបន់ជនបទ ដើម្បីធ្វើជាចំនុចគោលចម្បងមួយសម្រាប់កំណត់ទំហំនៃលាភការ។ បន្ទាត់នៃភាពក្រីក្រត្រូវបានគណនាដោយផ្អែកលើការសន្មតនៃកម្រិតថ្លៃទំនិញដែលវាស់វែងដោយសន្ទស្សន៍នៃថ្លៃទំនិញរបស់អ្នកប្រើប្រាស់ (តារាង៦.៤)។ គួរកត់សម្គាល់ដែរថាសម្រាប់កញ្ចប់នៃថ្លៃទំនិញសម្រាប់ការប្រើប្រាស់ដូចគ្នា បន្ទាត់នៃភាពក្រីក្រផ្នែកស្បៀងអាហារបានកើនឡើងដល់៩៤០០០រៀល (២២,៥០ដុល្លារ) ពីឆ្នាំ២០០៩ដល់ឆ្នាំ២០១២។ ក្នុងអំឡុងពេលនៃឆ្នាំ២០០៩-២០២០ បន្ទាត់នៃភាពក្រីក្រផ្នែកស្បៀងអាហារនឹងកើនពី៨២០០០រៀល(១៩,៥ដុល្លារ) រហូតដល់១២០០០០រៀល (២៨,៩ ដុល្លារ) ចំណែកបន្ទាត់នៃភាពក្រីក្រសរុប នឹងកើនពី៩៦០០០ រៀល (២៣,០ដុល្លារ) ទៅដល់១៤០០០០រៀល (៣៣,៦ ដុល្លារ) ដូចមានបង្ហាញក្នុងតារាង៦.៦។

**តារាង៦.៦.  បន្ទាត់នៃភាពក្រីក្រ និទស្សន៍សម្រាប់ឆ្នាំ ២០០៩-២០២០**

| | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| បរិមាណប្រចាំថ្ងៃ | | | | | | | | | | | | |
| បន្ទាត់នៃភាពក្រីក្រផ្នែកស្បៀងអាហារ | 2 721 | 2 830 | 2 988 | 3 117 | 3 232 | 3 329 | 3 429 | 3 532 | 3 638 | 3 747 | 3 859 | 3 975 |
| បន្ទាត់នៃភាពក្រីក្រសរុប | 3 213 | 3 341 | 3 528 | 3 680 | 3 816 | 3 931 | 4 049 | 4 170 | 4 296 | 4 424 | 4 557 | 4 694 |
| ប្រចាំខែ (ពាន់រៀល) [២] | | | | | | | | | | | | |
| បន្ទាត់នៃភាពក្រីក្រផ្នែកស្បៀងអាហារ | 81.6 | 84.9 | 89.6 | 93.5 | 97.0 | 99.9 | 102.9 | 106.0 | 109.1 | 112.4 | 115.8 | 119.3 |
| បន្ទាត់នៃភាពក្រីក្រសរុប | 96.4 | 100.2 | 105.8 | 110.4 | 114.5 | 117.9 | 121.5 | 125.1 | 128.9 | 132.7 | 136.7 | 140.8 |
| ប្រចាំខែ (ដុល្លារ) [៣] | | | | | | | | | | | | |
| បន្ទាត់នៃភាពក្រីក្រផ្នែកស្បៀងអាហារ | 19.5 | 20.3 | 21.4 | 22.3 | 23.2 | 23.9 | 24.6 | 25.3 | 26.1 | 26.9 | 27.7 | 28.5 |
| បន្ទាត់នៃភាពក្រីក្រសរុប | 23.0 | 23.9 | 25.3 | 26.4 | 27.4 | 28.2 | 29.0 | 29.9 | 30.8 | 31.7 | 32.7 | 33.6 |

**កំណត់សម្គាល់:**

១. បរិមាណប្រចាំថ្ងៃ: គណនាដោយផ្អែកលើការនិទស្សន៍លើដំណើរវិវត្តន៍សន្ទស្សន៍ថ្លៃទំនិញសម្រាប់អ្នកប្រើប្រាស់ (តារាង៦.៤)

២. ដោយកំណត់ថា ក្នុង១ខែមាន៣០ថ្ងៃ

៣. ដោយកំណត់ថា ១ ដុល្លារ = ៤១៨៥ រៀល

## ៦.៤.២ អត្រានៃភាពក្រីក្រដោយរាប់តាមមនុស្ស

យោងទៅលើការគណនារបស់ធនាគារពិភពលោក (ក្នុងការអង្កេតសង្គមសេដ្ឋកិច្ចកម្ពុជាឆ្នាំ២០០៩) អត្រាភាពក្រីក្រដោយរាប់តាមមនុស្សនៃភាពក្រីក្រសរុប អាចថយចុះដល់១៥% សម្រាប់ប្រជាជនគ្រប់រូប និង៧%សម្រាប់ភាពក្រីក្របំផុត។ ការគណនាជាបឋមនេះ បង្ហាញពីការធ្លាក់ចុះដ៏គួរឲ្យកត់សម្គាល់មួយ នៃឧប្បត្តិហេតុនៃអត្រាភាពក្រីក្រ ចាប់តាំងពីឆ្នាំ២០០៧។ ប៉ុន្តែប្រការដែលគួរឲ្យប្រុងប្រយ័ត្នក្នុងការប្រើប្រាស់ព័ត៌មាន គឺថាលទ្ធផលនៃការស្រាវជ្រាវស្តីពីនិន្នាការនេះ នៅពុំទាន់បញ្ជាក់ច្បាស់នៅឡើយ។

ទិន្នន័យនៃភាពក្រីក្រ ដែលដកស្រង់ចេញពីការសង្កេតលើការប្រើប្រាស់ និងការបរិភោគនៅកម្រិតថ្នាក់ជាតិ អាចត្រូវគ្នានៃផ្នែកខ្លះប៉ុណ្ណោះទៅនឹងបរិបទនៃឯកសារនេះ ដោយសារ និយមន័យជាលក្ខណៈស្ថិតិសាស្ត្រនៃភាពក្រីក្រ អាចពុំមានសង្គតិភាពទៅនឹងលក្ខខណ្ឌកំណត់ស្តីពីភាពក្រីក្រ ដែលប្រើប្រាស់នៅក្នុងការវាយតម្លៃលើភាពក្រីក្រនៅកម្រិតថ្នាក់ភូមិ (ឧទាហរណ៍ យន្តការអត្តសញ្ញាណកម្មគ្រួសារក្រីក្រ)។ ទិន្នន័យសំណាកដែលដកស្រង់ចេញពីប្រព័ន្ធទិន្នន័យនៃកម្មវិធីអត្ត

សញ្ញាណកម្មគ្រួសារក្រីក្រ (២០១០) បានបង្ហាញថា គ្រួសារក្រីក្របំផុត (ID-Poor 1) អាចមានអត្រានៃភាពក្រីក្រដោយរាប់តាមមនុស្សស្មើនឹង១២,៧% ចំណែកឯសម្រាប់គ្រួសារក្រីក្រ (ID-Poor 2) វិញ អត្រានៃភាពក្រីក្រដោយរាប់តាមមនុស្ស ស្មើនឹង១៤,២% ហើយដែលការបូកបញ្ចូលគ្នានៃអត្រានៃភាពក្រីក្រដោយរាប់តាមមនុស្ស គឺស្មើនឹង២៦,៩% (ILO, 2012) ។

ការធ្វើនិទស្សន៍លើភាពក្រីក្រសម្រាប់អំឡុងឆ្នាំ២០០៨-២០១០ ដែលរៀបចំដោយរាជរដ្ឋាភិបាលកម្ពុជា ក្នុងអំឡុងពេលធ្វើការត្រួតពិនិត្យពាក់កណ្តាលអណត្តិលើផែនការយុទ្ធសាស្រ្តអភិវឌ្ឍជាតិ (RGC, ២០១១b) បានបង្ហាញថា អត្រានៃភាពក្រីក្របានថយចុះជាលំដាប់ ពី៣០,១% នៅឆ្នាំ២០០៧ ដល់២៦,១% នៅឆ្នាំ២០១០ ហើយអត្រានៃភាពក្រីក្របំផុត បានថយចុះពី១៨% មកដល់១៥%ក្នុងអំឡុងពេលដូចគ្នា។ ដូច្នេះ ប្រការនេះអាចទាញចេញជាការសន្មតថា អត្រានៃភាពក្រីក្រដោយរាប់តាមមនុស្សអាចនឹងថយចុះ១% ជារៀងរាល់ឆ្នាំ (-0,៩៧%) សម្រាប់ភាពក្រីក្របំផុត និងប្រហែល០,៤% (-0,៣៧%) សម្រាប់ភាពក្រីក្រទូទៅ។ ដោយប្រើប្រាស់និន្នាការនៃការធ្លាក់ចុះនេះសម្រាប់ឆ្នាំបន្តបន្ទាប់ទៀត (២០១២-២០២០) តារាង ៦.៧ នឹងបង្ហាញពីការនិទស្សន៍ សម្រាប់ដំណាក់កាលមធ្យម លើអត្រានៃភាពក្រីក្រដោយរាប់តាមមនុស្ស។ ដោយយោងទៅលើការសន្មតនេះ ប្រេវ៉ាឡង់នៃភាពក្រីក្រសរុបអាចថយចុះដល់១២,៨%នៅឆ្នាំ២០២០ ហើយ ប្រេវ៉ាឡង់នៃភាពក្រីក្របំផុត អាចថយចុះដល់៥,៤%។ ភាពខុសគ្នារវាងភាពក្រីក្រទៅតាមភេទ ត្រូវបានគណនាដោយផ្អែកលើសំណាកនៃទិន្នន័យកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ (ILO, ២០១២) ។

**តារាង ៦.៧ អត្រាប្រេវ៉ាឡង់នៃភាពក្រីក្រ និទស្សន៍សម្រាប់ឆ្នាំ ២០១០ - ២០២០ (គិតជាភាគរយនៃប្រជាជន)**

| | ២០១០[1] | ២០១១ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ |
|---|---|---|---|---|---|---|---|---|---|---|---|
| ភាពក្រីក្រសរុប | **26.1** | **24.8** | **23.4** | **22.1** | **20.8** | **19.4** | **18.1** | **16.8** | **15.4** | **14.1** | **12.8** |
| បុរស | 25.3 | 24.0 | 22.7 | 21.4 | 20.1 | 18.8 | 17.6 | 16.3 | 15.0 | 13.7 | 12.4 |
| ស្ត្រី | 26.9 | 25.5 | 24.1 | 22.8 | 21.4 | 20.0 | 18.6 | 17.2 | 15.9 | 14.5 | 13.1 |
| ភាពក្រីក្រធ្ងន់ធ្ងរ | **15.1** | **14.1** | **13.2** | **12.2** | **11.2** | **10.3** | **9.3** | **8.3** | **7.4** | **6.4** | **5.4** |
| បុរស | 14.5 | 13.6 | 12.7 | 11.7 | 10.8 | 9.9 | 8.9 | 8.0 | 7.1 | 6.2 | 5.2 |
| ស្ត្រី | 15.6 | 14.6 | 13.6 | 12.6 | 11.6 | 10.6 | 9.6 | 8.6 | 7.6 | 6.6 | 5.6 |
| ភាពក្រីក្រពុំធ្ងន់ធ្ងរ | **11.0** | **10.6** | **10.3** | **9.9** | **9.5** | **9.2** | **8.8** | **8.4** | **8.1** | **7.7** | **7.3** |
| បុរស | 10.8 | 10.4 | 10.0 | 9.7 | 9.3 | 9.0 | 8.6 | 8.2 | 7.9 | 7.5 | 7.2 |
| ស្ត្រី | 11.2 | 10.9 | 10.5 | 10.1 | 9.7 | 9.4 | 9.0 | 8.6 | 8.2 | 7.9 | 7.5 |

***កំណត់សម្គាល់:*** និន្នាការដែលសន្មតខាងលើ គឺផ្អែកលើ RGC (២០១១b)

លទ្ធផលនៃការគណនាលើចំនួនមនុស្សដែលស្ថិតក្នុងភាពក្រីក្រក្នុងអំឡុងឆ្នាំ២០១២ - ២០២០ អាចកំណត់បានដោយប្រើប្រាស់អត្រានៃភាពក្រីក្រដោយរាប់តាមមនុស្ស ដែលបង្ហាញក្នុង

តារាង ៦.៧ ធៀបទៅនឹងការនិទស្សន៍លើចំនួនប្រជាករនៅតារាង ៦.១ (តារាង៦.៨)។ ដោយផ្អែកលើការសន្មតខាងលើ ចំនួននៃជនក្រីក្រដែលនិទស្សន៍ឃើញ នឹងថយចុះពី៣,៥លាននាក់ នៅឆ្នាំ ២០១២ ដល់២,១លាននាក់ នៅឆ្នាំ ២០២០។ ចំនួននៃជនក្រីក្របំផុត នឹងថយចុះពី១,៩ លាននាក់ នៅឆ្នាំ២០១៨ មកដល់០,៩លាន នាក់នៅឆ្នាំ ២០២០។

**តារាង ៦.៨ ចំនួនប្រជាជនក្រីក្រ និទស្សន៍សម្រាប់ឆ្នាំ ២០១០ - ២០២០**

| គិតជាពាន់នាក់ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ |
|---|---|---|---|---|---|---|---|---|---|
| ជនក្រីក្រសរុប | **3 454** | **3 307** | **3 153** | **2 994** | **2 828** | **2 657** | **2 480** | **2 297** | **2 107** |
| បុរស | 1 636 | 1 568 | 1 497 | 1 423 | 1 346 | 1 266 | 1 183 | 1 097 | 1 008 |
| ស្ត្រី | 1 818 | 1 739 | 1 656 | 1 571 | 1 482 | 1 391 | 1 297 | 1 200 | 1 099 |
| ជនក្រីក្របំផុត(កម្រិត១) | **1 941** | **1 825** | **1 706** | **1 582** | **1 453** | **1 321** | **1 184** | **1 043** | **897** |
| បុរស | 913 | 859 | 804 | 746 | 686 | 624 | 560 | 494 | 425 |
| ស្ត្រី | 1 028 | 966 | 902 | 836 | 767 | 696 | 624 | 549 | 472 |
| ភាពក្រីក្រ (កម្រិត២) | **1 513** | **1 481** | **1 448** | **1 412** | **1 375** | **1 337** | **1 296** | **1 254** | **1 210** |
| បុរស | 723 | 709 | 693 | 677 | 660 | 642 | 623 | 604 | 583 |
| ស្ត្រី | 790 | 773 | 754 | 735 | 715 | 695 | 673 | 651 | 627 |

**ប្រភព** ILO (២០១២)

តារាង ៦.៩ ខាងក្រោម បង្ហាញពីរបាយនៃភាពក្រីក្រទៅតាមក្រុមអាយុ ដោយគណនាផ្អែកលើទិន្នន័យសំណាកនៃកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ (ILO, ២០១២)។ ការគណនានេះសន្មតថា អត្រានៃភាពក្រីក្រដោយរាប់តាមមនុស្សទៅតាមក្រុមអាយុនឹងថយចុះស្របគ្នាសម្រាប់គ្រប់ក្រុមអាយុ គឺបានន័យថាអត្រានៃភាពក្រីក្រដោយរាប់តាមមនុស្សសម្រាប់ក្រុមអាយុខុសៗគ្នា នឹងមានសមមាត្រស្មើគ្នាក្នុងអំឡុងពេលនៃការធ្វើនិទស្សន៍។ ការសន្មតលើរបាយនៃភាពក្រីក្រទៅតាមក្រុមអាយុដែលបង្ហាញក្នុងតារាង ៦.៩ ជាទិន្នន័យសម្រាប់ឆ្នាំ២០១២។ យោងទៅលើការនិទស្សន៍នេះ ចំនួនជនក្រីក្រសរុបដែលជាកុមារអាយុក្រោម១៥ឆ្នាំ គឺមានជាង១,១លាននាក់ ដែលត្រូវជា ៣២% នៃជនក្រីក្រសរុបទាំងអស់។ ចំនួននៃជនក្រីក្រដែលជាស្ត្រី គឺមាន១,៨ លាននាក់ ធៀបនឹង ១,៦ លាននាក់ ដែលជាចំនួនបុរសក្រីក្រ ។

**តារាង ៦.៩ នាពក្រីក្រដោយរាប់តាមមនុស្ស ទៅតាមក្រុមអាយុ សម្រាប់ឆ្នាំ២០១២**

| គិតជាពាន់នាក់ | ជនក្រីក្រសរុប | | | ជនក្រីក្របំផុត (កម្រិត១) | | | ជនក្រីក្រ (កម្រិត២) | | |
|---|---|---|---|---|---|---|---|---|---|
| ក្រុមអាយុ | សរុប | បុរស | ស្ត្រី | សរុប | បុរស | ស្ត្រី | សរុប | បុរស | ស្ត្រី |
| ០-៤ | 420.0 | 212.8 | 207.2 | 250.2 | 127.0 | 123.2 | 169.8 | 85.8 | 84.0 |
| ៥-៩ | 363.6 | 185.4 | 178.2 | 215.9 | 109.9 | 105.9 | 147.7 | 75.4 | 72.3 |
| ១០-១៤ | 340.9 | 173.6 | 167.2 | 197.3 | 101.1 | 96.2 | 143.5 | 72.5 | 71.0 |
| ១៥-១៩ | 375.1 | 191.0 | 184.0 | 205.3 | 104.8 | 100.5 | 169.8 | 86.2 | 83.5 |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ២០-២៤ | 396.8 | 197.7 | 199.1 | 210.7 | 104.3 | 106.3 | 186.2 | 93.4 | 92.8 |
| ២៥-២៩ | 371.6 | 176.8 | 194.8 | 200.3 | 95.1 | 105.2 | 171.3 | 81.7 | 89.6 |
| ៣០-៣៤ | 303.4 | 145.7 | 157.7 | 168.3 | 79.7 | 88.7 | 135.1 | 66.0 | 69.0 |
| ៣៥-៣៩ | 147.3 | 67.2 | 80.1 | 83.1 | 37.0 | 46.0 | 64.2 | 30.2 | 34.0 |
| ៤០-៤៤ | 168.7 | 75.2 | 93.5 | 93.9 | 41.0 | 52.8 | 74.9 | 34.2 | 40.7 |
| ៤៥-៤៩ | 144.4 | 62.5 | 81.9 | 78.6 | 33.5 | 45.1 | 65.7 | 29.0 | 36.8 |
| ៥០-៥៤ | 108.1 | 43.6 | 64.5 | 56.6 | 22.2 | 34.4 | 51.5 | 21.4 | 30.1 |
| ៥៥-៥៩ | 84.7 | 27.1 | 57.6 | 44.9 | 13.7 | 31.2 | 39.8 | 13.4 | 26.4 |
| ៦០-៦៤ | 72.6 | 23.0 | 49.6 | 40.0 | 11.9 | 28.0 | 32.6 | 11.1 | 21.5 |
| ៦៥-៦៩ | 53.4 | 17.7 | 35.7 | 31.1 | 9.5 | 21.6 | 22.3 | 8.2 | 14.1 |
| ៧០-៧៤ | 44.1 | 15.1 | 29.0 | 26.7 | 8.6 | 18.2 | 17.3 | 6.5 | 10.8 |
| លើស៧៥ | 59.8 | 21.4 | 38.3 | 38.0 | 13.1 | 24.9 | 21.7 | 8.3 | 13.4 |
| សរុប | **3 454** | **1 636** | **1 818** | **1 941** | **913** | **1 028** | **1 513** | **723** | **790** |

ប្រភព ILO (២០១២)

## ៦.៥ ការសន្ទតជាក់លាក់សម្រាប់កម្មវិធី

### ៦.៥.១ ជម្រើសគោលនយោបាយទី៣ និង ៣ស

ដើម្បីធ្វើការនិទស្សន៍លើចំនួនស្ត្រីមានផ្ទៃពោះ ដែលអាចសក្តិសមដើម្បីទទួលលាភការក្នុងជម្រើសគោលនយោបាយទី៣ និង៣ស ឯកសារនេះបាននិទស្សន៍លើអត្រាបង្កកំណើតជាក់លាក់ទៅតាមក្រុមអាយុ សម្រាប់ក្រុមអាយុពេញវ័យបន្តពូជ ដោយផ្អែកលើការវិវត្តន៍ដោយនិទស្សន៍នៃអត្រាបង្កកំណើតសរុប (TFR) ដូចបង្ហាញក្នុងតារាង ៦.១០។ ចំនួននៃកំណើតទារក អាចគណនាបានដោយប្រើប្រាស់អត្រាបង្កកំណើតជាក់លាក់ទៅតាមក្រុមអាយុ ទៅលើក្រុមស្ត្រីនៃក្រុមអាយុនីមួយៗ ដែលដកស្រង់ចេញពីការនិទស្សន៍លើចំនួនប្រជាករ (NIS, ២០១១)។

**តារាង ៦.១០ អត្រាបង្កកំណើតទៅតាមក្រុមអាយុ និងអត្រាបង្កកំណើតសរុប និទស្សន៍សម្រាប់ឆ្នាំ ២០១២ - ២០២០**

| ក្រុមអាយុ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ |
|---|---|---|---|---|---|---|---|---|---|
| ១៥-១៩ | 0.029 | 0.029 | 0.028 | 0.027 | 0.027 | 0.026 | 0.026 | 0.025 | 0.025 |
| ២០-២៤ | 0.130 | 0.127 | 0.124 | 0.120 | 0.118 | 0.116 | 0.114 | 0.113 | 0.111 |
| ២៥-២៩ | 0.137 | 0.134 | 0.130 | 0.126 | 0.124 | 0.122 | 0.120 | 0.118 | 0.116 |
| ៣០-៣៤ | 0.105 | 0.102 | 0.100 | 0.097 | 0.095 | 0.094 | 0.092 | 0.091 | 0.089 |
| ៣៥-៣៩ | 0.073 | 0.071 | 0.069 | 0.067 | 0.066 | 0.065 | 0.064 | 0.063 | 0.062 |
| ៤០-៤៤ | 0.035 | 0.034 | 0.033 | 0.032 | 0.031 | 0.031 | 0.030 | 0.030 | 0.029 |
| ៤៥-៤៩ | 0.009 | 0.009 | 0.009 | 0.008 | 0.008 | 0.008 | 0.008 | 0.008 | 0.008 |
| **អត្រាបង្កកំនើតសរុប** | 2.594 | 2.526 | 2.458 | 2.39 | 2.352 | 2.314 | 2.276 | 2.238 | 2.2 |

**កំណាត់សម្គាល់:**

១. ដោយផ្អែកលើបែបផែននៃក្រុមអាយុដែលបាននិទស្សន៍រួច កាលពីឆ្នាំ២០០៨ (NIS, ២០១១) ការគណនាក្នុងឯកសារនេះ សន្មត នូវការថយចុះដោយសមមាត្រនៃអត្រាបង្កកំណើតទៅតាមក្រុមអាយុ ស្របគ្នាជាមួយនឹងការថយចុះនៃអត្រាបង្កកំណើតសរុប។

**ប្រភព:** ការគណនារបស់អ្នកនិពន្ធ ដោយផ្អែកលើអត្រាបង្កកំណើតសរុប ដែលនិទស្សន៍ដោយវិទ្យាស្ថានជាតិស្ថិតិ (NIS, ២០១១)

## ៦.៥.២ ជម្រើសគោលនយោបាយទី៦ និងទី៧

សម្រាប់កម្មវិធីសំណង់សាធារណៈ (ជម្រើសគោលនយោបាយទី៦ និងទី៧) កម្រិតប្រាក់កម្រៃប្រចាំថ្ងៃ គឺសន្មតថាស្មើនឹង១០000រៀល (២,៤0 ដុល្លារ) សម្រាប់ឆ្នាំ២០១២ ដោយផ្អែកលើឯកសារនៃការរៀបចំកម្មវិធីសំណង់សាធារណៈ ដែលបានរៀបចំដោយអង្គការពលកម្មអន្តរជាតិ (ILO, ២០១២)។ នៅក្នុងចំនុចស្តីពីផែនការអនុវត្តកម្មវិធី ធាតុចូលដែលមិនមែនជាកម្លាំងពលកម្មសម្រាប់កម្មវិធីគឺស្មើនឹង៤0-៦0% នៃថវិកាចំណាយសម្រាប់កម្មវិធីទាំងមូល។ ប្រការនេះ អាចបង្កើតជាការសន្មតសម្រាប់ជម្រើសគោលនយោបាយទាំងពីរថា ធាតុចូលដែលជាកម្លាំងពលកម្មសម្រាប់កម្មវិធី អាចត្រូវជា៥0%នៃថវិកាចំណាយសម្រាប់កម្មវិធីទាំងមូល ។

## ៦.៥.៣ ជម្រើសគោលនយោបាយទី ១២ និងទី ១២ស

ដោយយោងទៅលើលទ្ធផលនៃការធ្វើជំរឿនទូទៅចុងក្រោយ ចំនួនសរុបនៃជនពិការគឺស្មើនឹង១៩២៥៣៨នាក់នៅឆ្នាំ២០០៨ (តារាង ៦.១១)។ ប្រសិនបើធៀបទៅនឹងចំនួនប្រជាជនសរុប តួរលេខនេះបង្ហាញថាអត្រាប្រេវ៉ាឡង់នៃពិការភាពថ្នាក់ជាតិ គឺស្មើនឹង១,៤៤%។

តារាង ៦.១១ បង្ហាញពីរបាយនៃពិការភាពទៅតាមក្រុមអាយុ និងអត្រាប្រេវ៉ាឡង់នៃពិការភាពទៅតាមក្រុមអាយុនីមួយៗ។ ដោយផ្អែកទៅលើចំនួននៃពិការភាព មូលហេតុនៃការបាត់បង់ផ្នែកផ្សេងៗនៃសារពាង្គកាយ អាចបណ្តាលមកពីសង្គ្រាម ពិសេសសម្រាប់ក្រុមប្រជាជនដែលមានអាយុច្រើន។ ដូច្នេះអត្រាប្រេវ៉ាឡង់នេះអាចរំពឹងថានឹងថយចុះនៅថ្ងៃអនាគត។ ដោយគ្មានទិន្នន័យជាក់លាក់ណាដែលបង្ហាញពីឧប្បត្តិហេតុនៃករណីថ្មី ឯកសារនេះសន្មតថាចំនួនជនពិការសរុប នឹងមិនកើនឡើងទៀតទេនៅពេលអនាគត ប៉ុន្តែនឹងស្ថិតនៅថេរដដែល។ ប្រការនេះគឺមានន័យថា ប្រេវ៉ាឡង់នៃពិការភាពសម្រាប់ប្រជាជនទាំងអស់ អាចថយចុះពី១,៤៤%នៅឆ្នាំ២០០៨ ទៅ១,១៦% នៅឆ្នាំ២០២០ (គឺថយចុះ១៩%) ដែលនេះជាការសន្មតដែលមានលក្ខណៈចង្អៀតបំផុត[6]។ ចំនួនជនពិការក្នុងចំណោមគ្រួសារក្រីក្រ ដែលស្ថិតក្នុងកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ អាចគណនាបានដោយការប្រើប្រាស់អត្រាប្រេវ៉ាឡង់ជាក់លាក់ទៅតាមក្រុមអាយុ ធៀបទៅនឹងក្រុម

[6] ការរៀបចំម៉ូដែលជាក់លាក់សម្រាប់ប្រេវ៉ាឡង់នៃពិការភាព នឹងទាមទារឲ្យមាននូវទិន្នន័យពិស្តារនៃអត្រាប្រេវ៉ាឡង់ ទៅតាមអាយុនីមួយៗ (ឧទាហរណ៍ ចំពោះករណីពិការថ្មី) និងអត្រាមរណភាពជាក់លាក់ទៅតាមក្រុមអាយុ ដែលបណ្តាលមកពីបន្ទុក នៃពិការភាព ។

អាយុដូចគ្នាសម្រាប់ជនក្រីក្រ។ យោងទៅលើលទ្ធផលនៃការអង្កេតសង្គមសេដ្ឋកិច្ចកម្ពុជា ឆ្នាំ ២០០៧ អត្រាប្រេវ៉ាឡង់នៃពិការភាពក្នុងចំណោមជនក្រីក្រ ពុំខុសគ្នាខ្លាំងពីអត្រាថ្នាក់ជាតិទាំងមូលទេ[7]។ យោងទៅលើការសន្មតនេះ ចំនួនសរុបនៃជនពិការក្នុងចំណោមគ្រួសារក្រីក្រដែលស្ថិតក្នុងកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ អាចស្មើនឹង៤៨៩៥៥នាក់ នៅឆ្នាំ ២០១២។

**តារាង ៦.១១ អត្រាប្រេវ៉ាឡង់នៃពិការភាព ទៅតាមក្រុមអាយុ និងភេទនៅឆ្នាំ ២០០៨**

| គិតជាពាន់នាក់ | ជនពិការ | | | អត្រាប្រេវ៉ាឡង់ (%នៃប្រជាជនសរុប) | | |
|---|---|---|---|---|---|---|
| ក្រុមអាយុ | បុរស | ស្ត្រី | សរុប | បុរស | ស្ត្រី | សរុប |
| ០-៤ | 7 952 | 4 281 | 3 671 | 0.58 | 0.61 | 0.55 |
| ៥-៩ | 11 201 | 6 233 | 4 968 | 0.76 | 0.83 | 0.69 |
| ១០-១៤ | 14 775 | 8 609 | 6 166 | 0.88 | 1.00 | 0.76 |
| ១៥-១៩ | 17 865 | 10 163 | 7 702 | 1.10 | 1.22 | 0.98 |
| ២០-២៤ | 16 270 | 9 128 | 7 142 | 1.19 | 1.36 | 1.02 |
| ២៥-២៩ | 14 596 | 8 075 | 6 521 | 1.18 | 1.33 | 1.04 |
| ៣០-៣៤ | 9 526 | 5 394 | 4 132 | 1.37 | 1.61 | 1.15 |
| ៣៥-៣៩ | 14 350 | 8 936 | 5 414 | 1.70 | 2.19 | 1.24 |
| ៤០-៤៤ | 15 493 | 9 800 | 5 693 | 2.10 | 2.85 | 1.45 |
| ៤៥-៤៩ | 15 888 | 10 345 | 5 543 | 2.43 | 3.46 | 1.56 |
| ៥០-៥៤ | 13 013 | 7 811 | 5 202 | 2.65 | 3.99 | 1.76 |
| ៥៥-៥៩ | 10 581 | 5 790 | 4 791 | 2.71 | 3.57 | 2.09 |
| ៦០-៦៤ | 7 911 | 3 999 | 3 912 | 2.85 | 3.43 | 2.43 |
| ៦៥-៦៩ | 7 173 | 3 405 | 3 768 | 3.31 | 3.76 | 2.98 |
| ៧០-៧៤ | 6 284 | 2 742 | 3 542 | 3.95 | 4.29 | 3.73 |
| លើស៧៥ | 9 660 | 3 757 | 5 903 | 4.94 | 4.96 | 4.93 |
| សរុប | **108 468** | **84 070** | **192 538** | 1.66 | 1.22 | 1.44 |

**ប្រភព:** លទ្ធផលជំរឿនទូទៅ ឆ្នាំ២០០៨ (NIS, ២០០៩)

## ៦.៦ ការប៉ាន់ប្រមាណលើថវិកាចំណាយសម្រាប់ការថែទាំសុខភាព សម្រាប់ជនក្រីក្រ

ប្រការចាំបាច់មួយដែលត្រូវធ្វើឡើង មុននឹងឈានទៅដល់ការប៉ាន់ប្រមាណលើថវិកាចំណាយសម្រាប់ការពង្រីកវិសាលភាពនៃកម្មវិធីមូលនិធិសមធម៌ គឺការរៀបចំបង្កើតម៉ូដែលមួយដែលអាចបង្ហាញពីថវិកាចំណាយសម្រាប់ថ្ងៃអនាគត ដោយផ្អែកលើអញ្ញត្តិមួយចំនួនរួមមានវិសាលភាពនៃកម្មវិធី អត្រានៃការប្រើប្រាស់កម្មវិធី និងការចំណាយក្នុងមួយឯកតាសម្រាប់កញ្ចប់លាភការ។

[7] យោងទៅលើទិន្នន័យនៃការអង្កេតសង្គមសេដ្ឋកិច្ចកម្ពុជា ឆ្នាំ២០០៧ អត្រានៃជនពិការដែលកំនត់ដោយជនពិការខ្លួនឯង មានកម្រិតប្រហាក់ប្រហែលគ្នា ក្នុងចំនោមបញ្ចាភាគនៃប្រជាជន។

លក្ខណៈពិសេសសំខាន់ៗនៃម៉ូដែលទិន្នន័យគោល និងការសន្មតមួយចំនួនដើម្បីគណនាលើថវិកាចំណាយ នឹងបង្ហាញនៅក្នុងការរៀបរាប់ខាងក្រោម។

### ៦.៦.១ អតិក្រមនៃម៉ូដែល

ម៉ូដែលដែលត្រូវប្រើប្រាស់ ដើម្បីធ្វើនិទស្សន៍ លើការចំណាយថវិកាសរុបសម្រាប់កម្មវិធីមូលនិធិសមធម៌ គឺត្រូវផ្អែកលើការវិភាគវិនិច្ឆ័យ លើការចំណាយនៃឆ្នាំ ២០១០ ដែលជាឆ្នាំគោល។ ការចំណាយថវិកាសរុបនៅឆ្នាំ២០១០ ត្រូវបំបែកបន្តទៅទៀតទៅតាមសមាសភាគសំខាន់ៗនៃកម្មវិធី ដែលឆ្លុះបញ្ចាំងឲ្យឃើញពីប្រភេទផ្សេងៗគ្នានៃថវិកាចំណាយនិងលាភការ។ សមាសភាគនៃកម្មវិធីទាំងនេះរួមមានៈ

- ការចំណាយថវិកាដោយផ្ទាល់ រួមមានៈ
  + ការមកពិគ្រោះជម្ងឺ នៅមណ្ឌលសុខភាព
  + ការមកពិគ្រោះជម្ងឺនៅ មន្ទីរពេទ្យបង្អែក
  + ការមកសម្រាកព្យាបាលជម្ងឺ ដោយពុំគិតរួមទាំង ថ្លៃសម្រាលកូននិងថ្លៃវះកាត់
  + ថ្លៃវះកាត់
  + ថ្លៃសម្រាលកូន
  + សោហ៊ុយធ្វើដំណើរសម្រាប់អ្នកជម្ងឺ ក្នុងករណីត្រូវបញ្ជូនទៅមន្ទីរពេទ្យបង្អែក
  + សោហ៊ុយសម្រាប់ថ្លៃអាហារសម្រាប់អ្នកជម្ងឺក្នុងពេលសម្រាកព្យាបាល
  + ប្រាក់ឧបត្ថម្ភផ្សេងទៀតសម្រាប់អ្នកជម្ងឺ
  + ប្រាក់ឧបត្ថម្ភផ្សេងទៀតសម្រាប់អ្នកកំដរ
- ការចំណាយថវិកាដោយប្រយោល រួមមានចំណាយរដ្ឋបាល និងថវិកាចំណាយសម្រាប់ការរៀបចំកម្មវិធី

សមាសភាគនៃការចំណាយថវិកាដោយផ្ទាល់ អាចបន្តបំបែកបន្ថែមទៀតឲ្យទៅជាចំនួនដងនៃសកម្មភាពនីមួយៗ និងចំណាយក្នុងមួយឯកតា ហើយកត្តាទាំងពីរនេះអាចនិទស្សន៍បានដោយផ្អែកលើការសន្មតមួយចំនួន (ដូចរៀបរាប់ខាងក្រោម)។ ចំពោះការពិគ្រោះជម្ងឺសម្រាប់អ្នកដែលមកពិនិត្យនៅមន្ទីពេទ្យ និងអ្នកជម្ងឺដែលត្រូវសម្រាកនៅមន្ទីរពេទ្យ ចំនួនដងនៃសកម្មភាពនីមួយៗ អាចគណនាបានដោយការគុណចំនួនអ្នកជម្ងឺក្នុងមួយឆ្នាំ នៅនឹងអត្រានៃការប្រើប្រាស់ដែលសន្មតសម្រាប់ឆ្នាំដដែល (តារាង ៦.១២)[8]។

---

[8] អត្រានៃការប្រើប្រាស់ (សេវាសុខាភិបាល) ឆ្លុះបញ្ចាំងពីអត្រាឧប្បត្តិហេតុនៃលាភការគិតជាមធ្យម រួមមាន ចំនួនគិតជាមធ្យមនៃលាភការ ដែលអាចផ្តល់ឲ្យបានសម្រាប់មនុស្សម្នាក់ ក្នុងមួយឆ្នាំ។

ចំពោះការនិទស្សន៍លើការចំណាយថវិកាដោយប្រយោលវិញ សមាមាត្រវាងថវិកាចំណាយដោយប្រយោល ទៅនឹងថវិកាចំណាយដោយផ្ទាល់ ត្រូវសន្មតថាស្ថិតនៅថេរ (ប្រហែល ០,២៤៨) ក្នុងអំឡុងពេលនៃការនិទស្សន៍។

### ៦.៦.២ ទិន្នន័យគោល

ទិន្នន័យគោលនៃថវិកាចំណាយសម្រាប់មូលនិធិសមធម៌ ជាការដកស្រង់យកចេញពីទិន្នន័យនៃក្រសួងសុខាភិបាល ដែលរួមមានទិន្នន័យសរុបនៃគ្រប់ថវិកាក្នុងមូលនិធិសមធម៌ ដែលបានកត់ត្រាសម្រាប់ឆ្នាំ២០១០[9]។ ដោយសាររបាយការណ៍នៃមូលនិធិសមធម៌ពុំផ្តល់ព័ត៌មាន គ្រប់គ្រាន់ និន្នន័យសំណាកនឹងត្រូវប្រើប្រាស់ក្នុងករណីចាំបាច់[10]។

### ៦.៦.៣ អត្រានៃការប្រើប្រាស់សេវា

**អត្រានៃការប្រើប្រាស់សេវា**គិតជាមធ្យម សម្រាប់អ្នកមកពិគ្រោះជម្ងឺនិងអ្នកត្រូវសម្រាកព្យាបាលជម្ងឺនៅមន្ទីរពេទ្យ ត្រូវបានគណនាដោយផ្អែកលើទិន្នន័យគោលនៅឆ្នាំ២០១០។ អត្រានៃការប្រើប្រាស់សេវា នៅមានកម្រិតទាបបើធៀបនឹងកម្រិតអន្តរជាតិ ពិសេសសម្រាប់ការពិនិត្យព្យាបាលដល់អ្នកដែលមកពិនិត្យជម្ងឺនៅមន្ទីរពេទ្យ ដែលមានកម្រិតប្រហែល០,៥៩ដង នៃការមកពិនិត្យព្យាបាលសម្រាប់មនុស្សម្នាក់ក្នុងមួយឆ្នាំ គិតជាមធ្យមសម្រាប់ឆ្នាំ ២០១០[11]។ ដូច្នេះ អត្រានៃការប្រើប្រាស់សេវារបស់អ្នកដែលមកពិគ្រោះជម្ងឺ ត្រូវសន្មតថានឹងកើនឡើងយ៉ាងឆាប់រហ័ស ក្នុងអំឡុងពេលនៃការធ្វើនិទស្សន៍ ដើម្បីឈានទៅដល់កម្រិតមួយដែលអាចចាត់ទុកថាជាកម្រិត "**ធម្មតា**" ក្នុងបរិបទនៃឆ្នាំ ២០២០[12]។

---

[9] ទិន្នន័យផ្តល់ដោយលោកស្រី វេជ្ជបណ្ឌិត សុក កញ្ញា នៃនាយកដ្ឋានផែនការនិងព័ត៌មានសុខាភិបាល នៃក្រសួងសុខាភិបាល ។

[10] ព័ត៌មានស្តីពីអត្រានៃការប្រើប្រាស់សេវាសុខាភិបាល ពុំបានកត់ត្រានៅក្នុងគ្រប់របាយការណ៍ នៃមូលនិធិសមធម៌ទេ ។

[11] កម្រិតទាបនៃអត្រានៃការប្រើប្រាស់សេវាចំពោះអ្នកមកពិគ្រោះជម្ងឺ អាចបកស្រាយបានថាបណ្តាលមកពីកង្វះការកត់ត្រាព័ត៌មាននៅកម្រិតកម្មវិធីមូលនិធិសមធម៌និងអ្នកផ្តល់សេវា ឧបសគ្គនៃការទទួលបានសេវា កង្វះការយល់ដឹងស្តីពីសិទ្ធិសម្រាប់ជនក្រីក្រ ចំណង់ចំណូលចិត្តនៃការប្រើប្រាស់ជម្រើសព្យាបាលដែលងាយស្រួលផ្សេងទៀត (ឧទាហរណ៍ ការទទួលសេវាពីអ្នកលក់ថ្នាំពេទ្យដែលមានថ្លៃថោកនៅក្បែរផ្ទះ)។

[12] ទិន្នន័យគោលធម្មតានៃអត្រានៃការប្រើប្រាស់សេវាថែទាំសុខភាពនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ គឺការមកពិគ្រោះជម្ងឺចំនួនពីរដងក្នុងមនុស្សម្នាក់ក្នុងមួយឆ្នាំសម្រាប់អ្នកមកពិគ្រោះជម្ងឺ និង០,០៥ដង សម្រាប់អ្នកមកសម្រាកព្យាបាលជម្ងឺនៅមន្ទីរពេទ្យ។ ដោយសារអត្រានៃការប្រើប្រាស់សេវានឹងកើនឡើងជាប្រចាំ អត្រាគោលដៅសម្រាប់ឆ្នាំ២០២០សម្រាប់អ្នកមកសម្រាកព្យាបាលជម្ងឺត្រូវបានកម្រិតដល់០,៦ដងក្នុងមនុស្សម្នាក់ក្នុងមួយឆ្នាំនៅឆ្នាំ២០២០ ដោយសន្មតថាកំណើនប្រចាំឆ្នាំគឺស្មើនិង២,៥% ចាប់ពីឆ្នាំ ២០១០។

## តារាង ៦.១២ អត្រានៃការប្រើប្រាស់សេវាថែទាំសុខភាព សន្មតសម្រាប់ឆ្នាំ ២០១០-២០២០

| | ២០១០[១] | ២០១១ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ |
|---|---|---|---|---|---|---|---|---|---|---|---|
| ការមកពិនិត្យជំងឺ [២] | **0.59** | **0.73** | **0.87** | **1.01** | **1.15** | **1.30** | **1.44** | **1.58** | **1.72** | **1.86** | **2.00** |
| មណ្ឌលសុខភាព | 0.56 | 0.69 | 0.82 | 0.95 | 1.09 | 1.22 | 1.35 | 1.49 | 1.62 | 1.75 | 1.88 |
| មន្ទីរពេទ្យបង្អែក | 0.03 | 0.04 | 0.05 | 0.06 | 0.07 | 0.08 | 0.08 | 0.09 | 0.10 | 0.11 | 0.12 |
| ការព្យាបាលនៅពេទ្យ [៣] | **0.047** | **0.048** | **0.050** | **0.051** | **0.052** | **0.054** | **0.055** | **0.056** | **0.057** | **0.059** | **0.060** |
| ករណីតូចតាច | 0.044 | 0.046 | 0.047 | 0.048 | 0.049 | 0.051 | 0.052 | 0.053 | 0.054 | 0.055 | 0.057 |
| ការវះកាត់ | 0.003 | 0.003 | 0.003 | 0.003 | 0.003 | 0.003 | 0.003 | 0.003 | 0.003 | 0.003 | 0.003 |

**កំណត់សម្គាល់**

១. តួរលេខជាក់ស្តែងសម្រាប់ឆ្នាំ ២០១០ ដែលប៉ាន់ប្រមាណដោយប្រើប្រាស់ទិន្នន័យនៃ ក្រសួងសុខាភិបាល

២. សមមាត្រនៃករណីមកពិគ្រោះជម្ងឺនៅមន្ទីរពេទ្យបង្អែក ត្រូវសន្មតថាស្ថិតនៅថេរ ក្នុងកម្រិត៥,៩%នៃករណីសរុប (កំណត់សម្គាល់ទី៨ ខាងក្រោម)

៣. ដោយលើកលែងការសម្រាលកូន សមមាត្រនៃការវះកាត់ត្រូវសន្មតថាស្ថិតនៅថេរ ក្នុងកម្រិត៥,៦%នៃគ្រប់ករណីមកពិនិត្យព្យាបាលជម្ងឺទាំងអស់ (កំណត់សម្គាល់ទី ៨ ខាងក្រោម)

**ប្រភព:** ការគណនារបស់អ្នកនិពន្ធ និងទិន្នន័យក្រសួងសុខាភិបាល (MoH, ២០១២)

ចំពោះការសម្រាលកូន អត្រាប្រើប្រាស់សេវារបស់អ្នកមកសម្រាកព្យាបាលនៅមន្ទីរពេទ្យ អាចគណនាបានដោយគុណចំនួននៃកំណើតទារកក្នុងចំណោមជនក្រីក្រ (ចំនុច ៦.៥.១) ទៅនឹងអត្រានៃការសម្រាលកូននៅមន្ទីរពេទ្យ។ អត្រានៃការសម្រាលកូននៅមន្ទីរពេទ្យ ត្រូវសន្មតថានឹងមានកំណើនជាប្រចាំ ពី៧០%នៅឆ្នាំ២០១២ ដល់១០០% នៅឆ្នាំ២០១៨ (តារាង ៦.១៣)។

ចំនួនដងនៃករណីផ្តល់លាភការជាសាច់ប្រាក់ដែលផ្តល់ជូនអ្នកជម្ងឺ ត្រូវសន្មតថាស្មើនឹងចំនួនប៉ាន់ស្មាននៃករណីដែលជនក្រីក្របានមកប្រើប្រាស់សេវា ពិសេសក្នុងករណីនៃការបញ្ជូនទៅមន្ទីរពេទ្យបង្អែកសម្រាប់ករណីនៃអ្នកជម្ងឺដែលសម្រាកនៅមន្ទីរពេទ្យ គិតរួមទាំងការសម្រាលកូនស្មុគ្រស្មាញ។

## តារាង ៦.១៣ ការសម្រាលកូន ក្រោមកម្មវិធីមូលនិធិសមធម៌និទស្សន៍សម្រាប់ឆ្នាំ ២០១២ - ២០២០

| | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ |
|---|---|---|---|---|---|---|---|---|---|
| គ្រួសារក្រីក្រ (គិតជាលានគ្រួសារ) | 1.82 | 1.74 | 1.66 | 1.57 | 1.48 | 1.39 | 1.30 | 1.20 | 1.10 |
| ចំនួនកំណើតកុមារ (គិតជាពាន់) [១] | 84.5 | 79.6 | 74.5 | 69.3 | 64.8 | 60.1 | 55.2 | 50.1 | 45.0 |
| អត្រានៃការបង្កើតទារកនៅពេទ្យ (%) [២] | 70 | 75 | 80 | 85 | 90 | 95 | 100 | 100 | 100 |
| ការបង្កើតទារកនៅពេទ្យ (គិតជាពាន់) [៣] | **59.2** | **59.7** | **59.6** | **58.9** | **58.3** | **57.0** | **55.2** | **50.1** | **45.0** |
| ការបង្កើតទារកនៅមណ្ឌលសុខភាព | 41.4 | 41.8 | 41.7 | 41.2 | 40.8 | 39.9 | 38.6 | 35.1 | 31.5 |
| ការបង្កើតទារកនៅមន្ទីរពេទ្យបង្អែក | 17.8 | 17.9 | 17.9 | 17.7 | 17.5 | 17.1 | 16.5 | 15.0 | 13.5 |

**កំណត់សម្គាល់**

១. ការនិទស្សន៍របស់អ្នកនិពន្ធ
២. ការសន្មតរបស់ក្រសួងសុខាភិបាល សម្រាប់ឆ្នាំ ២០១២ - ២០១៥
៣. ការសម្រាលកូននៅមណ្ឌលសុខភាព ត្រូវសន្មតថាស្មើនឹង ៧០% នៃករណីសរុប (ការសន្មតរបស់ក្រសួងសុខាភិបាល)
**ប្រភព:** ការសន្មតរបស់អ្នកនិពន្ធ និទស្សន៍ដោយផ្អែកលើទិន្នន័យក្រសួងសុខាភិបាល

### ៦.៦.៤ ថវិកាចំណាយក្នុងមួយឯកតា

ថវិកាចំណាយក្នុងមួយឯកតា ជាការចំណាយថវិកាគិតជាមធ្យមសម្រាប់មួយករណីនៃការប្រើប្រាស់សេវាសុខាភិបាល ដែលផ្តល់ឲ្យដោយកម្មវិធីមូលនិធិសមធម៌នៅក្នុងសមាសភាគនៃការចំណាយដោយផ្ទាល់ ហើយគណនាសម្រាប់ឆ្នាំ២០១២ ដោយផ្អែកលើទិន្នន័យនៃក្រសួងសុខាភិបាល (តារាង ៦.១៤)។ ប្រការនេះឆ្លុះបញ្ចាំងពីបែបផែនថ្មីនៃសុខដុមនីយភាពរវាងអត្រានៃការបង់ថ្លៃរបស់ប្រតិបត្តិករនៃមូលនិធិសមធម៌ផ្សេងៗគ្នា ដែលប្រកាសដោយក្រសួងសុខាភិបាលនៅឆ្នាំ២០១១ ហើយដែលមានប្រសិទ្ធិភាពចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០១២។ ម្យ៉ាងទៀត ការបង់ថ្លៃរបស់មូលនិធិសមធម៌ពុំឆ្លុះបញ្ចាំងពីថវិកាចំណាយទាំងមូលនៃការព្យាបាលទេ ប៉ុន្តែគ្របដណ្តប់តែទៅលើផ្នែកមួយនៃការបង់ថ្លៃជំនួសទៅឲ្យប្រតិបត្តិករ ពីសំណាក់មូលនិធិសមធម៌តែប៉ុណ្ណោះ។

ដើម្បីធ្វើការនិទស្សន៍លើថវិកាចំណាយក្នុងមួយឯកតា ដែលនឹងត្រូវកើតមានសម្រាប់ថ្ងៃអនាគត តួរលេខនៃឆ្នាំ២០១២ដែលជាឆ្នាំគោល ត្រូវបានកែសម្រួលជាមួយនឹងអត្រាអតិផរណានៃថ្លៃឱសថ ដែលសន្មតថាស្មើនឹងអត្រាអតិផរណានៃថ្លៃទំនិញរបស់អ្នកប្រើប្រាស់បូកថែម២% ដែលតួរលេខ២%នេះគឺជាកត្តាបច្ចេកវិទ្យា ដែលពាក់ព័ន្ធនឹងអតិផរណានៃថ្លៃឱសថ។

**តារាង ៦.១៤ ថវិកាចំណាយក្នុងមួយឯកតាសម្រាប់លាភការ ក្នុងកម្មវិធី មូលនិធិសមធម៌ និទស្សន៍សម្រាប់ឆ្នាំ ២០១២ - ២០២០**

| គិតជាដុល្លារក្នុងមួយករណី | ២០១២ [១] | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ |
|---|---|---|---|---|---|---|---|---|---|
| ការមកពិនិត្យជំងឺ | | | | | | | | | |
| មណ្ឌលសុខភាព | 1.00 | 1.06 | 1.11 | 1.17 | 1.22 | 1.28 | 1.35 | 1.42 | 1.49 |
| មន្ទីរពេទ្យបង្អែក [២] | 1.98 | 2.10 | 2.20 | 2.31 | 2.43 | 2.55 | 2.68 | 2.81 | 2.95 |
| ការព្យាបាលនៅពេទ្យ | | | | | | | | | |
| ករណីតូចតាច [២] | 25.50 | 26.96 | 28.30 | 29.72 | 31.21 | 32.77 | 34.40 | 36.12 | 37.93 |
| ការវះកាត់ [២] | 87.40 | 92.38 | 97.00 | 101.85 | 106.94 | 112.29 | 117.90 | 123.80 | 129.99 |
| ការសម្រាលកូន | | | | | | | | | |
| មណ្ឌលសុខភាព | 15.00 | 15.86 | 16.65 | 17.48 | 18.35 | 19.27 | 20.24 | 21.25 | 22.31 |
| មន្ទីរពេទ្យបង្អែក [២] | 25.50 | 26.96 | 28.30 | 29.72 | 31.21 | 32.77 | 34.40 | 36.12 | 37.93 |
| សោហ៊ុយធ្វើដំណើរ [២] | 6.93 | 7.19 | 7.40 | 7.62 | 7.85 | 8.09 | 8.33 | 8.58 | 8.84 |
| ប្រាក់ឧបត្ថម្ភអាហារ [២] | 8.12 | 8.42 | 8.67 | 8.93 | 9.20 | 9.47 | 9.76 | 10.05 | 10.35 |
| ប្រាក់ឧបត្ថម្ភមិនសម្រាប់អាហារ [២] | 0.28 | 0.29 | 0.30 | 0.31 | 0.32 | 0.33 | 0.34 | 0.35 | 0.36 |
| ប្រាក់ឧបត្ថម្ភដល់អ្នកផ្តល់សេវា [២] | 0.48 | 0.50 | 0.51 | 0.53 | 0.55 | 0.56 | 0.58 | 0.60 | 0.61 |

**កំណត់សម្គាល់**

១. គណនាដោយផ្អែកលើអត្រាបង់ថ្លៃនៅ ប្រតិបត្តិករ ដែលបានកែប្រែរួច និងមានសុពលភាព ចាប់ពីថ្ងៃទី១ ខែ មករា ឆ្នាំ ២០១២
២. កែសម្រួលគិតជាមធ្យម ដោយផ្អែកលើករណីពិនិត្យព្យាបាល នៅមន្ទីរពេទ្យ CPA1, CPA2, និង CPA3 នៅឆ្នាំ ២០១០

## ៦.៦.៥ វិសាលភាព

យោងទៅតាមក្រសួងសុខាភិបាល ការពង្រីកវិសាលភាពនៃមូលនិធិសមធម៌សម្រាប់ជនក្រីក្រទាំងអស់ (ជនក្រីក្របំផុត និងជនក្រីក្រ) នឹងអាចសម្រេចបាននៅឆ្នាំ២០១៣[13]។ សម្រាប់ការវាយតម្លៃផ្នែកហិរញ្ញប្បទាននៅក្នុងឯកសារនេះ (ជំពូក ៤ ចំនុច ៤.៤) វិសាលភាព ពេញលេញនៃកម្មវិធីត្រូវបានសន្មតថានឹងធ្វើឡើងនៅឆ្នាំ២០១២ ដើម្បីបង្ហាញថាថវិកាចំណាយប្រៀបធៀបនៃមូលនិធិសមធម៌ដែលមានវិសាលភាពពេញលេញដូចគ្នាសម្រាប់ឆ្នាំដ៏ទៃទៀត ក្នុងអំឡុងពេលនៃការធ្វើនិទស្សន៍។

## ៦.៦.៦ លទ្ធផលនៃការធ្វើនិទស្សន៍

ចំនួនប៉ាន់ប្រមាណនៃការមកពិនិត្យព្យាបាល ដែលនឹងធ្វើឲ្យមានកំណើនទៅដល់ការបង់ថ្លៃលើលាភការ អាចគណនាបានដោយគុណទំហំវិសាលភាពដែលប៉ាន់ប្រមាណ ទៅនឹងអត្រាឧប្បត្តិហេតុ ឬអត្រានៃការប្រើប្រាស់លាភការក្នុងសេវាសុខាភិបាល (តារាង ៦.១៥)។

**តារាង ៦.១៥ ចំនួននៃការមកពិនិត្យព្យាបាល សម្រាប់មូលនិធិសមធម៌ និទស្សន៍សម្រាប់ឆ្នាំ ២០១២ - ២០២០**

| គិតជាពាន់ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ |
|---|---|---|---|---|---|---|---|---|---|
| ការមកពិនិត្យជំងឺ | **3 016.2** | **3 353.0** | **3 641.5** | **3 879.0** | **4 063.2** | **4 191.6** | **4 261.6** | **4 270.1** | **4 214.3** |
| មណ្ឌលសុខភាព | 2 839.7 | 3 156.8 | 3 428.4 | 3 652.0 | 3 825.4 | 3 946.3 | 4 012.2 | 4 020.2 | 3 967.7 |
| មន្ទីរពេទ្យបង្អែក | 176.5 | 196.2 | 213.1 | 227.0 | 237.8 | 245.3 | 249.4 | 249.9 | 246.6 |
| ការព្យាបាលនៅពេទ្យ | **171.7** | **168.6** | **164.8** | **160.4** | **155.1** | **149.2** | **142.4** | **134.9** | **126.4** |
| ករណីតូចតាច | 162.0 | 159.1 | 155.6 | 151.3 | 146.4 | 140.8 | 134.4 | 127.3 | 119.3 |
| ការវះកាត់ | 9.7 | 9.5 | 9.3 | 9.0 | 8.7 | 8.4 | 8.0 | 7.6 | 7.1 |
| ការសម្រាលកូន | **59.2** | **59.7** | **59.6** | **58.9** | **58.3** | **57.0** | **55.2** | **50.1** | **45.0** |
| មណ្ឌលសុខភាព | 41.4 | 41.8 | 41.7 | 41.2 | 40.8 | 39.9 | 38.6 | 35.1 | 31.5 |
| មន្ទីរពេទ្យបង្អែក | 17.8 | 17.9 | 17.9 | 17.7 | 17.5 | 17.1 | 16.5 | 15.0 | 13.5 |
| សោហ៊ុយធ្វើដំណើរ [១] | **110.9** | **109.4** | **107.3** | **104.6** | **101.6** | **98.0** | **93.8** | **88.2** | **82.1** |
| ប្រាក់ឧបត្ថម្ភអាហារ [១] | **110.9** | **109.4** | **107.3** | **104.6** | **101.6** | **98.0** | **93.8** | **88.2** | **82.1** |
| ប្រាក់ឧបត្ថម្ភមិនសម្រាប់អាហារ [១] | **110.9** | **109.4** | **107.3** | **104.6** | **101.6** | **98.0** | **93.8** | **88.2** | **82.1** |
| ប្រាក់ឧបត្ថម្ភដល់អ្នកផ្តល់សេវា [១] | **110.9** | **109.4** | **107.3** | **104.6** | **101.6** | **98.0** | **93.8** | **88.2** | **82.1** |

**កំណត់សម្គាល់**

[13] ព័ត៌មាន ផ្តល់ដោយលោកស្រី វេជ្ជបណ្ឌិត សុក កញ្ញា

១. ចំនួនប៉ាន់ប្រមាណសម្រាប់មន្ទីរពេទ្យបង្អែក ដោយសន្មតថាអត្រានៃការប្រើប្រាស់សេវានៅមន្ទីរពេទ្យបង្អែក នឹងស្ថិតនៅថេរ ក្នុងអំឡុងពេលនៃការនិទស្សន៍

**ប្រភព:** អង្គការអន្តរជាតិខាងការងារ

ការប៉ាន់ប្រមាណលើថវិកាចំណាយសម្រាប់ការផ្តល់លាភការដោយផ្ទាល់ អាចគណនាបានដោយគុណចំនួននៃការមកពិនិត្យព្យាបាលនៃឆ្នាំនីមួយៗ (តារាង ៦.១៥) ទៅនឹងថវិកាចំណាយដោយប៉ាន់ប្រមាណសម្រាប់មួយឯកតានៃកញ្ចប់លាភការដូចគ្នា (តារាង ៦.១៤)។ ថវិកាចំណាយសរុបនៃការចំណាយថវិកាដោយផ្ទាល់ គឺជាផលបូកនៃថ្លៃចំណាយក្នុងសមាសភាគនីមួយៗ សម្រាប់ឆ្នាំនីមួយៗ (តារាង ៦.១៦) ។

### តារាង ៦.១៦ ថវិកាចំណាយសម្រាប់ ការចំណាយដោយផ្ទាល់ នៅក្នុងមូលនិធិសមធម៌ និទស្សន៍សម្រាប់ឆ្នាំ ២០១២ - ២០២០ (គិតជាពាន់ដុល្លារ)

| គិតជាដុល្លារ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ |
|---|---|---|---|---|---|---|---|---|---|
| ការមកពិនិត្យជំងឺ | **3 189.8** | **3 748.2** | **4 274.2** | **4 780.6** | **5 258.0** | **5 695.4** | **6 080.0** | **6 396.7** | **6 628.9** |
| មណ្ឌលសុខភាព | 2 839.7 | 3 336.7 | 3 805.0 | 4 255.9 | 4 680.8 | 5 070.2 | 5 412.5 | 5 694.5 | 5 901.2 |
| មន្ទីរពេទ្យបង្អែក | 350.2 | 411.5 | 469.2 | 524.8 | 577.2 | 625.2 | 667.4 | 702.2 | 727.7 |
| ការព្យាបាលនៅពេទ្យ | **4 977.0** | **5 166.2** | **5 303.3** | **5 417.0** | **5 502.8** | **5 555.8** | **5 569.5** | **5 537.1** | **5 450.9** |
| ករណីតូចតាច | 4 132.0 | 4 289.1 | 4 402.9 | 4 497.3 | 4 568.6 | 4 612.6 | 4 624.0 | 4 597.1 | 4 525.5 |
| ការវះកាត់ | 844.9 | 877.1 | 900.3 | 919.6 | 934.2 | 943.2 | 945.5 | 940.0 | 925.4 |
| ការសម្រាលកូន | **1 074.0** | **1 145.3** | **1 200.7** | **1 245.6** | **1 294.6** | **1 330.4** | **1 350.7** | **1 289.0** | **1 215.9** |
| មណ្ឌលសុខភាព | 621.3 | 662.6 | 694.6 | 720.6 | 748.9 | 769.6 | 781.4 | 745.7 | 703.4 |
| មន្ទីរពេទ្យបង្អែក | 452.7 | 482.8 | 506.1 | 525.1 | 545.7 | 560.8 | 569.3 | 543.3 | 512.5 |
| សោហ៊ុយធ្វើដំណើរ [១] | **768.4** | **785.9** | **794.1** | **797.8** | **798.1** | **792.9** | **781.4** | **756.7** | **725.5** |
| ប្រាក់ឧបត្ថម្ភអាហារ [១] | **899.9** | **920.5** | **930.1** | **934.4** | **934.8** | **928.6** | **915.2** | **886.2** | **849.7** |
| ប្រាក់ឧបត្ថម្ភមិនសម្រាប់អាហារ [១] | **31.0** | **31.8** | **32.1** | **32.2** | **32.2** | **32.0** | **31.6** | **30.6** | **29.3** |
| ប្រាក់ឧបត្ថម្ភដល់អ្នកផ្តល់សេវា [១] | **53.4** | **54.6** | **55.2** | **55.4** | **55.4** | **55.1** | **54.3** | **52.6** | **50.4** |
| សរុបថវិកាចំណាយដោយផ្ទាល់ | **10 994** | **11 852** | **12 590** | **13 263** | **13 876** | **14 390** | **14 783** | **14 949** | **14 951** |

**ប្រភព:** អង្គការអន្តរជាតិខាងការងារ

# ឯកសារពិគ្រោះ

Council for Agricultural and Rural Development (CARD). 2010. *Towards a social protection strategy for the poor and vulnerable: Outcomes of the consultation process* (Phnom Penh).

International Labour Office. 2010. *A Public Works Programme as part of the National Social Protection Strategy: A framework for implementation* (Phnom Penh, CARD).

— 2012. *Cambodia: Social protection expenditure and performance review*, EU/ILO Technical Assistance Report (Geneva).

International Monetary Fund. 2012. *Article IV Consultation 2011, Staff Report: Cambodia*, Report No. 12/46 (Washington DC).

Knowles, J. C. 2005. *A new set of poverty estimates for Cambodia, 1993/94 to 2004*, Report to the EAS Country Units of the World Bank (Washington DC).

— 2009. *Poverty profile and trends in Cambodia, 2007: Findings from the Cambodia Socio-Economic Survey (CSES)*, Report No. 48618-KH (World Bank, East Asia and Pacific Division). Available at: www. worldbank.org/.

Ministry of Health (MOH). 2011. *Circular No. 110/O/12 (HSSP2): Standard benefit package and provider payment mechanism for Health Equity Funds* (Phnom Penh).

Ministry of Planning (MOP). 1998. *Cambodia Human Development Report* (Phnom Penh).

National Institute of Statistics. 2009. *General Population Census of Cambodia 2008, National Report on Final Census Results* (Phnom Penh).

— 2010. *General Population Census 2008, analysis of the Census Results, Report 8: Economic activity and employment*, Report for the Ministry of Planning (Phnom Penh).

— 2011. *General Population Census 2008, analysis of the census results, Report 12: Population projection for Cambodia*, Report for the Ministry of Planning (Phnom Penh).

Prescott, N.; Pradhan, M. 1997. *A poverty profile of Cambodia*, World Bank Discussion paper No. 373 (Washington DC, World Bank).

Royal Government of Cambodia (RGC). 2011a. *National Social Protection Strategy for the Poor and Vulnerable*, prepared by the Council for Agricultural and Rural Development (CARD) )Phnom Penh).

— 2011b. *Mid-Term Review on National Strategic Development Plan, Update 2009–2013* (Phnom Penh).